ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 27-Apr-2012, 13:52
CMS/CFO: Uch Arun

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១២**

**ម៉ោង ០៩:០២ នាទី**

**សវនាការលើកទី៥៧**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ដាវ អានសាន

លោក អេនឌ្រូ ចេមស៍ ម៉ាគិនថាយអ៊័រ
*(Andrew James MCINTYRE)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាវស្មី

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោកស្រី អង់តា ហ្គីសសេ

*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ូនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ម៉ុច សុវណ្ណារី

លោក ហុង គីមសួន

លោកស្រី ជេត វណ្ណលី

លោក ឡោ ជុនធី

លោក គីម ម៉េងឃី

លោក សំ សុគង់

លោក បាណាបេ ណេគ្វី

*(Mr. Barnabé NEKUIE)*

លោកស្រី អេលីហ្សាបេត រ៉ាបេសាន់ដ្រាតាណា

*(Ms. Elisabeth RABESANDARATANA)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក សាឡុត បាន (TCW-586) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី សាឡុត បាន** (TCW-586)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី៖............ទំព័រ០១

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន ផ្ដើមពី៖............ទំព័រ១៥

សួរដោយ លោក ម៉ៃខល កាណាវាស ផ្ដើមពី៖ ............ទំព័រ ៣១

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:៣៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសកិច្ចដំណើរការនីតិវិធីសវនាការ។

អរុណសួស្តីសាក្សី លោក សាឡុត បាន! អង្គជំនុំជម្រះដឹងថា លោកពិតជាមានការនឿយហត់ច្រើននៅក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មបីថ្ងៃកន្លងមកនេះ។ ប៉ុន្តែឥឡូវនេះកិច្ចដំណើរការ គឺទៅមុខហើយ ហើយជិតចប់ហើយដែរ។ អង្គជំនុំជម្រះសង្ឃឹមថា សាក្សីនឹងសហការជាមួយនឹងអង្គជំនុំជម្រះក្នុងការផ្តល់សក្ខីកម្ម តាមអ្វីដែលលោកបានដឹង បានឮ បានឃើញ ចងចាំ ពាក់ព័ន្ធទៅនឹងសំណួរដែលសួរដោយអង្គជំនុំជម្រះ និងដោយភាគី។ ជាពិសេសនៅអំឡុងពេលចុងនៃការដេញដោលចំពោះលោក គឺនឹងដល់វេទិកាទៅក្រុមមេធាវីការពារក្តី បន្ទាប់ពីអង្គជំនុំជម្រះតាំងសំណួរមួយចំនួន។

ដូច្នេះសូមលោកផ្តង់អារម្មណ៍ ហើយនិងធ្វើអារម្មណ៍ឲ្យបានត្រជាក់ និងនឹងនរ ដើម្បីត្រៀមក្នុងការស្តាប់នូវសំណួរ ហើយនិងឆ្លើយតបឲ្យបានត្រឹមត្រូវជាក់ច្បាស់ ជាប្រយោជន៍ដើម្បីរកការពិតនៅក្នុងរឿងក្តីនេះ។

ឥឡូវនេះយើងផ្ទាល់ក៏មានបញ្ហាមួយចំនួន ឃើញថា ភាគីបានសាក្សីសួរខ្លះហើយ ប៉ុន្តែដូចជាមិនច្បាស់ ហើយមានចំណុចខ្លះ ឃើញថាមានភាពខុសគ្នារវាងចម្លើយរបស់លោក។ ជាពិសេសប្រៀបនឹងចម្លើយលាយលក្ខណ៍អក្សរដែលបានឆ្លើយឲ្យការណ៍ នៅក្នុងអំឡុងពេលសាក្សីសួរលោកដោយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតនៅក្នុងអំឡុងពេលកន្លងមក។

[០៩:០៥:១៦]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** តើលោកអាចបញ្ជាក់ម្តងទៀតទេ ថាតើនៅក្នុងឆ្នាំ១៩៧៥, ៧៦ តើគណៈកម្មាធិការមជ្ឈិមបក្សមានសមាជិកប៉ុន្មាននាក់? ហើយតើអ្នកណាខ្លះ? តើលោកអាចរៀបរាប់ប្រាប់អង្គជំនុំជម្រះបានដែរទេ?

**លោក សាឡុត បាន៖**

**ឆ៖** បាទ គណៈកម្មាធិការមជ្ឈិមបក្ស ខ្ញុំមិនជាអ្នកស្ថាបនិក ហើយការប្រជុំបក្ស ខ្ញុំក៏មិនបានចូលរួម ហើយការប្រកាសមជ្ឈិមបក្សមានប៉ុន្មាននាក់ៗ ក៏អត់បានដឹង។ ដូច្នេះ ខ្ញុំមិនបានដឹងច្បាស់ទេបញ្ហានេះ។

[០៩:០៦:២២]

**ស៖** បាទ អរគុណ។ នៅចំពោះមុខអ្នកស៊ើបអង្កេត លោកបានឆ្លើយថា “តាមលោកដឹង គឺសមាជិកគណៈកម្មាធិការមជ្ឈិមបក្សមានចំនួនប្រហែល២០នាក់”។ បញ្ហា-- តើចម្លើយដែលលោកឆ្លើយនេះ យ៉ាងម៉េចដែរ?

**ឆ៖** ក្នុងចម្លើយនេះ ដោយខ្ញុំមានអារម្មណ៍ថា ចង់បំភ្លឺឲ្យតុលាការស៊ើបអង្កេតដឹង ខ្ញុំប្រើពាក្យប្រហែល មិនច្បាស់ទេលោក ប្រហែល។ ដោយសារសកម្មភាពធ្វើការងារ ខ្ញុំឃើញប្រហែលអ៊ីចេះអ៊ីចុះ។ តែប៉ុណ្ណឹងទេលោក។

**ស៖** ដល់ពេលនេះ លោក-- តើលោកគិតថាសមាជិកគណៈកម្មាធិការមជ្ឈិមបក្ស តាមដែលលោកកត់សម្គាល់ហ្នឹងមានទំនងប្រហែល២០នាក់ អ៊ីចឹងមែនដែរឬទេ?

[០៩:០៧:៣៧]

**ឆ៖** បាទ ប្រហែលដែរ។

**ស៖** បាទ អរគុណ។ ចុះគណៈកម្មាធិការអចិន្ត្រៃយ៍មជ្ឈិមបក្សទៅវិញ តើមានគ្នាប្រហែលប៉ុន្មាននាក់ដែរ? ហើយមានអ្នកណាខ្លះដែលលោកស្គាល់?

**ឆ៖** បញ្ហានេះក៏មិនមានប្រាប់ខ្ញុំឲ្យច្បាស់ថា អ្នកណាជាគណៈកម្មាធិការអចិន្ត្រៃយ៍ដែរ។ ខ្ញុំឃើញតែរូបភាព រូបភាពដែលប្រជុំជាមួយគ្នាជាញឹកញាប់ គឺមានតែពីរនាក់ទេ គឺ ប៉ុល ពត និងបង នួន ជា។

**ស៖** បាទ អរគុណ។ តើលោកស្គាល់ សុន សេន ទេ?

**ឆ៖** បាទ ខ្ញុំស្គាល់ សុន សេន។

**ស៖** តាមលោកដឹង តើ សុន សេន គាត់ជាសមាជិកអចិន្ត្រៃយ៍ គណៈកម្មាធិការមជ្ឈិមបក្សឬមិនមែនទេ?

**ឆ៖** តាមខ្ញុំដឹង ធ្វើការងារឃើញតែពីរនាក់ហ្នឹងទេអចិន្ត្រៃយ៍។ ឯ សុន សេន គាត់ម្តងមួយកាល។ តាមខ្ញុំស្មានទេ មិនច្បាស់ទេ ប្រហែលជាមិនមែនអចិន្ត្រៃយ៍ទេ។

**ស៖** បាទ អរគុណ។ ហើយគាត់ទទួលបន្ទុកកិច្ចការអ្វីដែរ សុន សេន នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** តាមខ្ញុំដឹងច្បាស់ គឺ សុន សេន ទទួលខុសត្រូវខាងយោធា។

[០៩:០៩:៥៧]

**ស៖** បាទ អរគុណ។ តាមលោកដឹងតើលោក ខៀវ សំផន គាត់ជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ឬក៏ជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្សដែរឬទេ?

**ឆ៖** ដូចជាសមាជិក គឺសមាជិកធម្មតា មិនមែនជាសមាជិកអចិន្ត្រៃយ៍ទេ។

**ស៖** អរគុណ សមាជិកធម្មតាហ្នឹង គឺមានន័យថា សមាជិកគណៈកម្មាធិការមជ្ឈិម អ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** លោកមានដែលឃើញលោក ខៀវ សំផន រស់នៅ ឬ/និង ឬក៏ធ្វើការជាមួយនឹងលោក អៀង សារី ជាមួយនិងលោក នួន ជា ហើយនិងលោក ប៉ុល ពត ដែរឬទេ?

[០៩:១១:១៨]

**ឆ៖** ខ្ញុំឃើញ ធ្លាប់ឃើញ ប៉ុន្តែមិនដឹងជាធ្វើការរបៀបណាទេ។

**ស៖** លោកបានឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត អ៎! អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតថា សំណួរគេសួរថា “តើលោក ខៀវ សំផន ធ្លាប់ជួបមុខជាមួយនឹងគ្នាជាមួយនឹងលោក អៀង សារី ដែរឬទេ?”។ លោកឆ្លើយថា “គាត់ជួបគ្នាដោយសារអ្នកដឹកនាំទាំងអស់នោះរស់នៅជាមួយគ្នា ដូច្នេះពួកគេដឹងការងារគ្នាទាំងអស់”។ លោកចាំចម្លើយនេះទេ?

**ឆ៖** បាទ ខ្ញុំចាំចម្លើយនេះ ប៉ុន្តែខ្ញុំសូមធ្វើអត្ថាធិប្បាយនឹងចម្លើយនេះ។ នេះតាមខ្ញុំយល់ចម្លើយគឺថា បើគេធ្វើការជាមួយគ្នាហើយ គេអាចដឹងការងារហើយ។ ការងារអីៗដឹងគ្នាហើយ នេះជាធម្មតាទេ បើធ្វើការងារជាមួយគ្នាដឹងហើយ ប៉ុន្តែខ្ញុំមិនដឹងការងារនោះជាអ្វីទេ។ បាទសូមបញ្ជាក់ប៉ុណ្ណឹងបាទ។

[០៩:១៣:១៩]

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការអាចបញ្ចាំងនូវឯកសារ D369/36 នៅលើកញ្ចក់អេក្រង់ទូរទស្សន៍! ហើយនិងអាចណែនាំគាត់ក្នុងករណីដែលខ្ញុំនឹងមានការពាក់ព័ន្ធទៅនឹងសំណួរ ដែលអាចដកស្រង់ចេញពី

សំណួរនៅក្នុងឯកសារនេះ។ ហើយឯកសារនេះ មានហើយ ប៉ុន្តែមិនទាន់ដល់ពេលទេ។ គ្រាន់ដាក់បញ្ចាំងឯកសារហ្នឹងនៅលើអេក្រង់កុំព្យូទ័រសិនទៅ!

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក បាន តើលោកស្គាល់មន្ទីរ៨៧០ ដែរឬទេ?

**លោក សាឡុត បាន៖**

**ឆ៖** បាទ ខ្ញុំស្គាល់មន្ទីរ៨៧០ មានច្រើនកន្លែង ចល័តច្រើនកន្លែងតាមសភាពការណ៍នៃការវិវត្តន៍សង្គ្រាមជំនាន់នោះ។ មានច្រើនបាទ។

**ស៖** តាមលោក ចម្លើយរបស់លោកនេះ មានន័យថា មន្ទីរ៨៧០ហ្នឹង គឺកើតមានយូរហើយ មិនមែនកើតមាន ទើបតែកើតមាននៅក្នុងអំឡុងឆ្នាំ១៩៧៥ ក្រោយ ១៧ មេសា ៧៥ទេ។ បានន័យថា កើតមានមុននឹងទៀត ពីព្រោះកើតមានតាំងពីសម័យសង្គ្រាមម្ល៉េះ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ។

[០៩:១៥:០០]

**ស៖** មន្ទីរ៨៧០ហ្នឹង ពិតប្រាកដហ្នឹង គឺជាមន្ទីរអ្វីទៅ? ព្រោះអានេះជាពាក្យលេខៗ លេខសម្ងាត់ទេលេខ កូដសម្ងាត់ទេ។ តាមពិតមន្ទីរនេះ គឺមន្ទីរអ្វីដលជាក់ច្បាស់?

**ឆ៖** ខ្ញុំមិនយល់ថាមន្ទីរ៨៧០នោះ ជាមន្ទីរមជ្ឈិម មន្ទីរអីទេ។ គេច្រើនតែហៅថា មន្ទីររបស់អង្គការៗ តែប៉ុណ្ណោះ និងអ្នកដឹកនាំ។

**ស៖** បាទ អរគុណច្រើន។ តាមឯកសារមន្ទីរនេះ កាលពីមុនថ្ងៃរំដោះថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ដូចជាមិនទាន់មានឈ្មោះថា “មន្ទីរ៨៧០” ទេ មានមន្ទីរ១០០ ហើយក្រោយទេ ហើយក្រោយមកទើបមានលេចនូវឈ្មោះ “មន្ទីរ៨៧០”។ តើមន្ទីរ៨៧០ និងមន្ទីរ១០០ ហ្នឹង វាមានចរិតដូចគ្នាគ្រាន់តែមានការប្តូរលេខកូដ ដោយសារមុនពេលអំឡុងសង្គ្រាម នៅក្នុងអំឡុងពេលសង្គ្រាម ហើយនិងក្រោយពេលសង្គ្រាម អ៊ីចឹងពិតមែនទេ?

[០៩:១៦:៣៩]

**ឆ៖** ខ្ញុំមិនបានវិភាគរឿងហ្នឹងទេ ខ្ញុំគ្រាន់តែប្រហែលជាអ៊ីចឹងបាទ។

**ស៖** បាទអរគុណ។ ចុះមន្ទីរអង្គការដែលបានរើពីខេត្តរតនគីរីមកនៅតំបន់ព្រៃមួយម្តុំព្រំប្រទល់រវាងដីខេត្តកំពង់ចាម ហើយនិងខេត្តកំពង់ធំតាមមាត់ស្ទឹង-- ដងស្ទឹងជីនិត មន្ទីរនុ៎ងគេដាក់លេខកូដអីដែរ

អង្កាល់ពីក្នុងសម័យសង្គ្រាមក្នុងអំឡុងឆ្នាំ៧០-៧៥?

**ឆ៖** មកដល់ពេលនេះ ខ្ញុំដូចជាភ្លេច ក៏ប៉ុន្តែខ្ញុំអាចចាំបានខ្លះដូចជា ស-២១ និងស-៧០។

**ស៖** ស-២១ហ្នឹង គឺសំដៅលើមន្ទីរអីទៅ? ហើយស-៧០ សំដៅលើមន្ទីរអីទៅ?

**ឆ៖** ស-២១ហ្នឹង គឺក៏មន្ទីរ៨៧០ដែរ នៅជាប់នឹងស្ទឹង-- ក្បែរស្ទឹងជីនិត។ ស-៧០ហ្នឹង ឆ្ងាយមកទៀត មកត្បូងស្ទឹងជីនិតទៀត ប្រហែលជាដើរមួយថ្ងៃ។

**ស៖** ភាពខុសគ្នាយ៉ាងដូចម្ដេចរវាងមន្ទីរ ដែលលោកនិយាយអម្បាញ់មិញស-២១ ហើយនិងមន្ទីរស-៧០ វាមានចរិតលក្ខណៈខុសគ្នាយ៉ាងដូចម្ដេចទៅរវាងអ្នកធ្វើការនៅទីនោះ ហើយនិងមុខងារនៃមន្ទីរស-២១ ហើយនិងមុខងារមន្ទីរស-៧០?

**ឆ៖** មន្ទីរស-២១ ជាកន្លែងសម្រាករបស់ដឹកនាំ ឯមន្ទីរស-៧១ នេះម្ដងម្កាលហៅគ្នាប្រជុំរៀនសូត្រ។

[០៩:១៩:២១]

**ស៖** បាទ អរគុណ។ ចុះដល់ក្រោយឆ្នាំ១៩៧៥ ក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ មន្ទីរ៨៧០ មានទីតាំងនៅកន្លែងណាទៅ?

**ឆ៖** ពេលនោះដូចជាឈប់ហៅមន្ទីរ៨៧០ហើយ វាចេះតែចល័ត ពីព្រោះខ្លាចកប៉ាល់ហោះខ្លាចអីទៅ ដូចជាមិនមានមន្ទីរអីធំដុំទេ ចេះតែចល័តចុះចល័តឡើងបាទ។ ហើយបើមានការប្រជុំអីធំដុំនាំគ្នាទៅប្រជុំនៅឯមន្ទីរស-៧១ ហ្នឹងដដែលបាទ។ ដូច្នេះ វាចល័ត អត់ជាមន្ទីរអីធំដុំទេលោក។

**ស៖** អត់ទេស្ដាប់សំណួរខ្ញុំឱ្យបាន។ សំណួរនោះគឺសួរថា ក្រោយ១៧ មេសា ឆ្នាំ១៩៧៥ ដែលនៅមានអត្ថិភាពមន្ទីរ៨៧០ បានន័យថានៅក្រុងភ្នំពេញ។ អ៊ីចឹង យើងចង់ដឹងថា តើមន្ទីរ៨៧០ហ្នឹង មានទីតាំងនៅកន្លែងណា? លោកដឹងដែរឬទេបាទ?

[០៩:២១:០២]

**ឆ៖** តាមខ្ញុំដឹងគឺនៅក-១ គេហៅថា ក-១ បាទ។ នៅមាត់ទន្លេនោះគេហៅ ក្បែរប៊ូលខឹងហ្នឹង បាទ យកផ្ទះប៊ូលខឹងហ្នឹង។

**ស៖** បាទ អរគុណ។ អ៊ីចឹង យើងអាចនិយាយអ៊ីចេះបានទេថា មន្ទីរ៨៧០ ឬក៏មន្ទីរក-១?

**ឆ៖** ពេលនោះ ខ្ញុំហៅតែមន្ទីរក-១ បាទ លែងហៅ ៨៧០ ហើយបាទ។

**ស៖** បាទ អរគុណ។ តាមលោកដឹងនៅក្រោយពេលរំដោះ ១៧ មេសា ឆ្នាំ១៩៧៥ នោះ ពេល

ដែលចប់សង្គ្រាមទៅ ហើយថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យ បានចូលមកកាន់កាប់នៅទីក្រុងភ្នំពេញ។ តើមន្ទីរ៨៧០ ឬក៏មន្ទីរក-១ហ្នឹង មានអ្នកណាជាប្រធានមន្ទីរ? ចាត់ចែងកិច្ចការទូទៅនៅក្នុងមន្ទីរ?

**ឆ៖** ចំពោះខ្ញុំគេឲ្យជួបតែលោក ប៉ង់ ម្នាក់ទេ ធ្វើអីៗក៏ដោយឆ្លងលោក ប៉ង់។ ដូច្នេះ ខ្ញុំយល់ឃើញថា គឺលោក ប៉ង់ នេះហើយជាប្រធានមន្ទីរ។

**សៈ** បាទ អរគុណ។ លោកមានដែលស្គាល់ឈ្មោះ ឌឿន ទេ សឿ វ៉ាស៊ី ហៅ ឌឿន?

**ឆ៖** បាទ ខ្ញុំស្គាល់។

**សៈ** តើ សឿ វ៉ាស៊ី ហៅ ឌឿន ហ្នឹង គាត់ធ្វើអ្វីដែរ? គាត់មានតួនាទីធ្វើអ្វីដែរ នៅមន្ទីរ៨៧០ ឬក៏ក-១ នោះ?

[០៩:២៣:៣៧]

**ឆ៖** ខ្ញុំដឹងថា គាត់ជាអនុរបស់ភូមិភាគ៣០៤។ ក្រោយមកទៀត ខ្ញុំទាក់ទងជាសំបុត្រស្នាមចូលទៅមន្ទីរក-១ ខ្ញុំឃើញ មិនមែនក-១ទេបាទ មន្ទីរក-១ នេះៗបំបែកទៅជាមន្ទីរមួយទៀត។ ក្រោយពីមន្ទីរក-១ មានមន្ទីរមួយទៀត នៅក្បែរផ្លូវប៉ាស្ទ័រ ដូចជា ក-២ៗ អ៊ីចឹងបាទ មន្ទីរហ្នឹងចល័ត ចល័តពីក-១ មកមានមន្ទីរក-២។ ខ្ញុំទាក់ទងសំបុត្រស្នាម ឃើញ ឌឿន នៅទីនោះ មិនដឹងជាមុខងារគាត់ធ្វើអីទេ ប៉ុន្តែឃើញចែកចាយ ឃើញគិតគូរ ខាងការចែកចាយភស្តុភារបាទ។

[០៩:២៤:៥៩]

**សៈ** ចុះលោក ខៀវ សំផន តើគាត់មានតួនាទីអ្វីដែលនៅក្នុងមន្ទីរអង្គការ ឬក៏មន្ទីរមជ្ឈិមនោះ?

**ឆ៖** ខៀវ សំផន ខ្ញុំគ្រាន់តែដឹងថា គាត់ជាគិតគូរខាងរណសិរ្ស។ ក៏ប៉ុន្តែចូលទៅក្នុងនោះ ពេលបាត់ ឌឿន ទៅ ខ្ញុំឃើញគាត់ទៅចែកចាយរបស់ទ្រុងដែរ។ ប៉ុន្តែនាទីគាត់មិនដឹងជានាទីអីទេ ក្នុងការចែកចាយនោះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ លោកមើលត្រង់ឯកសារ D369/36 ត្រង់សំណួរចម្លើយលេខ៣៩។

មន្ត្រីរដ្ឋបាលតុលាការបង្ហាញត្រង់ចំណួរចម្លើយ៣៩ ហើយនិងបង្ហាញជូនសាក្សី ឲ្យសាក្សីពិនិត្យលើចំណុច-- ត្រង់ចំណុចនេះ។

**សួរដោយប្រធានអង្គជំនុំ៖**

**សៈ** សាក្សីបានពិនិត្យហើយ ហើយខ្ញុំសូមអាន "សំណួរ៖ តើលោក ខៀវ សំផន មានតួនាទី

ជាអ្វី នៅក្នុងមន្ទីរ៨៧០? ឆ្លើយ៖ តាមខ្ញុំដឹង គាត់ជាសមាជិកមជ្ឈិមបក្ស ប៉ុន្តែចូលអចិន្ត្រៃយ៍ពេលណា ខ្ញុំមិនដឹងទេ។ គាត់ទទួលបន្ទុកការងាររណសិរ្ស ការប្រមូលកម្លាំង។ គ្រាន់តែឃើញមកជួបធ្វើការងារ ខ្ញុំសន្និដ្ឋាន ខៀវ សំផន ជាប្រធានមន្ទីរ៨៧០ ទទួលបន្ទុកចាត់ចែងសម្ភារៈ ក្រោយពី សឿ វ៉ាស៊ី ហៅ ឌឿន ត្រូវបានចាប់ខ្លួន។ ពេលចូលព្រៃដំបូង គាត់ធ្វើការក្នុងមន្ទីរមួយ ហៅថា មន្ទីររណសិរ្ស មិនមែនមន្ទីរមជ្ឈិមទេ។ ប៉ុន្តែ តែងតែចុះឡើងមកមន្ទីរមជ្ឈិម ដល់យូរទៅ គាត់ឡើងជាប្រធានរដ្ឋបានមកនៅក្នុងមន្ទីរមជ្ឈិមតែម្តង"។

[០៩:២៧:៣៣]

បាទ នេះ ជាចម្លើយរបស់លោកដែលបានឆ្លើយនៅចំពោះមុខអ្នកស៊ើបអង្កេត នៃការិយាល័យសហចៅក្រមស៊ើបអង្កេត។ តើចម្លើយដែលលោកបានឆ្លើយនេះយ៉ាងម៉េចដែរ? លោកមានអ្វីចង់ធ្វើអត្ថាធិប្បាយលើចម្លើយដែលឆ្លើយនេះទេ ដែលបានឆ្លើយនេះទេ?

**លោក សាឡុត បាន៖**

**ឆ៖** បាទ ក្នុងចម្លើយនេះ គឺសំណួរចង់ដឹងការពិត។ ប៉ុន្តែខ្ញុំប្រឹងរកការពិត ខ្ញុំប្រើពាក្យថា ខ្ញុំសន្និដ្ឋានតែប៉ុណ្ណោះបាទ។

**ស៖** អរគុណ។ អ៊ីចឹងហើយបានជាយើងចង់ដឹងច្បាស់ ពីព្រោះវាអត់ទាន់ច្បាស់ រវាងដែលលោកឆ្លើយអ៊ីចឹង ហើយលោកឆ្លើយបង្ហាញនូវពាក្យសន្និដ្ឋាន នៅក្នុងចម្លើយនេះ។ អ៊ីចឹងហើយបានជាយើងចង់ដឹង ថាតើការពិតដែលលោកដឹងយ៉ាងដូចម្តេចដែរ ចំពោះតួនាទីរបស់ ខៀវ សំផន នៅក្នុងមន្ទីរ៨៧០?

[០៩:២៨:១២]

**ឆ៖** ខ្ញុំដឹងថា ពេល ឌឿន បាត់ទៅ ការងារឋានៈណាក៏ដោយ ប្រធានរដ្ឋ ប្រធានអីក៏ដោយ តែការងារណាដែលមិនទាន់បានចាត់ចែង គឺថ្នាក់លើត្រូវតែឲ្យធ្វើ។ ដូច្នេះគាត់ទៅជួយជាបណ្តោះអាសន្នជួយការងារនោះ ជាបណ្តោះអាសន្នតែប៉ុណ្ណោះ។

**ស៖** បាទ អរគុណ។ លោកបាននិយាយប៉ុន្មានថ្ងៃនេះ ការគឺដល់ឈ្មោះ ប៉ង់ បានន័យថាលោកស្គាល់ឈ្មោះ ប៉ង់ ច្បាស់ណាស់។ តើឈ្មោះ ប៉ង់ នេះ ឈ្មោះពិតប្រាកដរបស់គាត់នោះ ឈ្មោះអ្វីទៅ? ឈ្មោះពេញលេញ? នៃឈ្មោះពេញលេញគាត់ឈ្មោះអីទៅ? លោកដឹងទេ?

**ឆ៖** មកដល់ពេលនេះ ឈ្មោះ ប៉ង់ នេះឈ្មោះពេញលេញខ្ញុំអត់បានដឹងទាល់តែសោះបាទ។

**ស៖** បាទ អរគុណ។ តើលោកដែលឮឈ្មោះ ឈឹម សំអោក?

**ឆ៖** បាទ ខ្ញុំអត់ដែលបានឮទេ។

**ស៖** អរគុណ។ តាមការដែលលោកសង្កេត ឬក៏ការចងចាំរបស់លោក តើឈ្មោះ ប៉ង់ ហ្នឹងមានតួនាទីអ្វីដែលនៅក្នុងមន្ទីរ៨៧០ ឬក៏មន្ទីរអង្គការនោះ?

**ឆ៖** តាមខ្ញុំដឹង ប៉ង់ នេះមានតួនាទីគ្រប់គ្រងក្រសួងទាំងអស់ដែលនៅក្រោមបញ្ជារបស់មជ្ឈិម បាទ។ គាត់មានសិទ្ធិគ្រប់គ្រងបាន គ្រប់មន្ទីរ។

[០៩:៣១:២៥]

**ស៖** បាទ អរគុណ។ ហើយលោកគិតមើលថាតើឈ្មោះ ប៉ង់ ហ្នឹងបានមកកាន់កាប់តួនាទីជា-- មានសិទ្ធិនៅក្នុងការគ្រប់គ្រងមន្ទីរក្រសួងជុំវិញមជ្ឈិមចាប់ពីពេលណាមក?

**ឆ៖** បាទ ខ្ញុំសូមកែតម្រូវសម្ដីខ្ញុំបន្តិច។ ពីដើមមកគេមិនដែលហៅមន្ទីរមជ្ឈិមទេ គេហៅតែអង្គការ ណ៎ះ បាទ អង្គការ បាទ។ គាត់គ្រប់គ្រងតាំងពីខ្ញុំឃើញនៅព្រៃ ទៅជួបគាត់ឃើញ ប៉ង់ នៅទីនោះតែម្ដង។ នៅឆ្នាំ១៩៦០-- ចុង១៦៧ ដើម៦៨ បាទ នៅរតនគិរី។

**ស៖** លោកគិតមើល ឥឡូវវាមានបញ្ហាអ៊ីចេះ បញ្ហាសំណួរ គឺសួរទៅ គឺថាមានឈ្មោះ ខឿន ដំបូងឡើយមានឈ្មោះ ខឿន។ ហើយក្រោយមកគឺត្រូវ ខឿន ទៅចាប់ខ្លួនទៅ កិច្ចការមន្ទីរ៨៧០ ឬក៏មន្ទីរមជ្ឈិមនេះ ដែលលោកហៅថា មន្ទីរអង្គការនេះ អ្នកដែលទៅធ្វើការបណ្ដោះអាសន្នគឺលោក ខៀវ សំផន ដោយអត់មានមនុស្សធ្វើ គឺលោក ខៀវ សំផន ប៉ុន្តែទន្ទឹមនឹងឃើញថា មានវត្តមាន ប៉ង់ មួយទៀត។ ហើយតាមលោកនិយាយអម្បាញ់មិញ គឺថា ប៉ង់ ហ្នឹងធ្វើកិច្ចការហ្នឹងតាំងពីក្នុងព្រៃមក ប៉ុន្តែចន្លោះមួយ នៅពេលដែលមានវត្តមាន ខឿន បែរជាអត់មាន អត់មានបាន លោកអត់មានបាននិយាយថានៅក្រោម ខឿន ឬក៏នៅពីលើ ខឿន ហ្នឹងមាន ប៉ង់ ទេ ក្រោយពេលដែលចាប់ឈ្មោះ ខឿន ហើយ។ ហើយជាបណ្ដោះអាសន្ន គឺ ខៀវ សំផន គាត់ទទួលជំនួសដោយអត់មានមនុស្សធ្វើការមកជួយធ្វើការងារ ហើយបន្ទាប់មកទើបមានឈ្មោះ ប៉ង់។ អ៊ីចឹងបញ្ហាមន្ទីរនេះ វាអាចតួនាទីរបស់ ប៉ង់ នេះ ប្រសិនបើណាតួនាទីរបស់ ប៉ង់ ហ្នឹងជាប្រធាន គាត់ជាប្រធាននៅពេលណាមក? ចាប់ពីពេលណាមក? ខ្ញុំនិយាយក្របខ័ណ្ឌត្រឹមក្រោយថ្ងៃ១៧ មេសា ៧៥។

[០៩:៣៤:២៣]

**ឆ៖** របស់ ប៉ង់? បាទ។ ខ្ញុំបានជម្រាបរួចហើយ គឺថាតួនាទីរបស់ ប៉ង់ ដែលខ្ញុំបានឃើញហ្នឹង

គឺថាជាប្រធានហ្នឹងក្នុងព្រៃក៏ ប៉ង់ ជាប្រធាន រហូតមកដល់ចូលក្រុងវិញនេះក៏ ប៉ង់ ជាប្រធានបាទ នៅតែជាប្រធាន។

**សៈ** អ៊ីចឹងយើងអាចនិយាយថា ប៉ង់ និងឈ្មោះ ខឿន ហ្នឹងគ្រប់គ្រងមន្ទីរខុសដោយឡែកពីគ្នាទេ នៅក្នុងអំឡុងពេលតែមួយក្រោយឆ្នាំ១៧ មេសា ៧៥ហ្នឹង គឺការ-- មានតួនាទីនៅក្នុងមន្ទីរអង្គការគ្រាន់តែមន្ទីរអង្គការហ្នឹងបែងចែកជាពីរ ដូចលោកនិយាយអំមិញអ៊ីចឹង មានក-១ មានក-២។ ហើយបើតាមឯកសារដែលបានសួរដេញដោលកន្លងមក គឺអត់មានឮថា ក-២ ទេ បានន័យថាមាន ក-៣, ក-១ និង ក-៣។ តើវាគ្រាន់តែខុសគ្នាត្រង់ថា កាន់កាប់មន្ទីរដោយឡែកពីគ្នា ប៉ុន្តែពេលវេលាគឺធ្វើការព្រមៗជាមួយគ្នា ចាប់ពីក្រោយថ្ងៃ១៧ មេសា ៧៥ មកអ៊ីចឹង ឬក៏យ៉ាងម៉េច?

**ឆៈ** នៅមន្ទីរក-២ ខ្ញុំបានឃើញៗ ពេល ខឿន នៅមន្ទីរក-២ នេះ ខ្ញុំឃើញ ប៉ង់ ក៏នៅទីនោះ ខឿន ក៏នៅទីនោះ បងខៀវ សំផន ក៏នៅទីនោះ។ ដល់តែពេល ខឿន បាត់ទៅ ឃើញបង ខៀវ សំផន ទៅជំនួស ខឿន រឿងចាត់ចែងអីវ៉ែអីវ៉ាន់។ ឯ ប៉ង់ ក៏នៅទីនោះដែរ។ ប៉ង់ ក៏នៅក្នុងមន្ទីរ ក-២ នោះដែរ។ ដូច្នេះ ខ្ញុំសន្និដ្ឋានថា ប៉ង់ ជាប្រធានមន្ទីរ៨៧០ ដដែល។

[០៩:៣៥:៥៤]

**សៈ** បាទ អរគុណ។ ចំណុចមួយទៀតនៅសំណួរចម្លើយ៤១ សូមលោកមើលឯកសារអម្បាញ់មិញ 369/36 សំណួរខាងក្រោមដែលយើងបានចង្អុលបង្ហាញ ពិភាក្សាគ្នាអម្បាញ់មិញនេះ គឺសំណួរចម្លើយ៤១។ សំណួរសួរលោកថា “តើ ប៉ង់ ធ្លាប់ជាប្រធានមន្ទីរ៨៧០ ដែរឬទេ? លោកឆ្លើយថា៖ បាទ គាត់ក៏ជាប្រធានដែរ តែចល័ត គឺមើលកិច្ចការខាងក្រៅ។ ប៉ុន្តែចំពោះខៀវ សំផន នៅតែខាងក្នុងប៉ុណ្ណោះ”។ សំណួរចម្លើយនេះយ៉ាងម៉េចដែរ លោកមានអីអត្ថាធិប្បាយដែរទេ?

**ឆៈ** បាទ ខ្ញុំសូមធ្វើអត្ថាធិប្បាយបន្តិចគឺថា បញ្ហានេះគឺខ្ញុំមិនមែនដឹងអីច្បាស់ទេ ក៏ប៉ុន្តែខ្ញុំចូលទៅ ខ្ញុំចេះតែសង្កេត ក្នុងការសង្កេតទេបាទ។ ប៉ង់ គឺអ្នកដើរបានដូចខ្ញុំបានមានជម្រាបជូនមុនហ្នឹង គឺដើរគ្រប់គ្រងមន្ទីរបាន។ ឯបង ខៀវ សំផន លោកនៅតែក្នុងមន្ទីរទេ លោកអត់មានចេញទៅណាបានទេលោក បាទ។

[០៩:៣៩:៣៨]

**សៈ** បាទ អរគុណ។ លោកបាននិយាយច្រើនហើយ ប៉ុន្តែយើងខ្ញុំស្តាប់មិនទាន់ ញែកឲ្យបានច្បាស់លាស់នៅក្នុងចំណោមមនុស្សដែល ប៉ង់ ទៅយកចេញពីមន្ទីរ បេ-១។ ដោយមិនទាន់ញែកច្បាស់

លាស់រវាងមនុស្សដែល ប៉ង់ យកមកផ្ញើមួយរយៈពេល រួចហើយយកចេញទៅ។ ហើយនិងករណី មួយទៀតដែល ប៉ង់ ហ្នឹងមកនាំយកមនុស្សចេញទៅដោយផ្ទាល់ ឬក៏មានលិខិតបង្គាប់បញ្ជាឲ្យមនុស្ស ផ្សេងទៀតមកទទួលយកមនុស្ស ដែលជាកម្មាភិបាល បុគ្គលិកនៃ បេ-១ ចេញទៅ។ តើរឿងនេះ យើងអាចញែកចេញជាពីរច្បាស់លាស់អ៊ីចឹងទេ រវាងមនុស្សដែល ប៉ង់ យកមកផ្ញើនៅក្នុង បេ-១ មួយរយៈពេល ហើយក្រោយមកក៏ ប៉ង់ មកខ្លួនឯង ឬក៏បង្គាប់ឲ្យមនុស្សផ្សេងទៀត ដែលមានលិខិតបញ្ជា បញ្ជាក់ច្បាស់លាស់ឲ្យមកទទួលយកមនុស្សហ្នឹងចាកចេញពី បេ-១ ហើយនិងមនុស្សមួយចំនួនទៀត គឺជាមនុស្សដែលជាកម្មាភិបាល ជាបុគ្គលនៃ បេ-១។ អ៊ីចឹងទេក្នុងការដែលនាំចេញទៅនោះ?

[០៩:៤១:២៥]

**ឆ៖** បាទ អ៊ីចឹងមែនបាទ។

**ស៖** បាទ អរគុណ។ តាមលោកដឹង តើមនុស្សដែល ប៉ង់ បាននាំយកចេញពីស្ថាប័ន ពីមន្ទីរ ឬក៏ពីទីកន្លែងផ្សេងៗយកមកផ្ញើនៅ បេ-១ ហើយមួយរយៈពេល បន្ទាប់មកក៏យកចេញទៅ។ តើមានចំនួនប្រហែលប៉ុន្មានដែរ តាម-- គ្រាន់តែជាចំនួនប្រហែលទេ វាប្រហាក់ប្រហែលប៉ុន្មានដែរ ក្នុងអំឡុងពេលដែលលោកធ្វើការនៅទីនោះ ហើយលោកធ្វើការកត់សម្គាល់ ឬក៏សង្កេតនោះ ប្រហែលជាប៉ុន្មានដែរ?

**ឆ៖** តាមខ្ញុំចងចាំ ក្រសួងការបរទេសមិនអាចរើសបុគ្គលិកផ្សេងៗទាំងបញ្ញាជន និងកសិករតាមចិត្តទេ។ ខ្ញុំមិនដែលរើសទេ បើខ្ញុំវិញ ខ្ញុំមិនដែលបានរើសទេបាទ។ គឺលោក ប៉ង់ បញ្ជូនមកទាំងអស់។ ដូច្នេះ ពេលដែល ប៉ង់ ត្រូវការយកនរណាទៅ គឺ ប៉ង់ មានសិទ្ធិយក។ នេះគឺជាសិទ្ធិរបស់ ប៉ង់ បាទ។

[០៩:៤៣:០០]

**ស៖** យើងអត់សួរអ៊ីចឹងទេ យើងសួរថា ពេលដែលមនុស្សយកមកផ្ញើ ហើយ ប៉ង់ មកយកចេញទៅវិញហ្នឹង តើមានចំនួនប្រហែលប៉ុន្មានដែរ?

**ឆ៖** ឯចំនួន ខ្ញុំពិនិត្យទៅអាចលើសពី២០ បាទ។

**ស៖** បាទ អរគុណ។ ចុះកម្មាភិបាលបុគ្គលិករបស់ក្រសួងការបរទេស ដែលត្រូវ ប៉ង់ មកយក ឬក៏បញ្ជាអ្នកផ្សេងឲ្យមកទទួលយកចេញទៅ មានចំនួនប្រហែលប៉ុន្មានដែរ ក្នុងអំឡុងពេលដែលចាប់តាំងពីដើមដំបូងរហូតនៃ-- រហូតដល់ថ្ងៃ០៦ មករា ៧៩ តាមលោកប៉ាន់ស្មាន ប្រហែល គ្រាន់តែប្រហែល

បានហើយ?

**ឆ៖** ប្រហែលជាពីរ ឬបីនាក់តែប៉ុណ្ណោះបាទ។ អ្នកមកយក លោកអូ! អ្នកដែលមកយក?

**ស៖** កម្មាភិបាល បុគ្គលរបស់ក្រសួងការបរទេស ដែលគេត្រូវពួក ប៉ង់ ហើយនិងអ្នកដែលទទួលបញ្ជាពី ប៉ង់ នាំយកចេញទៅ ចេញពីក្រសួងទៅ មានចំនួនប្រហែលប៉ុន្មានទៅ?

**ឆ៖** ប្រហែលជា២០អីនាក់។ ពី១៥ ទៅ ២០នាក់អីហ្នឹងបាទ។

[០៩:៤៥:00]

**ស៖** បាទអរគុណ។ កាលពីអំឡុងពេលកម្ពុជាប្រជាធិបតេយ្យហ្នឹង តើលោកស្គាល់មន្ទីរសន្តិសុខ ស-២១ ដែរទេ?

**ឆ៖** បាទ ខ្ញុំអត់ស្គាល់ទេ។ ឮតែឈ្មោះ។

**ស៖** បាទ អរគុណ។ តើលោកដឹងថា ប៉ង់ មកទទួលយកមនុស្សចាកចេញទៅទាំងមនុស្សដែល ប៉ង់ យកមកផ្ញើនៅក្រសួងការបរទេស ក៏ដូចជាកម្មាភិបាលបុគ្គលិករបស់ក្រសួងការបរទេសដែល ប៉ង់ មកទទួលយកខ្លួនឯង ឬក៏បង្គាប់បញ្ជាឲ្យអ្នកក្រោមឱវាទរបស់គាត់មកទទួលយកចេញទៅ តើលោកដឹងថា មនុស្សទាំងនោះត្រូវ ប៉ង់ និងមនុស្សរបស់ ប៉ង់ មកនាំទទួលយកៗទៅហ្នឹងទៅទីណា ទៅកាន់ទីណាដែរទេ?

**ឆ៖** បាទ ខ្ញុំអត់បានដឹងទេ។ ប៉ុន្តែខ្ញុំបានដឹងថា យកទៅណា? ខ្ញុំសួរគេដែរ អូ! យកទៅធ្វើការនេះ ធ្វើការនោះ ខាងបង្កបង្កើនផលអីអ៊ីចឹងបាទ។ គេប្រាប់ខ្ញុំអ៊ីចឹងដែរ។ មិនមែនថា មិនប្រាប់ទេ បាទ។

[០៩:៤៦:៤0]

**ស៖** អរគុណ។ តើលោកធ្លាប់បានដឹងថា ឈ្មោះ ជាម ដែលជាអនុប្រធានរបស់លោក ធ្លាប់បានយកមនុស្ស ចាកចេញពីក្រសួងការបរទេសទៅកាន់មន្ទីរស-២១ ដែរទេ?

**ឆ៖** ខ្ញុំបានដឹងថា ជាម យកមនុស្សចេញពីមន្ទីរស-២១ ប៉ុន្តែខ្ញុំមិនដឹងថា ជាម យកទៅណាៗទេ។

**ស៖** លោកចង់និយាយថា ម៉េចទៅ? ជាម យកចេញៗពីមន្ទីរស-២១។ មន្ទីរណាមួយទៅមន្ទីរស-២១ ដែល ជាម យកមនុស្សចេញទៅនោះ?

**ឆ៖** បាទ ពីប-១ បាទ យកពី ប-១ បាទ។ ប៉ុន្តែ មិនដឹងយកទៅណាទេបាទ។

**ស៖** បាទ អរគុណ។ នៅពេលដែលឈ្មោះ ជាម យកមនុស្សពី-- ចេញពីមន្ទីរប-១ ទៅនោះ។ តើមនុស្សនោះជាកម្មាភិបាល ជាបុគ្គលិកមន្ទីរប-១ ឬក៏ជាមនុស្សដែល ប៉ង់ យកមកផ្ញើនៅមន្ទីរប-១?

**ឆ៖** ជាមនុស្សដែល ប៉ង់ យកមកផ្ញើ។

**ស៖** បាទ អរគុណ។ សំណួរសួរថា តើលោក អៀង សារី ដឹងរឿងនោះដែរឬទេ?

**ឆ៖** តាមខ្ញុំសង្កេតមើលដូចជាលោកមិនដឹងទេ។ ទាល់តែបាត់ហើយបានលោកមកសួរ សួរខ្ញុំ "ទៅណាហើយ?"។ ខ្ញុំប្រាប់ថា "គេយកទៅវិញហើយ"។ ខ្ញុំប្រាប់លោកអ៊ីចឹង។

**ស៖** បាទ អរគុណ។

[០៩:៤៩:៣៤]

**ប្រធានអង្គជំនុំ៖**

ហើយមន្ត្រីរដ្ឋបាលតុលាការ បង្ហាញឯកសារអំមិញនេះ ត្រង់សំណួរចម្លើយ៤៧, ៤៩។ ទៅចង្អុលគាត់ ឲ្យគាត់មើលចំណុចនេះ ចំណុចសំណួរចម្លើយ៤៧ ហើយសំណួរចម្លើយ៤៩។

នៅចំពោះមុខអ្នកស៊ើបអង្កេត លោកបានឆ្លើយថា "សួរ៖ មានសាក្សីខ្លះនិយាយថា ឈ្មោះ ជាម ជាអ្នកដឹកយកអ្នកទោសទៅស-២១។ តើលោកយល់យ៉ាងណា? រឿងនេះ បើ ប៉ង់ បញ្ជាមកអ្នកណា អ្នកនោះត្រូវតែធ្វើ។" ហើយសំណួរបន្ទាប់គឺ "តើលោកទទួលស្គាល់ថា មានការដឹកអ្នកទោសទៅដូច្នេះមែនឬទេ? បាទ។"

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** បាទ នេះជាការបញ្ជាក់ឡើងវិញ លើអ្វីដែលលោកបានឆ្លើយអម្បាញ់មិញ។ តើលោកមានអ្វីអត្ថាធិប្បាយលើសំណួរចម្លើយដែលលោកបានឆ្លើយអម្បាញ់មិញនេះដែរទេ? សំណួរចម្លើយ៤៧ ហើយនិងសំណួរចម្លើយលេខ៤៨?

**លោក សាឡុត បាន៖**

**ឆ៖** បាទ អត់មានអីអត្ថាធិប្បាយទេ។

[០៩:៥១:២៥]

**ស៖** ហើយនៅក្នុងនេះគឺសំណួរចម្លើយលេខ៤៩ សំណួរសួរថា "តើលោក អៀង សារី អាចដឹងអំពីរឿងនេះដែរឬទេ? ឆ្លើយ៖ លោក អៀង សារី ត្រូវតែដឹង ប៉ុន្តែគាត់មិនអាចនិយាយបាន។" លោកមានអ្វីអត្ថាធិប្បាយលើសំណួរចម្លើយនេះដែរទេ?

**ឆ៖** បាទ ក្នុងពេលមុនខ្ញុំបានជម្រាបម្ដងហើយ។ ពេលខ្លះលោកអត់ដឹង ប៉ុន្តែភាគច្រើនលោកអត់ដឹងគេយកទៅទេ។ ប៉ុន្តែពេលដែលដឹង ដល់គេបាត់ហើយមកសួរបានលោកដឹងៗ។ ដូច្នេះ ខ្ញុំយល់ឃើញថា បើបាត់មនុស្សហើយ លោកត្រូវដឹងមូលហេតុហើយ។ លោកអាចទៅសួរនាំអ្នកដឹកនាំខាងលើៗទៀតហើយ។ ដូច្នេះ លោកអាចដឹង ក៏ប៉ុន្តែលោកនិយាយមករកខ្ញុំ ដែលខ្ញុំចង់ដឹងដែរហ្នឹងលោកនិយាយមិនបានទេ។ ខ្ញុំចង់មាន-- បាទអ៊ីចឹងបាទ។

**ស៖** អរគុណ ហើយសំណួររបស់ខ្ញុំចុងក្រោយសួរថា សំណួរចុងក្រោយលោកបានឆ្លើយហើយ ហើយសួរបញ្ជាក់បន្ថែមទៀត។ ថាតើលោកបានដឹងទេ ដឹងថាឈ្មោះ ប៉ង់ ដែលមកនាំយកមនុស្សពីក្រសួងការបរទេសទៅ ទាំងបុគ្គលិកមន្ត្រីរាជការ អំ!បុគ្គលិកកម្មាភិបាលក្រសួងការបរទេស ក៏ដូចជាមនុស្សដែលឈ្មោះ ប៉ង់ មកធ្វើ យកមកធ្វើ ហើយគាត់មកខ្លួនឯងមកយកទៅ ឬក៏គាត់ចាត់តាំងមនុស្សឲ្យមកយក ឬក៏គាត់បានបង្គាប់បញ្ជាឈ្មោះ ជាម ដែលជាអនុប្រធានរបស់លោកឲ្យនាំយកមនុស្សនោះចេញទៅ។ តើលោកដឹងថា គេយកមនុស្សហ្នឹងទៅកាន់ទីកន្លែងណាទេ?

**ឆ៖** បញ្ហានេះ គឺខ្ញុំដឹងថា ជាម យកទៅ។ ការពិតខ្ញុំសួរ ជាម ដែរ "យកទៅណា? មនុស្សហ្នឹងអ្នា? តិចមកដល់អញទៀតអ្នា?" នេះសួរជាសាមញ្ញហ្នឹងលោកណា៎ បាទសូមទោសបាទ។ "ទេ គ្នាយកទៅហ្នឹង យកទៅ មានម្នាក់គេមកទទួលយកទៅទៀតហើយ"។ ដូច្នេះ អត់ដឹងទាំងអស់តែគ្នាហ្នឹង មិនដឹងទៅកន្លែងណាទេលោក។

[០៩:៥៤:១២]

**ស៖** បាទអរគុណ។ ហើយចុះលោក អៀង សារី លោកដែលធ្វើការកត់សម្គាល់ ឬក៏បានស្ដាប់គាត់និយាយថា គាត់បានដឹងអំពីការដែលគេយកបុគ្គលិក យកកម្មាភិបាលចាកចេញពីក្រសួង ដែលកាន់កាប់ដោយគាត់ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកជារដ្ឋមន្ត្រីក្រសួងការបរទេសនេះ ហើយត្រូវគេយកមនុស្សចាកចេញពីក្រសួងរបស់គាត់ទៅហ្នឹង ហើយគាត់ថាគាត់អត់ដឹងនែ៎។ បានន័យថា អត់ប្រាប់គាត់មុន ឬក៏គាត់មិនដឹង។ តើគាត់មានអារម្មណ៍ មានការគិតយ៉ាងម៉េចដែរ ថាតើមនុស្សនោះគេយកទៅណាដែរទេ?

[០៩:៥៥:00]

**ឆ៖** ខ្ញុំមិនដឹងអារម្មណ៍ណាទេ ក៏ប៉ុន្តែខ្ញុំមើលទឹកមុខគាត់ស្រពោន។ ដូចតែគ្នា ខ្ញុំក៏ស្រពោន គេនៅជុំវិញ ក៏ស្រពោន។ ដូច្នេះ សភាពការណ៍ក្នុងមន្ទីរក្នុងពេលនោះ គឺស្រពោនទាំងអស់គ្នា បាទ។

**សៈ** ហេតុផលយ៉ាងម៉េចទៅ គ្រាន់តែគេផ្លាស់ទីបុគ្គលិក ផ្លាស់ទីកន្លែងបុគ្គលិកពីមួយ ទៅធ្វើក្រសួង ទៅធ្វើកន្លែងមួយទៀត បែរជាមានការស្រពោន។ ម្សិលមិញ គឺលោកបាននិយាយ ទាំងលោក ទាំងលោក ខៀវ សំផន គឺមានការភ័យព្រួយ ន៎ ភ័យព្រួយ មិនហ៊ាននិយាយ ហើយភ័យព្រួយខ្លួនឯងទៀតផង ទាំងលោក ទាំងគាត់។ ហើយឥឡូវហ្នឹង គឺលោកនិយាយថា ស្រពោន វាមានន័យថា ខុសគ្នារវាងថាការនាំយកមនុស្សយកមនុស្សចេញទៅ ផ្លាស់កន្លែងទៅធ្វើការកន្លែងទៀត ហើយនិងគ្រាន់តែយកមនុស្សចេញទៅ ខ្លួនដែលជាមេកើយ ជាអ្នកគ្រប់គ្រងហ្នឹង មានការភ័យព្រួយ ហើយមានការស្រពោន។ ស្រពោន ក៏មានន័យស្មើប្រហាក់ប្រហែលគ្នា និងភ័យព្រួយ ដែរ មិនអ៊ីចឹងអេ្ហះ! ហេតុផលយ៉ាងម៉េច បាននាំឲ្យលោកភ័យព្រួយ? ហើយក៏ដូចជាលោក អៀង សារី ភ័យព្រួយ?

[០៩:៥៦:២៦]

**ឆៈ** ពីព្រោះ តាមខ្ញុំយល់ ពីព្រោះបញ្ហាបាត់នេះ បាត់ខ្លួន គេយកទៅពីក្រសួងនេះ មិនមែនតែក្រសួង ប-១ តែប៉ុណ្ណោះទេ។ គឺសភាពដូចជាទូទៅហើយ។ ដូច្នេះ ឥទ្ធិពលភ័យព្រួយ វាចេះតែត១គ្នាបាទ។ ឮសួរគេនិយាយអ៊ីចេះ និយាយអ៊ីចុះ បាត់ដែរ១ហ្នឹង ខ្លះថាបាត់ទៅ ងាប់ហើយ គេទៅបាញ់ចោល បាញ់អីអ៊ីចឹងទៅ។ ដូច្នេះ ភ័យព្រួយហ្នឹង វាចេះតែត១គ្នាអ៊ីចឹងមកលោក បាទ។

[០៩:៥៧:១២]

**សៈ** លោកបាន ដែលបានចាប់អារម្មណ៍ ឬក៏ធ្វើកត់សម្គាល់មនុស្សដែលគេនាំចាកចេញពីក្រសួងការបរទេសទៅហ្នឹង ទាំងបុគ្គលិក ទាំងកម្មាភិបាលក្រសួងការបរទេស ទាំងមនុស្សដែល ប៉ង់យកមកធ្វើនៅក្រសួងការបរទេស ហើយគេយកចាកចេញទៅហ្នឹង ដែលមនុស្សណាត្រឡប់វិញទេ? គេបញ្ជូនត្រឡប់មកក្រសួងការបរទេសវិញទេ?

**ឆៈ** បាទ ខ្ញុំពិនិត្យទៅ ដូចជាគ្មានទេបាទ គ្មានត្រឡប់មកវិញទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន ខ្ញុំអស់សំណួរហើយ។ តើអស់លោក លោកស្រីចៅក្រមសំណួរអ្វីត្រូវសួរដល់សាក្សីរូបនេះទេ? សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកសាក្សី! ជម្រាបសួរភាគីទាំងអស់ ដែលមានវត្តមាននៅទីនេះ។

[០៩:៥៨:១៣]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោកសាក្សី ជាដំបូង ខ្ញុំមានសំណួរពាក់ព័ន្ធនឹងអត្រានុកូលដ្ឋានរបស់លោក។ ក្នុងអំឡុងប៉ុន្មានថ្ងៃនៃសវនាការនេះ ខ្ញុំបានស្តាប់ឮ ហើយខ្ញុំចង់បានការបំភ្លឺមួយចំនួនអំពីលោក។

កាលពីថ្ងៃចន្ទព្រឹក លោកបាននិយាយថា លោកមានអាយុ៦៧ឆ្នាំ គឺខ្ញុំគិតថា លោកកើតនៅឆ្នាំ៤៥។ នៅពេលដែលសហចៅក្រមស៊ើបអង្កេតចម្លើយរបស់លោក លោកបានបញ្ជាក់ថា លោកកើតថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៥១។ ហើយឈ្មោះរបស់លោក គឺឈ្មោះ សាឡុត បាន ហៅ ឡុត និត្យា ហៅ សួរ ហុង។ ហើយនៅសវនាការកាលពីថ្ងៃចន្ទ លោកបាននិយាយឆ្លើយតបទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា ហើយលោកបានបញ្ជាក់ថា លោកកើតនៅឆ្នាំ១៩៤៧។

[០៩:៥៩:៣៣]

កាលពីម្សិលមិញ យើងទទួលការជូនដំណឹងអំពីឯកសារពីរ សម្រាប់ដាក់ចូលទៅក្នុងសំណុំរឿង។ គឺទទួលបាននូវអត្តសញ្ញាណប័ណ្ណរបស់លោក សញ្ជាតិខ្មែរ គឺឯកសារលេខ E172/13/1.2។ អត្តសញ្ញាណប័ណ្ណនេះ បានដាក់ឈ្មោះថ្មីមួយទៀត ដែលមានឈ្មោះថា សេង លីតា (S-E-N-G N-I-T-H-A) ហើយកាលបរិច្ឆេទ ថ្ងៃខែឆ្នាំកំណើតនោះ ថ្ងៃទី០៩ ធ្នូ ឆ្នាំ១៩៥១។ ហើយយើងមានឯកសារមួយទៀតដែរ ដែលជាអត្តសញ្ញាណប័ណ្ណយោធារបស់លោក ដែលមានលេខ E172/13/1.3។ អត្តសញ្ញាណប័ណ្ណយោធានេះមានឈ្មោះថា សួរ ហុង។ ហើយថ្ងៃខែឆ្នាំកំណើត គឺដាក់តែឆ្នាំទេ ឆ្នាំ១៩៥១។ តើឈ្មោះពិតរបស់លោកនោះ ឈ្មោះអ្វីទៅ? ហើយថ្ងៃខែឆ្នាំកំណើតពិតប្រាកដរបស់លោកគឺមួយណា? សូមជម្រាបតុលាការ។

[១០:០១:១០]

**ឆ៖** ចំពោះអត្តសញ្ញាណប័ណ្ណមានការច្រឡូលច្របល់ អត្រានុកូលដ្ឋាន សៀវភៅអត្រានុកូលដ្ឋានអី រហូតមកដល់ឥឡូវនេះ អត់ទាន់បានច្បាស់លាស់អីប៉ុន្មានទេ ពីព្រោះរយៈកាលមួយទៅរយៈកាលមួយ វាមានការលំបាកនឹងធ្វើ ពីព្រោះវាបាត់របស់អាដែង របស់ដើមដែលមានទាំងប៉ុន្មានដែលគ្មានបញ្ជីទាំងប៉ុន្មានហ្នឹង វាបាត់អស់ហើយបាទ។ ធ្វើសាថ្មីហ្នឹង គឺថាធ្វើទៅតាម តាមចម្លើយ តាមសំណួររបស់បុគ្គលម្នាក់ៗនៅក្នុងគ្រួសារ ហើយមិនទាន់ឯកភាពគ្នាទេ នេះជាទីមួយ។

[១០:០២:០៥]

ទីពីរទៀត ច្បាស់ពិតប្រាកដប្រវត្តិរបស់ខ្ញុំ គឺខ្ញុំដឹងច្បាស់តែខ្មែរ គឺខ្ញុំកើតនៅឆ្នាំ-- កើតឆ្នាំរកាៗ ខែកត្តិក។ ឆ្នាំរកា ខែកត្តិក។ ហើយខ្ញុំចាំបានម៉ោង នៅម៉ោងប្រាំបួន ថ្ងៃទី០៩ ដូចថាថ្ងៃទី០៩ ម៉ោងប្រាំបួនបាទ ថ្ងៃសៅរ៍។ ហ្នឹង ខ្ញុំចាំច្បាស់ជាងគេ ដោយម្ដាយឪពុកខ្ញុំប្រាប់ អាហ្នឹងច្បាស់។

ដល់ក្រោយមកធ្វើបញ្ជីជាតិធ្វើបញ្ជីអីទៅវា ខ្ញុំវាធំត្រឡោកនោះ វាចូលរៀននោះត្រូវអាយុ៦ឆ្នាំនោះ ក៏បងប្អូនគេចុះបញ្ជីជាតិ ហើយមកក្រោយមកទៀតមក ខ្ញុំមកធ្វើយោធា ខ្ញុំចង់បានប្រាក់ខែក៏ខ្ញុំបញ្ចុះទៅទៀត។ អាហ្នឹខ្ញុំជម្រាបត្រង់។ ដូច្នេះ ឆ្នាំកំណើតរបស់ខ្ញុំ គឺឆ្នាំខ្មែរ ដែលខ្ញុំបាននិយាយអំមិញនេះបាទ។

[១០:០៣:៤៥]

ឯឈ្មោះ ខ្ញុំពីដើមមក គេហៅ បានៗ ទេ។ ប៉ុន្តែជីតាខ្ញុំហ្នឹង សាឡុត ហើយចេះតែផ្សំផ្គុំមកដាក់ សាឡុត បាន អីអ៊ីចឹងទៅ។ ហើយដល់អ៊ំខ្ញុំនោះ ខ្ញុំមកនៅផ្ទះអ៊ំហ្នឹង អ៊ំខ្ញុំហ្នឹងក៏ដាក់ឈ្មោះក្នុងបញ្ជីជាតិហ្នឹង ឡុត និត្យា អត់មាន សា ទេ។ ដល់ក្រោយមកទៀត មកធ្វើប៉ាស្ព័រ ធ្វើសំបុត្រខាងយោធាអីទៅគេសរសេរអក្សរអត់ត្រឹមត្រូវ អីៗតាមដើមកំណើតមក វាចេញជាអ៊ីចឹងទៅលោក។ សូមលោកជ្រាប។

[១០:០៤:៤៤]

**ស៖** ខ្ញុំគិតថា ខ្ញុំទទួលយកនូវការពន្យល់នេះបាន។ ខ្ញុំចង់ត្រឡប់មកកាន់សំណួរមួយចំនួនដែលបានសួររួចមកហើយ ជាពិសេសសំណួរពាក់ព័ន្ធទៅនឹងមនុស្សម្នាក់ ដែលយើងបាននិយាយច្រើនមកហើយ គឺលោក ប៉ង់។ តើលោកអាចជម្រាបបានទេ បើតាមលោកដឹង។ តើ ប៉ង់ ស្ដាប់បញ្ជាអ្នកណា?

**ឆ៖** ខ្ញុំមិនបានដឹងថា ប៉ង់ ស្ដាប់បញ្ជានរណាទេ។

**ស៖** តើ ប៉ង់ ជាអង្គការឬ?

**ឆ៖** ខ្ញុំមិនបានចាត់ទុកថា ប៉ង់ ជាអង្គការទេ។ ពាក្យនៅក្នុងការទាក់ទងគ្នា ខ្ញុំហៅថា "មិត្តប៉ង់"ៗ។

**ស៖** បើតាមឋានានុក្រមនោះ តើអ្នកណានៅពីលើ ប៉ង់?

**ឆ៖** តាមឋានានុក្រមអ្នកពីនៅលើ ប៉ង់ តាមខ្ញុំដឹង គឺពាក្យថា "អង្គការ"។

**ស៖** តើអ្នកណាជាអង្គការ?

**ឆ៖** អង្គការ ខ្ញុំមិនដឹងទេ ខ្ញុំមិនអាចបកស្រាយបានទេ។ ប៉ុន្តែតាមខ្ញុំយល់ផ្ទាល់ខ្លួន ដែលខ្ញុំធ្លាប់ធ្វើការ គឺជាការប្រមូលផ្តុំ ហើយប្រជាធិបតេយ្យ ប្រជាធិបតេយ្យប្រមូលផ្តុំ រួមទទួលខុសត្រូវ បុគ្គល

ទទួលខុសត្រូវដោយឡែក។ រួមទទួលខុសត្រូវរួម បុគ្គលទទួលខុសត្រូវដោយឡែក។ នេះហើយហៅថា "អង្គការ"។

**ស៖** តើ ប៉ុល ពត ជាមេអង្គការឬ?

**ឆ៖** ខ្ញុំអត់ដឹងទេ ប៉ុន្តែខ្ញុំអាចបកស្រាយបាន។ ប៉ុល ពត ជាបុគ្គលនៅក្នុងអង្គការ ជាម្ចុលមួយនៅក្នុងសមុទ្រ។

[១០:០៨:៥២]

**ស៖** តើ នួន ជា នោះក៏ជាម្ចុលនៅក្នុងសមុទ្រមួយដែរ មែនទេ?

**ឆ៖** ខ្ញុំក៏មិនដឹងដែរ លោកដឹងច្បាស់-- លោកចង់ដឹងច្បាស់ នួន ជា នៅទីនេះហើយ លោកសួរចុះ!

**ស៖** ខ្ញុំសួរសំណួរទៅកាន់លោក លោកសាក្សី។ ដូច្នេះខ្ញុំបន្តទៀត។ តើលោក អៀង សារី ជាអង្គការដែរឬទេ?

**ឆ៖** បាទ។ ការពិត ដឹងការពិតទាល់តែសួរលោក។ ប៉ុន្តែបើខ្ញុំប្រើពាក្យថា "អង្គការ" ខ្ញុំគ្រាន់តែពន្យល់ថា "អង្គការ" គឺជាប្រជាធិបតេយ្យប្រមូលផ្តុំ ប្រមូលផ្តុំបុគ្គល ប្រមូលផ្តុំជារួម បុគ្គលទទួលខុសត្រូវដោយឡែកតែប៉ុណ្ណោះ។

[១០:១០:២៣]

**ស៖** ឥឡូវនេះត្រឡប់មកនិយាយអំពី ប៉ង់ វិញ តើលោកបាន-- តើលោករក្សាចម្លើយទេដែលថា ប៉ង់ គាត់មានការទទួលខុសត្រូវក្នុងការជ្រើសរើសបុគ្គលិករបស់ក្រសួងការបរទេស?

**ឆ៖** ខ្ញុំបានជម្រាប បុគ្គលិកក្រសួងការបរទេសគឺ ប៉ង់ អ្នកបញ្ជូនមក។ ចង់និយាយថា មានក្រុមរបស់ ប៉ង់ មួយក្រុមអាចធ្វើប្រវត្តិរូបអីច្បាស់លាស់ហើយ ឃើញថាបុគ្គលនោះត្រឹមត្រូវហើយអាចមកក្រសួងការបរទេសបាន បានគេបញ្ជូនមកក្រសួងការបរទេស។ ដូច្នេះ ខ្ញុំយល់ឃើញថា ប៉ង់ ជាបុគ្គលមួយទទួលខុសត្រូវដែរ ទទួលខុសត្រូវក្នុងការយកមនុស្សមកដាក់នៅក្នុងក្រសួងនេះ។

[១០:១១:៥១]

**ស៖** លោកសាក្សី តើលោកខ្លួនឯងផ្ទាល់នេះត្រូវបាន ប៉ង់ ជាអ្នកជ្រើសរើសយកទៅធ្វើការនៅក្រសួងការបរទេសមែនដែរឬទេ?

**ឆ៖** បាទ លោក ប៉ង់ មកធ្វើប្រវត្តិរូបខ្ញុំ ឲ្យខ្ញុំមកក្រសួងការបរទេស។

**ស៖** តើលោកនៅតែរក្សាចម្លើយថា-- ដដែលថា វាជាការសំខាន់ណាស់ដែលត្រូវតែមានប្រវត្តិរូបស្អាតស្អំនោះ?

**ឆ៖** បាទ ប្រវត្តិរូបស្អាតស្អំ សំខាន់បាទ។

**ស៖** តើលោកខ្លួនឯងផ្ទាល់នេះ លោកជាអ្នកសរសេរប្រវត្តិរូបរបស់លោកផ្ទាល់ឬ?

**ឆ៖** បាទ ប្រវត្តិរូបស្អាតស្អំនេះ មួយ គឺគេមើលឲ្យសរសេរ។ ទីពីរ គេតាមដានការងារដែលខ្ញុំធ្វើពីដើមមក ដែលគេធ្លាប់បានឃើញ។ ទីបី មានមហាជនគេថា ឱ! សមល្មមហើយឲ្យគាត់ទៅ ធ្វើទទួលខុសត្រូវអីទៅ។ នេះគេហៅថា សួរពីប្រជាធិបតេយ្យសិនដែរ ឲ្យបុគ្គលហ្នឹងធ្វើបាន ឬមិនបាន។ នេះជាប្រវត្តិរូប។

[១០:១៣:៥៥]

**ស៖** ឥឡូវនេះ ខ្ញុំចង់និយាយអំពីចំណុចមួយទៀតពាក់ព័ន្ធនឹងអ្វីដែលលោកបានឆ្លើយ ពាក់ព័ន្ធទៅនឹងការ-- លោកកាលពីនៅក្មេង។ ហើយលោកបានលើកឡើងថា នៅក្នុងឆ្នាំ១៩៦៦ លោកត្រូវបានចាប់ខ្លួន ហើយត្រូវបានឃុំខ្លួនរយៈពេល១០ថ្ងៃ ក្រោយមកត្រូវបានសម្តេចឪជាអ្នកដោះលែងលោក។ គឺសម្តេច នរោត្តម សីហនុ តើលោករក្សាចម្លើយនេះដដែលឬ?

**ឆ៖** បាទ ខ្ញុំរក្សាចម្លើយនេះដដែល។

**ស៖** តើការដោះលែងនេះ គឺដោយសារតែមានទំនាក់ទំនងជាពិសេសរវាងគ្រួសាររបស់លោក និងព្រះបរមរាជវាំងមែនទេ?

[១០:១៥:០០]

**ឆ៖** ខ្ញុំមិនដឹងខ្លួនខ្ញុំមានខ្សែទាក់ទងអ្វីនឹងក្នុងព្រះបរមរាជវាំងទេ។ ប៉ុន្តែខ្ញុំដឹងថា គ្រាន់តែដឹងថាម្តាយធំខ្ញុំធ្វើការនៅវាំង ឪពុកធំខ្ញុំធ្វើការក្នុងវាំងជាគ្រូរបាំ ហើយនិងនៅសារមន្ទីរ រក្សាសារមន្ទីរបាទ។ ចំពោះខ្ញុំ ខ្ញុំក្នុងការដោះលែងនេះ គឺជាការដោះលែងរួម មិនមែនជាការដោះលែងបុគ្គលខ្ញុំតែម្នាក់ទេ។ ខ្ញុំយល់ថា សិស្សជំនាន់នុំងជាប់គុកងងឹត ខ្ញុំនេះជាប់គុកងងឹត។ សិស្សជំនាន់នោះ បញ្ញាជនជំនាន់នោះដែលជាប់គុកលោកបានឲ្យដោះទាំងអស់។ មិនមែនជាប់ខ្សែទាក់ទងនឹងព្រះរាជវាំងទេបាទ។

**ស៖** អ៊ំរបស់លោកនុ៎ងតើឈ្មោះ សួង មែនទេ? ឬក៏មីងរបស់ឪពុកលោកហ្នឹងឈ្មោះ នាក់? តើលោកស្គាល់ រឿង ទេ? តើអ្នកទាំងអស់នេះមានទំនាក់ទំនងអ្វីទេជាមួយនឹងព្រះរាជវាំង?

[១០:១៦:៤២]

**ធ៖** អ៊ំរបស់ខ្ញុំឈ្មោះ សាឡុត ស្លូង មែន។ ឯម្ដាយមីងរបស់ខ្ញុំឈ្មោះ រឿង មែន។ ទាំងអស់គ្នានេះ មិនមានការអីទាក់ទងនៅក្នុងវាំងទេ។ តួនាទីនៅក្នុងវាំង គឺមានតែអ៊ំ ស្លូង និងប្រពន្ធរបស់គាត់តែប៉ុណ្ណោះ ជាតួនាទីទេ។

**ស៖** នៅក្នុងឯកសារ E/91 ឬក៏លេខ D91/14 ទំព័រ៣ ជាភាសាបារាំង ERN ជាភាសាបារាំង 00503932, ERN ជាភាសាអង់គ្លេស 00223590 រហូតទៅដល់ 91, ERN ជាភាសាខ្មែរ 00204093 រហូតទៅដល់ 98។ លោកបានបញ្ជាក់ថា៖ បន្ទាប់ពីការដោះលែង លោកបានផ្លាស់ប្ដូរឈ្មោះ ហើយលោកដាក់ឈ្មោះថា បៀន ឬក៏ ផាត ហើយលោករស់នៅទីនោះបានសំអាងដោយមានអត្តសញ្ញាណប័ណ្ណសង្គមរាស្ត្រនិយម។ តើលោកនៅរក្សាចម្លើយនេះដដែលទេ?

[១០:១៨:៤៣]

**ធ៖** បាទ ខ្ញុំរក្សាចម្លើយនេះ ពីព្រោះកាលណោះទាំងអស់គ្នាដែលជាសមាជិកសង្គមរាស្ត្រនិយមត្រូវធ្វើកាតមួយ។ ដូច្នេះ ដើម្បីខ្ញុំលាក់បាំងកុំឱ្យគិញរបស់លោក លន់ នល់ ចាប់ខ្ញុំបានទៀត ខ្ញុំគ្មានកាតអីទេ។ ខ្ញុំសុំ អង្កាល់នុ៎ងសុំ សុំអ្នកស្គាល់ដែលខ្ញុំភ្លេចឈ្មោះហើយឱ្យធ្វើកាតហ្នឹងឱ្យខ្ញុំមួយ ដើម្បីខ្ញុំទៅណាៗហ្នឹងមានកាតហ្នឹងជាសំអាងខ្លះ។

**ស៖** សូមអរគុណ។ ឥឡូវពាក់ព័ន្ធទៅនឹង ក-១ ប្អូនរបស់លោកឈ្មោះ សេង លីថេង ហើយនិងប្រពន្ធរបស់លោឈ្មោះ ជូ ឆេង។ តើលោកមានសមាជិករបស់លោក ឬក៏សាច់ថ្លៃរបស់លោកនោះធ្លាប់ធ្វើការនៅមន្ទីរក-១ ទេ ឬក៏មានកាន់មុខតំណែងអី នៅជិតស្និទ្ធនឹងមេដឹកនាំកម្ពុជាប្រជាធិប- តេយ្យដែរឬទេ?

**ធ៖** តំណែងគ្រួសារខ្ញុំឈ្មោះ ជូ ឆេង គាត់ដាំបាយនៅក-១ បានមួយរយៈខ្លី។ ក្រោយមកក៏មកនៅជាប់នឹងខ្ញុំ មួយរយៈខ្លីហ្នឹងប្រហែលជាមិនបានមួយខែផងទេ។ ប៉ុន្តែបើនៅព្រៃគាត់ដាំរហូត ដាំបាយរហូត ដល់ចូលក្រុងមកគាត់ដាំបានតែមួយខែទេ បាទ។ ឯប្អូនខ្ញុំឈ្មោះ លី ឆេង ខ្ញុំដឹងតែភារកិច្ចវា គឺថតៗរូប។

[១០:២១:៣២]

**ស៖** ឥឡូវនេះត្រឡប់មក ចម្លើយរបស់លោកកាលពីថ្ងៃទី២៤ ខែមេសា ជាពិសេសពាក់ព័ន្ធទៅនឹងមន្ទីរច្រាំងចំរេះ។ បើតាមលោកតើមានទំនាក់ទំនងគ្នាទេ រវាងការចាប់ខ្លួន កុយ ធួន និងការបោសសម្អាតក្រោយពីការចាប់ខ្លួន កុយ ធួន ហើយនិងការផ្ទេរមន្ទីរច្រាំងចំរេះ ឱ្យទៅស្ថិតនៅក្រោមឱវាទ

របស់ក្រសួងការបរទេសនោះ?

**ធ៖** សភាពការណ៍ កុយ ធួន ខ្ញុំអត់ដឹងទាល់តែសោះ ឯផ្ទេរច្រាំងចំរេះមកឲ្យការបរទេសនោះ ខ្ញុំដឹង។

**ស៖** តើច្រាំងចំរេះមានឈ្មោះជាកូដទេ?

**ធ៖** ខ្ញុំភ្លេចហើយ។ ហៅតែច្រាំងចំរេះៗអ៊ីចឹងរហូតបាទ។

**ស៖** តើមន្ទីរម-១ ឬក៏មន្ទីរប-៦០ នេះលោកមានធ្លាប់ឮទេ?

**ធ៖** បាទ ខ្ញុំអត់ធ្លាប់ឮទេ។

[១០:២៣:៤០]

**ស៖** កាលពីសវនាការថ្ងៃទី២៤ ខែមេសា លោកបានឆ្លើយថា លោកដឹងថា ចម្លើយសារភាពនៅមន្ទីរស-២១ ត្រូវបានបញ្ជូនទៅក្រសួងការបរទេស ជាអាទិ លោកបានឆ្លើយថា លោកបាននៅចំពោះសហចៅក្រមស៊ើបអង្កេតថា បើតាមលោកដឹងឯកសារនេះ មានការប្រឌិតច្រើន។ ហើយលោកបាន-- ខ្ញុំយោងទៅលើសេចក្តីឆ្លើយរបស់លោកនៅក្នុងឯកសារលេខ D233/2 ទំព័រ៦ ជាភាសាបារាំង ទំព័រ៧ ជាភាសាអង់គ្លេស ERN ជាភាសាខ្មែរ 00357530។ នៅក្នុងសវនាការនៅថ្ងៃ២៤ មេសា ដដែលនោះ លោកបានឆ្លើយថា ចម្លើយសារភាពរបស់ កុយ ធួន ត្រូវបាន លោក អៀង សារី អានឲ្យស្តាប់នៅក្នុងក្របខ័ណ្ឌនៃកិច្ចប្រជុំរបស់កម្មាភិបាលថ្នាក់កណ្តាល ហើយទាំងអស់គ្នារួមទាំង អៀង សារី ផងដែរ មានការភ័យខ្លាច។ ខ្ញុំចង់ដឹងថា តើហេតុអ្វីក៏ អៀង សារី នូវចម្លើយសារភាពរបស់ កុយ ធួន នេះ?

[១០:២៥:១៥]

**ធ៖** មានចម្លើយ ឯកសារជាសៀវភៅ តាមខ្ញុំដឹង បែបសៀវភៅក្រាស់ដែរ បែបប្រហែលកម្រាស់មេដៃនេះ។ សភាពការណ៍ពេលនោះ វៀតណាមកាន់តែសង្គ្រុញមកហើយ។ ទាំងអស់គ្នាច្របល់ទាំងនៅក្នុងមន្ទីរ ទាំងនៅក្នុងក្រុងទាំងមូល អានសភាពការណ៍នេះ។ ហើយសៀវភៅហ្នឹងមិនដឹង មកពីអង្កាល់ណាទេ ប៉ុន្តែពេលនុ៎ង បានដឹងឃើញ បានឃើញ បានគេយកមកអាន នៅពេលដែលយួនជិតចូលស្រុកហើយទេ។ បាទ ខ្ញុំជម្រាបជាសភាពការណ៍ដើម្បីឲ្យវាទាក់ទងគ្នា យល់។ ដល់យកមកអានឃើញថាវា ផ្ទាល់ខ្លួនខ្ញុំទេ ឃើញថាវាមិនសូវសមហេតុសមផលដែរ មិនត្រឹមត្រូវ។ បន្ទាប់ពីការអានហើយ អានរួចហើយ មួយថ្ងៃក្រោយមក ឬពីរថ្ងៃក្រោយមក បានចេញជាសារាចរ។ សារាចរនោះគឺសារាចរ ដូចខ្ញុំបានជម្រាបអ៊ីចឹង គឺថាឲ្យមានការចាប់មនុស្ស ការសម្លាប់មនុស្ស ឲ្យមានប្រាំពីរថ្នាក់។

ន៎ះ តាមសភាពការណ៍អ៊ីចឹង បានអារម្មណ៍ខ្ញុំវាមានការព្រួយបារម្ភយ៉ាងដូច្នេះបាទ។ សូមលោកជ្រាប បាទ។

[១០:២៧:១៣]

**ស៖** ខ្ញុំសោកស្ដាយណាស់ លោកមិនបានឆ្លើយទៅនឹងសំណួររបស់ខ្ញុំទេ។ ហេតុអីបានជា អៀង សារី អាននូវចម្លើយសារភាពនេះ? បើតាមលោកថានោះ គឺថាវៀតណាមបានមកជិត ចូលមក ដល់កម្ពុជាហើយ ជាមូលហេតុមួយ ក៏ប៉ុន្តែមានមូលហេតុមួយផ្សេងទៀត សូមលោកបញ្ជាក់?

**ឆ៖** ពេលនោះ តាមខ្ញុំចាំ លោកមិនអានផ្ទាល់ទេ លោកឲ្យ ដូចជានារី សួរ សៃ អីមិនដឹងអាន បាទ។ លោកកាន់យកមក ប៉ុន្តែលោកឲ្យនារី សួរ សៃ អាន បាទ។

**ស៖** លោកសាក្សី តើលោកអាចប្រាប់បានទេ ថាលោក អៀង សារី មិនមានបានពន្យល់ទេ នៅពេលដែលអានចម្លើយសារភាពនោះ? ខ្ញុំគិតថា មិនមែនជារឿងធម្មតា មិនមែនជារឿងប្រក្រតីអីទេ ដែលអានចម្លើយសារភាពរបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យនោះ។ តើមានការពន្យល់ទេ អំពីការ អាននុ៎ង គាត់មានផ្ដល់មូលហេតុទេ ថាហេតុអីបានជាគាត់អាននូវចម្លើយសារភាពនេះ?

[១០:២៨:៤៣]

**ឆ៖** បាទ លោកសួរបន្តដូច្នេះ ខ្ញុំនឹងឆ្លើយទៅទៀត។ ការអានហើយ ឲ្យទាំងអស់គ្នាចាប់ អារម្មណ៍។ តើទាំងអស់នេះ ទាំងខ្ញុំ ទាំងសមាជិកទាំងអស់ តើមានអីពាក់ព័ន្ធជាមួយ ផ្នែកផ្លូវអាក្រក់នេះ ជាមួយនឹងលោក កុយ ធួន ឬទេ? នេះ ជាខ្លឹមសារអានហើយ ឲ្យចាប់អារម្មណ៍ទាំងអស់គ្នា។

**ស៖** ដូច្នេះ គឺថា អៀង សារី បានសុំឲ្យអ្នកចូលរួមនៅក្នុងកិច្ចប្រជុំនោះ ឲ្យនិយាយអំពីទំនាក់ ទំនង ឬក៏ជាប់ខ្សែជាមួយ កុយ ធួន។ ហើយបន្ទាប់ពីកិច្ចប្រជុំនេះទៅ ប៉ុន្មាន-- មួយរយៈក្រោយមក គឺមានការចាប់ខ្លួនមនុស្ស។ តើលោកមានមើលឃើញទេ រវាងទំនាក់ទំនងនៃការអាន ហើយនិងការ ចាប់ខ្លួននោះ?

[១០:៣០:១៤]

**ឆ៖** ឯកសារដែលយកមកអាននេះ ក្នុងសភាពការណ៍ដូចខ្ញុំបានជម្រាប ពេលយួនជិតចូលមក ភ្នំពេញហើយ។ ឯកសារអស់ទាំងនេះ គ្រាន់តែយកមកបញ្ចាំងឲ្យឃើញថា តើមានអ្នកណាពាក់ព័ន្ធរឿង ហ្នឹងទេ។ បើមានពាក់ព័ន្ធ យើងលើកឡើងទៅ មិនមានជាបញ្ហាអីទេ។ ប៉ុន្តែពេលនោះ តាមខ្ញុំចាំ គ្មានអ្នកណាមួយពាក់ព័ន្ធ រឿងផ្លូវខូច ផ្លូវខិល រឿងសីលធម៌ ឬរឿងអីដែលទាក់ទងនឹងយោធាទេក្នុង

ក្រសួង។ ដូច្នេះក្នុងក្រសួង គ្មានអីពាក់ព័ន្ធទៅនឹងរឿងសៀវភៅហ្នឹងទេ។

[១០:៣១:២០]

ក្រោយមក ពីរបីថ្ងៃក្រោយមក ដូច្នេះមិនមានការអីយកមនុស្សចេញទៅទៀតទេ ពេលនុំងអស់ហើយ ចប់ហើយ ចប់យកមនុស្សចេញហើយ។ ពេលនោះ មានតែអនុវត្តច្បាប់ មានតែអនុវត្តច្បាប់ប្រាំពីរជាន់ទេ បានយកមនុស្សចេញ។ បាទ សូមជ្រាប។

**សៈ** នៅក្នុងអំឡុងសវនាការថ្ងៃទី២៤ មេសា គេបានសួរលោកថា តើលោកនោះ លោកធ្លាប់ធ្វើជាប្រធានអង្គប្រជុំនៅច្រាំងចំរេះដែរឬទេ? ហើយនៅពេលនោះ គឺថាមានលើកអំពីការចាប់ខ្លួន កុយ ធួន ហើយគាត់បានត្រូវបានគេឆ្លើយដាក់ថា "ជាខ្មាំង" "ជាជនក្បត់"។ ខ្ញុំបានអាននូវប្រតិចារឹកនេះឡើងវិញ ហើយខ្ញុំបានឃើញថា លោកមិនបានឆ្លើយនឹងសំណួរនេះទេ ក៏ប៉ុន្តែលោកបានបញ្ជាក់ថា លោកត្រូវធ្វើការខាងបញ្ហាសតិអារម្មណ៍ដើម្បីឲ្យមានភាពនឹងនរ។

[១០:៣២:៣៦]

ក្រោយមកទៀត លោកក៏បាននិយាយថា មនុស្សជាច្រើននៅច្រាំងចំរេះមកពីភូមិភាគ៣០៤ ប៉ុន្តែអ្នកដែលមកពីភូមិភាគរបស់ កុយ ធួន នោះគឺសុទ្ធតែជាកូនរបស់កសិករ ឬក៏ជាកសិករ ហើយមិនមានឥទ្ធិពលអ្វីទៅលើបញ្ហាយោធា ឬក៏បញ្ហាអាវុធទេ។ ហើយដូច្នេះ មិនចាំបាច់ធ្វើការស៊ើបអង្កេតអីទៅលើពួកអស់នេះទេ។

ខ្ញុំសួរសំណួរម្តងទៀត។ តើលោកមានបានចូលរួមនៅក្នុងកិច្ចប្រជុំនៅច្រាំងចំរេះ ដែលមានលើកឡើងអំពីការចាប់ខ្លួន កុយ ធួន ហើយនិងលើកឡើងថា កុយ ធួន ត្រូវបានគេឆ្លើយដាក់ថា ជាជនក្បត់ដែរឬទេ?

[១០:៣៣:៣៥]

**ឆៈ** ក្នុងឋានៈខ្ញុំដឹកនាំ ជួយខាងច្រាំងចំរេះ ខ្ញុំបានទៅធ្វើការនៅច្រាំងចំរេះ ប៉ុន្តែការទៅធ្វើការនេះ ខ្ញុំអត់បានទាន់ឃើញឯកសាររបស់ កុយ ធួន ទេ។ ទីមួយ អត់បានឃើញទេឯកសារហ្នឹង។ ប៉ុន្តែខ្ញុំឮសួរបងប្អូនគេនិយាយមកអ៊ីចេះអ៊ីចុះ ថាបង កុយ ធួន គេចាប់ហើយ គេចាប់ចោទថាក្បត់ថាអី។ ក្នុងឋានៈដឹកនាំ ខ្ញុំត្រូវតែសម្រប ខ្ញុំត្រូវតែធ្វើយ៉ាងម៉េចឲ្យបងប្អូនស្ងប់ស្ងាត់។ ដូច្នេះ ខ្ញុំនិយាយនេះត្រង់ គឺខ្ញុំទទួលខុសត្រូវកន្លែងនុំង! ខ្ញុំត្រូវតែមានអីអារម្មណ៍បងប្អូនដែលមិនស្ងប់ ខ្ញុំត្រូវតែពន្យល់។ ដូច្នេះ ខ្ញុំអាចនិយាយរឿងហ្នឹង បាទ។ ខ្ញុំមិនចងចាំអស់ទេ។ ប៉ុន្តែខ្ញុំសរុបមកវិញ ខ្ញុំអាចនិយាយរឿងហ្នឹង។

[១០:៣៤:៥៨]

**ស៖** លោកសាក្សី បើតាមលោក គឺមានតែកូនកសិករនេះនៅច្រាំងចំរេះ ឬក៏មានអ្នកណាផ្សេងទៀត? ខ្ញុំចង់អានឲ្យលោកស្តាប់នូវចម្លើយរបស់លោក កាំង ហ្កេកអ៊ាវ ហៅ ឌុច គឺឯកសារលេខ E3/15 ហើយកាលពីមុននោះ គឺសូមទោស! គឺក្នុងចម្លើយទី៨ គាត់បានឆ្លើយថា "កន្លែងខ្លះដូចជាច្រាំងចំរេះ បឹងត្របែក ជាមជ្ឈមណ្ឌលប្រមូលផ្តុំបញ្ញាជន ដែលមួយចំនួនជាសមាជិករណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។ គេចាត់ទុកពួកអស់នេះជា-- ថា មិនច្បាស់លាស់ខាងនយោបាយ អាចជាមិត្ត ឬអាចជាសត្រូវ"។ តើលោកមានធ្លាប់ឃើញសមាជិករណសិរ្សរួបរួមជាតិ និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជានៅច្រាំងចំរេះដែរឬទេ?

[១០:៣៦:០៣]

**ឆ៖** ខ្ញុំបានជម្រាបរួចហើយ។ ច្រាំងចំរេះដែល៣០៤ កាន់កាប់ និងច្រាំងចំរេះដែលខ្ញុំទៅទទួលខុសត្រូវនៅទីនោះ។ ខ្ញុំទទួលខុសត្រូវនៅទីនោះ ខ្ញុំមិនបានឃើញបញ្ញាជន ឥស្សរជននៅទីនោះទេ។ ឯរឿងដែល កុយ ធួន កាន់កាប់ខ្ញុំអត់ដឹងរឿងហ្នឹងទេ។

**ស៖** តើ ប៉ង់ មានធ្វើការចាប់ខ្លួនអ្នកដែលនៅច្រាំងចំរេះដែរឬទេ?

**ឆ៖** ចំពោះខ្ញុំ ខ្ញុំអត់បានដឹងទេ។

**ស៖** ខ្ញុំនឹងអាននូវសម្រង់មួយដែលឆ្លើយដោយសាក្សីមួយដែលមាននៅក្នុងសំណុំរឿងហើយ គឺឯកសារលេខ D369/18 នេះគឺជាចម្លើយរបស់សាក្សី តូច វណ្ណារិទ្ធ។ ERN ជាភាសាបារាំង 00702953, ERN ជាភាសាអង់គ្លេស 00498631, ERN ជាភាសាខ្មែរ 00488076 រហូតទៅដល់ 00488094។ ក្នុងឯកសារនោះ មានសរសេរថា-- សូមបញ្ជាក់សិនថា តូច វណ្ណារិទ្ធ គឺថា បញ្ជាក់ថា "គាត់ត្រូវបានឃុំនៅច្រាំងចំរេះ គឺចាប់ពីពេលប្រកាសថា កុយ ធួន ត្រូវបានចាប់ខ្លួន ព្រោះជាមន្ទីររបស់ កុយ ធួន និងជាពួកមកពីភូមិភាគឧត្តរ ហើយកម្មាភិបាលដែលធ្វើការជាមួយ កុយ ធួន ត្រូវបានដកជាបន្តបន្ទាប់។ ហើយអ្នកដែលមាននិន្នាការ កុយ ធួន ក៏ត្រូវបានបញ្ជូនទៅម-១ ដែរ"។ ចំពោះ តូច វណ្ណារិទ្ធ នោះម-១ នេះគឺច្រាំងចំរេះនេះឯង។ ដូច្នេះអ្នកដែលមាននិន្នាការ កុយ ធួន ក៏ត្រូវបញ្ជូនទៅមន្ទីរម-១។ មានមេមាយមកពីភ្នំពេញជាច្រើនដែលប្តីត្រូវបានគេចាប់ខ្លួន ហើយក៏មានយុទ្ធជនមកពីប-១ ក៏ត្រូវបានប្តូរមកមន្ទីរម-១ ដែរ។ ដូច្នេះ ប-១ គឺមន្ទីរក្រសួងការបរទេស"។

តើលោកមានមតិអ្វីទេ ចំពោះសម្រង់ដែលខ្ញុំបានអានអម្បាញ់មិញនេះ។

[១០:៣៩:៣៤]

**ឆ៖** ចំពោះការចោទប្រកាន់នេះ គឺខ្ញុំសូមបំភ្លឺដើម្បីឲ្យមានការពិតដូចតទៅ៖ ចំពោះច្រាំងចំរេះក្នុងក្របខ័ណ្ឌដែលផ្ទេរមកក្រសួងការបរទេស តាមខ្ញុំដឹងណ៎ះ! ហ្នឹងខ្ញុំដឹងក្រោយមកទេ ប៉ង់ កាន់កាប់មួយរយៈ មិនទាន់មកឲ្យខ្ញុំផ្ទាល់ទេ។ ប៉ង់ កាន់កាប់មួយរយៈយូរ បញ្ហានេះ រឿងចាប់រឿងចងអីខ្ញុំអត់ដឹងទេ។ ដល់មកពេលដែល ប៉ង់ ប្រគល់ឲ្យមកក្រសួងការបរទេស ក្រោមការគ្រប់គ្រងរបស់ខ្ញុំ គឺអត់មានបញ្ហាចាប់ចងទេបាទ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណច្រើន។ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល និងផ្តល់កន្លែងសម្រាកសម្រាប់សាក្សីនៅក្នុងសម្រាប់សម្រាប់សាក្សី ជាមួយនឹងមេធាវីប្រឹក្សារបស់គាត់ ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មវិញនៅវេលាម៉ោងដប់មួយ។

សូមអញ្ជើញលោកមេធាវី!

[១០:៤១:២៥]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម អស់លោក លោកស្រី។ នៅថ្ងៃទី២៤ ខែកុម្ភៈ ថ្ងៃទី២៦ និងថ្ងៃទី៣០ អង្គជំនុំជម្រះបានចេញនូវអនុស្សរណៈ ដែលលើកឡើងថាដើមបណ្តឹងរដ្ឋប្បវេណីមិនអាចយោងទៅលើចម្លើយរបស់សាក្សីផ្សេង នៅពេលដែលដេញដោលសាក្សីនៅទីនេះនោះទេ។ ខ្ញុំលើកឡើងត្រង់ឯកសារចុះថ្ងៃទី២៤ ខែកុម្ភៈ និងឯកសារថ្ងៃទី២៦ ខែកុម្ភៈ ចាប់ផ្តើមដល់ទំព័រ១០៨។ បាទសូមកែតម្រូវខែមករា នៅថ្ងៃទីខែមករា ថ្ងៃទី៣០ ត្រង់ទំព័រទី៥៦ ដែលនៅក្នុងចៅក្រម ឡាវ៉ែន៍ តាមអ្វីដែលខ្ញុំយល់ គឺគាត់លើកឡើងអំពីចម្លើយរបស់សាក្សីនៅក្នុងឯកសារផ្សេង។

ដូច្នេះចៅក្រមលើកឡើងថា សេចក្តីសម្រេចនោះអនុវត្តចំពោះភាគី។ អង្គជំនុំជម្រះមានសិទ្ធិយកចម្លើយរបស់សាក្សីផ្សេងមកដេញដោល ក៏ប៉ុន្តែភាគីមិនអាចធ្វើដូច្នេះនោះទេ។ ដូច្នេះហើយនៅក្នុងពេលឈប់សម្រាកនេះ អង្គជំនុំជម្រះអាចធ្វើការពិចារណាទៅលើជំហរនេះបាន។

[១០:៤២:៤៥]

ខ្ញុំសូមបញ្ជាក់ថា នៅព្រឹកនេះខ្ញុំត្រូវការកែប្រែការរៀបចំរបស់យើងខ្ញុំ ដោយសារតែយើងខ្ញុំបានយកចម្លើយរបស់សាក្សីផ្សេងមកដេញដោល។ ដូច្នេះ យើងខ្ញុំកែប្រែជំហររបស់យើងខ្ញុំ។ យើងដឹងអំពីសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ។ ដូច្នេះ យើងទាំងអស់គ្នាត្រូវតែគោរពតាមសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ ទើបខ្ញុំកែប្រែនូវវិធីសាស្ត្រតាំងសំណួររបស់ខ្ញុំ។ នេះជាសេចក្ដីសម្រេចយ៉ាងច្បាស់លាស់។ អង្គជំនុំជម្រះមានសិទ្ធិធ្វើដូច្នោះបាន ក៏ប៉ុន្តែភាគីមិនអាចមានសិទ្ធិដូច្នោះនោះទេ។ ដូច្នេះហើយយើងដឹងសេចក្ដីសម្រេចទាំងអស់គ្នាហើយ យើងត្រូវតែយល់ឲ្យបានច្បាស់ទាំងអស់គ្នា។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវី!

[១០:៤៣:៣២]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ជម្រាបសួរ ខ្ញុំសូមគាំទ្រទៅលើជំហររបស់មេធាវីការពារក្ដី។ ខ្ញុំគិតថាយុត្តិសាស្ត្រមានការផ្លាស់ប្ដូរ ហើយខ្ញុំសូម ខ្ញុំមានសេចក្ដីរីករាយណាស់ ហើយដើមបណ្ដឹងរដ្ឋប្បវេណីក៏មានសេចក្ដីរីករាយដែរ គឺថាយើងគួរតែអាចលើកយកមកនូវចម្លើយរបស់សាក្សីផ្សេងទៀតយកមកដេញដោលបាន។ បញ្ហាដែលចោទឡើងនៅពេលនេះ ថាតើអង្គជំនុំជម្រះកែប្រែនូវសេចក្ដីសម្រេចរបស់ខ្លួនឬទេ? ព្រោះបើតាមចៅក្រម ឡាវែន៍ សម្រេចពេលនោះគឺថាមានការយកចម្លើយរបស់សាក្សីផ្សេងមកដេញដោល។ ដូច្នេះ សូមឲ្យអង្គជំនុំជម្រះមេត្តាពិចារណាពីចំណុចនេះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្ដីលោក នួន ជា!

[១០:៤៤:៣៣]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណច្រើនលោកប្រធាន។ ខ្ញុំគិតថានេះជាលើកដំបូងហើយ ដែលក្រុមមេធាវីការពារក្ដីនិងសហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីឯកភាពទៅលើចំណុចនេះ។ យើងតាមអ្វីដែលយើងខ្ញុំដឹងនោះគឺថា អង្គជំនុំជម្រះបានធ្វើសេចក្ដីសម្រេចនេះរួចមកហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះ កត់សម្គាល់លើបញ្ហាអ្វីដែលភាគីបានលើកឡើងអម្បាញ់មិញនេះ។ សូមអញ្ជើញ! បាទ អង្គជំនុំជម្រះសូមពន្យារពេលនៃការសម្រាក រហូតដល់ម៉ោងដប់មួយដប់នាទីដែរ។ សូមអញ្ជើញ!

[១០:៤៥:២៣]

**លោក អាង ឧត្តម៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនពាក់ព័ន្ធរឿងបញ្ហាដែលបានលើកអំមិញទេ តែខ្ញុំស្នើសុំលោក អៀង សារី ស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ សម្រាប់រយៈពេលនៅសេសសល់ទាំងអស់ថ្ងៃនេះពេញតែម្តង ដោយសារបញ្ហាមូលហេតុសុខភាព ព្រោះគាត់មិនអាចអង្គុយនៅទីនេះបាន។ អាស្រ័យហេតុនេះ សូមលោកប្រធានមេត្តាពិចារណាសម្រេចឲ្យលោកចូលរួមសវនាការដោយប្រយោលពីបន្ទប់រង់ចាំនៅខាងក្រោម។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ តាម-- បានស្តាប់សំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមបន្ទប់សវនាការនេះ តាមរយៈប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលកិច្ចដំណើរការសវនាការ បន្តសម្រាប់ថ្ងៃនេះ។

[១០:៤៦:២៤]

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង សារី ផ្តល់មកអង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ ដោយចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ អៀង សារី។ បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះអាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការនេះដែលបានរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍ សម្រាប់ជនជាប់ចោទរូបនេះអាចចូលរួម និងតាម

ដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៤៨ នាទី ដល់ម៉ោង១១:១២ នាទី)*

[១១:១២:០៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ។ ហើយទន្ទឹមនេះដែរ អង្គជំនុំជម្រះក៏សូមប្រគល់វេទិកា(ឮមិនច្បាស់)ជូនទៅលោកចៅក្រម ហ្សង់ម៉ាក ដើម្បីឆ្លើយតបទៅនឹងការកត់សម្គាល់របស់ភាគីអម្បាញ់មិញនេះ ពាក់ព័ន្ធដែលលើកយកកំណត់ហេតុនៃសាក្សីមួយ ហើយមកសួរដេញដោលចំពោះសាក្សីមួយទៀត។ ហើយនិងឲ្យគាត់បន្តតាំងសំណួរបញ្ចប់នូវអ្វីដែលគាត់មានបំណងក្នុងការសួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ចំពោះបញ្ហានៃការប្រើប្រាស់សក្ខីកម្មរបស់សាក្សីផ្សេងទៀត យកសួរដេញដោលសាក្សីនៅចំពោះសវនាការនេះ។ ខ្ញុំសូមបញ្ជាក់ថា នេះវាជាកំហុសឆ្គង វាជាការយល់ច្រឡំចំពោះខ្ញុំ។ អង្គជំនុំជម្រះមិនចង់កែប្រែនូវសេចក្ដីសម្រេចរបស់ខ្លួនទេ។ ខ្ញុំសូមបញ្ជាក់ជូនភាគីថា សាក្សីមានរហស្សនាម គឺសាក្សី TCW-229។

[១១:១៣:៤៤]

ដូច្នេះ ខ្ញុំសូមឲ្យបង្គាប់ឲ្យភាគីប្រើប្រាស់នូវរហស្សនាម ដើម្បីនិយាយសំដៅដល់សាក្សីរូបនេះ។ ហើយដើម្បីចៀសវាងនូវការលំបាកនាពេលខាងមុខ។ អង្គជំនុំជម្រះនឹងស្ដាប់សក្ខីកម្មសាក្សីនេះ នៅពេលក្រោយនៃនីតិវិធី។ ដូច្នេះ គឺដើម្បីសួរសំណួរសំខាន់ៗទៅកាន់សាក្សីរូបនេះ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ខ្ញុំមានសំណួរខ្លីៗមួយចំនួនទៀត ដើម្បីសួរទៅកាន់សាក្សី។ លោកសាក្សីលោកបានបញ្ជាក់

ថាមានបរិយាកាសភ័យខ្លាចនៅក្នុងក្រសួងការបរទេស។ ហើយលោកបង្ហាញអំពីមូលហេតុ លោកក៏បានពន្យល់ថា លោកមានតួនាទីជាអ្នកជួយខាងផ្នែកសតិអារម្មណ៍។ ខ្ញុំចង់ឲ្យលោកពន្យល់ឲ្យបានក្បោះក្បាយបន្តិចមើល៍ អំពីតួនាទីជាអ្នកជួយខាងផ្នែកសតិអារម្មណ៍នេះ គឺថាលោកជាអ្នកនិយាយដើម្បីឲ្យបងប្អូនគាត់មានសតិអារម្មណ៍នឹងនរស្ងប់ចិត្តនោះ។ តើហេតុអីបានជាលោកត្រូវជាអ្នកធ្វើបែបនេះទៅវិញ? ហើយការខ្លាចនោះ តើខ្លាចរបៀបម៉េច? ខ្លាចអីដែរ?

**លោក សាឡុត បាន៖**

**ឆ៖** ទីមួយ ខ្ញុំសូមឆ្លើយអំពីរឿងការខ្លាច។ សូមជម្រាបពីសភាពការណ៍បានដឹងរឿង។ ខ្លាចនោះ មិនមែនខ្លាចតែត្រឹមថ្ងៃនោះទេ។ ខ្លាចតាំងពីដើមមក ប៉ុន្តែខ្លាចហ្នឹងមានការប្រុងប្រយ័ត្ន ពាក្យថា--បើខ្លាច ត្រូវប្រុងប្រយ័ត្ន ត្រូវមានវិធីទប់ទល់ កុំឲ្យខ្លាច។ អានេះជាការដោះស្រាយនូវការខ្លាច។ អ្នកដែល បង្ករឿងឲ្យខ្ញុំខ្លាចហ្នឹង ខ្ញុំគិតថា សួរពីអារម្មណ៍ខ្ញុំហើយនេះ។ អ្នកបង្ករឿងឲ្យខ្ញុំខ្លាច ដើមទីគេនោះ ខ្ញុំ បាននិយាយហើយ គឺមកពីលេខ០០០ អ្នកនាំហេតុ អ្នកដឹកនាំហេតុដែលខ្ញុំខ្លាចមុនដំបូងហ្នឹង គឺអ្នកបង្ករឿង អ្នកដែលនាំបង្ករឿង ន៎ែ!ខ្ញុំរកឃើញអ្នកនាំបង្ករឿង។ ដល់ខ្ញុំរកឃើញអ៊ីចឹងទៅ ខ្ញុំទៅអប់រំខាងសតិអារម្មណ៍ឲ្យបងប្អូនឃើញហើយ។ តើអាណាអ្នកបង្ករឿងមុនគេ?

[១១:១៦:២៩]

រឿងកម្ពុជាមិនមែនជារឿងខ្មែរក្រហមឯណា អ្នកបង្ករឿង គឺរឿង០០ ខ្ញុំមិនបញ្ចេញឈ្មោះទេ អានេះខ្ញុំចប់ប៉ុណ្ណោះ។ ទីពីរ ពេលខ្ញុំខ្លាចនៅពេលនេះ គឺខ្ញុំខ្លាចយួនលេបទឹកដី នេះទីមួយអារម្មណ៍ខ្ញុំ។ ទីពីរ ខ្លាច ខ្ញុំបាននិយាយហើយតើ ខ្ញុំខ្លាចខ្លួនខ្ញុំនេះ ជាក្របីឈ្លៀក និងក្របីខ្មៅ។ បងប្អូនខ្ញុំជាក្របីឈ្លៀក ក្របីខ្មៅ ត្រូវទន្សាយវាបោក វាចាក់ចុចអុជអាលឲ្យបែកបាក់គ្នា។ នេះជាអារម្មណ៍ខ្ញុំខ្លាច។ សូមជ្រាប។

**ស៖** តើលោកចង់និយាយថា លោកខ្លាចពីព្រោះថា លោកមានខ្មាំងនៅជុំវិញមែនទេ? លោកខ្លាច ដោយសារតែមានខ្មាំងនៅក្នុងក្រសួងការបរទេស តើមែនឬទេ? ឬមួយក៏លោកខ្លាច ដោយសារតែខ្លាចទៅលើគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** ខ្ញុំបញ្ជាក់អំមិញល្មមសមរម្យលោកយល់ហើយ។ ខ្ញុំមិនមែនខ្លាចកម្ពុជាប្រជាធិបតេយ្យទេ ខ្ញុំខ្លាច អ្វីដែលខ្ញុំនិយាយ ខ្ញុំមិននិយាយសាដើមទៀតទេបាទ។

[១១:១៨:១៨]

**ស៖** គឺថាមានការសម្ងាត់ ឬក៏អាថ៌កំបាំងពាក់ព័ន្ធទៅនឹងសំណុំរឿង០០០ ខ្ញុំមិនដឹងថាតើលោក

សំដៅទៅលើស្ទីទេអារឿង សំណុំរឿង000 នេះ ថាជាសំណុំរឿងនៅតុលាការដែលកំពុងស៊ើបសួរ ឬក៏យ៉ាងណា?

**ឆ៖** សំណុំរឿង000 នេះគឺខ្ញុំសម្ងាៗទិដ្ឋិរកឃើញ ខ្ញុំចងក្រងជាឯកសាររបស់ផ្ទាល់ខ្ញុំ សម្រាប់ផ្ទាល់ខ្លួនខ្ញុំបានរីកចម្រើន ហើយនិងសម្រាប់ឲ្យបងប្អូន គ្រួសារខ្ញុំនឹងរីកចម្រើន ប៉ុន្តែការរីកចម្រើននេះបើសាយភាយដល់សកលលោក ក៏ទទួលយកចុះ បើមិនសាយភាយល្អដល់សកលលោកទេ មិនបាច់យកទេ។

[១១:១៩:២៦]

**ស៖** ខ្ញុំចង់ត្រឡប់មកនិយាយអំពីចម្លើយរបស់លោក ដែលលោកបានឆ្លើយកាលពីថ្ងៃទី២៤ មេសា នៅក្នុងសវនាការ។ សហព្រះរាជអាជ្ញាបានសួរលោកអំពីមនុស្សដែលត្រូវបានយកទៅធ្វើជាបណ្តោះអាសន្ននៅក្រសួងការបរទេសដោយ ប៉ង់ ហើយមុន និងក្រោយពេលដែល ក្រោយមកត្រូវ ប៉ង់ ចាប់ខ្លួន។ គេបានសួរសំណួរទៅកាន់លោកថា តើលោកមានដឹងពីមូលហេតុ ថាហេតុអីបានជាមនុស្សទាំងអស់នេះ ត្រូវបានផ្ទេរទៅក្រសួងការបរទេសទេ? លោកបានឆ្លើយថា៖ ខ្ញុំកត់សម្គាល់ឃើញថាក្រសួងការបរទេសអត់មានអាវុធទេ។ គេបានពន្យល់ ឲ្យលោកពន្យល់អំពីទំនាក់ទំនងរវាងប្រការដែលថាមិនមានអាវុធ ហើយនិងការចាប់ខ្លួន។ ហើយលោកបានឆ្លើយតបទៅវិញថា ប្រហែលជាគេទុកចិត្តខ្ញុំ។ ខ្ញុំបានមើលឡើងវិញហើយ ហើយខ្ញុំមិនបានឃើញការឆ្លើយ ចម្លើយដែលផ្ទាល់ទៅនឹងសំណួរនេះទេ។ បើតាមលោក ហេតុអីបានជាថាលោកកត់សម្គាល់ឃើញថាអត់មានអាវុធនៅក្រសួងការបរទេស? ហើយគេយកមនុស្សទៅធ្វើបណ្តោះអាសន្ននៅក្រសួង។ អាចពន្យល់អំពីការចាប់ខ្លួនមនុស្សទាំងអស់នោះទៅវិញនោះ។

តើលោកយល់សំណួររបស់ខ្ញុំទេ?

[១១:២១:០៨]

**ឆ៖** បាទខ្ញុំអត់យល់សំណួរ។

**ស៖** ដើម្បីឲ្យងាយស្រួលនោះ បើតាមលោក តើវាមិនមានការងាយស្រួលទេឬនៅក្នុងការចាប់ខ្លួនមនុស្សម្នាក់នៅពេលដែលគេដឹងថាគាត់នៅកន្លែងមួយដែលអត់មានអាវុធនោះ?

**ឆ៖** កន្លែងណាដែលអត់មានអាវុធ ខ្ញុំយល់ឃើញថា គេមកយកទៅ គេមកចាប់ទៅគឺស្រួល។

**ស៖** អ៊ីចឹងហើយបានជាមិនមែនជាមូលហេតុ អ៊ីចឹងហើយបានជាគេយកមនុស្សនោះទៅដាក់

នៅក្រសួងការបរទេសមែនទេ ពីព្រោះគេដឹងថាក្រសួងការបរទេសអត់មានអាវុធ?

**ឆ៖** ខ្ញុំវិភាគដោយខ្លួនឯង ប្រហែលអ៊ីចឹងមែន។

**ស៖** នៅពេលដែលមានការចាប់ខ្លួន តើគេមានសួរសំណួរទៅកាន់លោកទេ? តើលោកនិយាយអីខ្លះដើម្បីឲ្យបងប្អូនមានអារម្មណ៍នឹងនរស្ងប់ចិត្តនោះ? តើមនុស្សនៅក្រសួងការបទេសមានការភ័យខ្លាចចំពោះការចាប់ខ្លួនដែរឬទេ?

**ឆ៖** មានការភ័យ។ គោលការណ៍មានតែខ្លួនយើងៗដឹងខ្លួនឯងទៅ ខំតែធ្វើការទៅ។ ខ្លួនគេៗធ្វើយ៉ាងម៉េច គេយកទៅណាទៅណីអីស្រេចតែគេទៅ។ យើងធ្វើតែខ្លួនឯងទៅបានហើយ កុំដឹងរឿងគេ។ កុំចង់ដឹងរឿងគេពេក។ ដឹងតែការងារខ្លួនឯងបានហើយ បានរក្សាសេចក្តីសុខបាន ពីព្រោះមានគេចាក់ចុចអុជអាលខ្លាំងណាស់ មិនទាន់ស្រួលបួលទេស្រុកយើង។ នេះគឺជាសម្តីរបស់ខ្ញុំ ដែលខ្ញុំធ្លាប់ប្រើ។

[១១:២៣:៥០]

**ស៖** សំណួរចុងក្រោយ នៅពេលដែលលោកបាននិយាយអំពីពូរបស់លោកនៅដើមសវនាការនេះ លោកមានការកត់សម្គាល់អំពីផែនការសង្គមរបស់ពូរបស់លោក។ លោកដូចជាបានប្រើពាក្យថា “គាត់មានផែនការសន្តិភាព”។ តើនេះជាអ្វីដែល-- តើត្រឹមត្រូវទេដែលខ្ញុំស្តាប់ឮ ឬក៏ខ្ញុំមានការភ័ន្តច្រឡំ?

**ឆ៖** មានផែនការសង្គម មានផែនការសន្តិភាព។ តាមសំណួរនេះ ខ្ញុំមិនច្បាស់លាស់ទេ។ ខ្ញុំមិនអាចឆ្លើយបានទេ បាទសំណួរដូចមិនច្បាស់លាស់ ចង់សួរឲ្យច្បាស់លាស់ជាងហ្នឹងបន្តិចបាទ។

[១១:២៤:៥០]

**ស៖** លោកសាក្សី បើតាមលោក តើគោលបំណងនៃផែនការសង្គម ដែលគ្រោងឡើងដោយពូរបស់លោក គឺលោក ប៉ុល ពត នោះ តើជាផែនការសន្តិភាពឬ? តើនេះជាអ្វីដែលលោកបាននិយាយដែរឬទេ?

**ឆ៖** ខ្ញុំមិនបាននិយាយថាផែនការសន្តិភាពអីទេ គឺខ្ញុំធ្លាប់និយាយថា គឺជាទ្រឹស្តីមួយឲ្យចេះស្រឡាញ់ខ្លួនឯង ចេះស្រឡាញ់ជាតិ ចេះស្រឡាញ់ប្រជាជន កុំរំលោភ កុំបំពានលើជាតិ លើប្រជាជនហើយយើងរួមរស់ដោយសន្តិវិធីជាមួយអ្នកជិតខាង ហើយកុំឲ្យមានអ្វីជាមូលដ្ឋានសឹកអីៗ មកលើទឹកដីកម្ពុជាយើង ៗចង់បានអព្យាក្រឹត្យ យើងចង់បានសុខ។ នេះជាសម្តីរបស់លោកដែលខ្ញុំស្តាប់បាន។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកសាក្សី។ លោកប្រធានខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណលោកចៅក្រម។ បាទ ជាកិច្ចអង្គជំនុំជម្រះផ្តល់វេទិកា ទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

[១១:២៦:៥១]

**សួរដោយលោក ម៉ៃខល កាណាវាស៖**

អរុណសួស្តីលោកប្រធាន លោក លោកស្រីចៅក្រម។ អរុណសួស្តីសាក្សី អស់លោក លោកស្រីនៅក្នុងបន្ទប់សវនាការ និងនៅជុំវិញបន្ទប់សវនាការ។

**ស៖** មុនពេលដែលខ្ញុំចាប់ផ្តើមសួរសំណួរទៅ សាក្សីដែលខ្ញុំបានរៀបចំឡើងនេះ គឺខ្ញុំសូមលើកឡើងអំពីសំណុំរឿង000 ដែលលើកឡើងនៅក្នុងថ្ងៃនេះ រួមទាំងពីពេលមុនផងដែរ។ លោកទើបតែជម្រាបយើងខ្ញុំថា លោកបានឃើញបុគ្គលម្នាក់ នៅពេលដែលលោកមានការភ័យខ្លាច ហើយដឹងអំពីរឿង000នោះ ថាតើអ្នកណាជាជនជាប់ចោទ ជនត្រូវចោទនៅក្នុងរឿងក្តី000 ដែលលោកលើកឡើងនេះ?

**លោក សាឡុត បាន៖**

**ឆ៖** ខ្ញុំសូមជម្រាបសាឡើងវិញ។ បើតាមខ្ញុំយល់គឺ 00 នេះជាមេបង្កហេតុ បើគ្មានលេខ0 តើមានលេខ១0 ឬទេ? ខ្ញុំសូមសួរអ៊ីចឹងវិញ? សំណួរសួរដោយខ្លួនឯងទេ។ មិនអាចបង្កើតលេខ១0 បានទេ ហើយក៏មិនអាចបង្កើតលេខ២0 បានដែរ ហើយក៏មិនអាចបង្កើតលេខ១0.000 បានដែរ។ ឪពុកខ្ញុំ ខ្ញុំម្តាយខ្ញុំបង្កើតមកមានបងប្អូនបីនាក់។ ពេលណាដែលឈ្លោះគ្នា ឪពុកខ្ញុំ ខ្ញុំជាបងគេនេះ ឪពុកខ្ញុំថា អ្អែងអាក្បាលខូច អ្អែង អាក្បាលធំ អ្អែងមិនចេះការពារបងប្អូនទេអ្អី? គំនិតនេះ គឺវាចេញដោយគំនិតខ្ញុំពិចារណា នៅក្នុងខួរក្បាលខ្ញុំទេ ខ្ញុំអត់មានទ្រឹស្តីពីកុម្មុយនីស្តណាទេ។ សូមលោកជ្រាប។

[១១:២៩:១០]

**ស៖** សូមអរគុណ។ នៅពេលដែលលោកនិយាយថា លោកមិនបាន មិនអាចការពារបងប្អូនរបស់លោកនោះ គឺលោកសំដៅទៅលើមិនអាចការពារបងប្អូនរបស់លោក នៅក្នុងឆ្នាំ៧៥ ដល់៧៩ ឬក៏លោកចង់និយាយអំពីអ្វីដែរ?

**ឆ៖** ខ្ញុំចង់និយាយនេះគឺ និយាយរួមតែម្តង។ បើចិត្តខ្ញុំចង់និយាយមួយពិភពលោកតែម្តងបាទ។

**ស៖** សូមអរគុណ។ មុនបន្តទៅមុខទៀត ដូច្នេះ។ ខ្ញុំសូមនិយាយអំពីប្រវត្តិរូបរបស់លោក

បន្តិច។ តាមអ្វីដែលលោកឆ្លើយ លោកបានជួបអ៊ំរបស់លោកនៅចុងឆ្នាំ១៩៦៧, ៦៨ ឬក៏ ៦៩។ តើលោកបានជួបគាត់នៅពេលនោះ ត្រឹមត្រូវដែរឬទេ?

[១១:៣០:១១]

**ឆ៖** សូមបញ្ជាក់ តើជួប ខ្ញុំជួបនៅក្នុងសង្គ្រាម ឬក៏ជួបតែម្តង?

**ស៖** តាមចម្លើយរបស់លោកៗបានលើកឡើងថា លោកបានចូលព្រៃនៅក្នុង៦៧ និង ៦៨ លោកក៏បានបញ្ជាក់ផងដែរថា នៅអំឡុងឆ្នាំ៦៨ និង៦៩ ដែលលោកនៅជាមួយពូរបស់លោកគឺ ប៉ុល ពត តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ពេលនោះ ខ្ញុំនៅជាមួយពូរបស់ខ្ញុំនៅក្នុងព្រៃរតនគិរី។

**ស៖** តាមចម្លើយរបស់លោកៗនៅជាមួយនឹងពូរបស់លោករហូតដល់ពេលបែកភ្នំពេញ។ បានន័យថារហូតមកដល់ឆ្នាំ៧៥ ត្រឹមត្រូវដែរឬទេ?

[១១:៣១:១៩]

**ឆ៖** បាទ ជាការត្រឹមត្រូវ។

**ស៖** តាមចម្លើយរបស់លោកបានលើកឡើង លោកស្និទ្ធជាមួយនឹងលោកពូរបស់លោកណាស់នៅពេលនោះ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បើប្រៀបធៀបនឹងលោក ប៉ង់ ៗស្និទ្ធជាងខ្ញុំ។

**ស៖** នៅពេលនេះ យើងមិននិយាយអំពី ប៉ង់ ទេ យើងសួរអំពីលោកសាក្សី។ តើលោកជិតស្និទ្ធជាមួយនឹងលោកឪពុកមាររបស់លោកដែរឬទេ?

**ឆ៖** ខ្ញុំសូមពន្យល់ បើខ្ញុំនិយាយមុនហ្នឹងអ៊ីចឹង ឥឡូវលោកសួរទៀត ខ្ញុំពន្យល់។ ពាក្យ "ជិតស្និទ្ធ" នេះ វាមានពីរបែប។ មួយ ជិតស្និទ្ធជាគ្រួសារ ជាគ្រួសារណ៍ា ប៉ុន្តែមួយទៀត ជិតស្និទ្ធជាយុទ្ធជនម្នាក់ ដែលនៅក្រោមអំណាចនៃសង្គ្រាមបាទ។

**ស៖** សូមអរគុណ ដែលលោកបញ្ជាក់បំភ្លឺត្រង់ចំណុចនេះ។ នៅពេលនេះ យើងនិយាយអំពីការជិតស្និទ្ធតាមរយៈអារម្មណ៍ ឬតាមរយៈរូបរាងកាយ បានន័យថា លោកជិតស្និទ្ធតាមផ្លូវ-- បានន័យថាមានអារម្មណ៍ជិតស្និទ្ធជាមួយនឹងលោកឪពុកមាររបស់លោកដែរឬទេ នៅក្នុងអំឡុងឆ្នាំទសវត្សរ៍៦០ នោះ?

[១១:៣៣:០៤]

**ឆ៖** បាទ ជិតស្និទ្ធជារៀងរហូត បាទ ហើយស្រឡាញ់ជាសក្ការៈទៀត។

**ស៖** តើលោកបានធ្វើម្ហូបអាហារជូនឪពុកមារបស់លោកដែរឬទេ?

**ឆ៖** លោកទុកចិត្តខ្ញុំ ហើយខ្ញុំធ្វើអាហារជូនលោកឆ្ងាញ់ជាងគេ។

**ស៖** តើឪពុកមារបស់លោកនោះ បានន័យថា ជឿទុកចិត្តលើលោកដោយគាត់មិនអាចជឿថា លោកអាចបាញ់គាត់បានអីចឹងដែរឬទេ?

[១១:៣៣:៥៥]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ។ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** គឺសូមកែតម្រូវ គឺលោកទុកចិត្តលោកឪពុកមារបស់លោករហូតដល់គាត់អាចយល់ថា លោកមិនអាចចាក់ថ្នាំដល់រូបលោកបានឬក៏យ៉ាងម៉េច?

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន អម្បាញ់មិញនេះ ខ្ញុំបានស្ដាប់សំណួររបស់លោក កាណាវាស អត់បាន។ អីចឹង សូមឲ្យគាត់សួរសំណួរឡើងវិញ។ សំណួរអម្បាញ់មិញនេះ ខាងដើមសំណួរហ្នឹងស្ដាប់អត់បានទេលោក ប្រធាន។

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** តើលោកមានដែលធ្លាប់ចាក់ថ្នាំឲ្យឪពុកមារបស់លោកដែរឬទេ?

[១១:៣៤:៣៤]

**លោក សាឡុត បាន៖**

**ឆ៖** បាទ ខ្ញុំធ្លាប់។

**ស៖** តើលោកជាអ្នកយាម ជាអង្គរក្សលោកឪពុកមារបស់លោកដែរឬទេ?

**ឆ៖** ខ្ញុំចម្រុះ ធ្វើការចម្រុះ ថាអង្គរក្សក៏មិនបាន ថាអ្នកដាំបាយក៏មិនបាន ថាពេទ្យក៏មិនបាន គឺចម្រុះ។ លោកឲ្យធ្វើអី គឺធ្វើនុំង លោកឲ្យបើកម៉ូតូ គឺបើកម៉ូតូ បើម៉ូតូហើយអត់មានអីសម្រាកតែប៉ុណ្ណោះឯងបាទ។

**ស៖** សូមអរគុណ។ ក្នុងអំឡុងពេលនោះ តើលោកអាចជម្រាបយើងខ្ញុំបានដែរឬទេថា ប៉ុន្មានថ្ងៃក្នុងសប្ដាហ៍ ដែលលោកនៅកៀកជាមួយនឹងឪពុកមារបស់លោក? ហើយបើសិននៅកៀកនោះ ក្នុង

ប៉ុន្មានថ្ងៃមួយសប្តាហ៍? ហើយមួយថ្ងៃប៉ុន្មានម៉ោងដែរ?

[១១:៣៥:៤១]

**ឆ៖** និយាយពីរឿងកៀក កៀកហ្នឹងវាថា បើថាកៀកស្នេហាអីអាហ្នឹងវាផ្សេងបាទ។ កុំច្រឡំណា! គឺថាកៀកនេះគឺកៀកតាមភារកិច្ច ទាំងអស់គ្នាហ្នឹងត្រូវតែកៀកហើយ បើជាកងការពារបាទ។ ដូច្នេះ ក្នុងមួយបរិវេណដែលខ្ញុំត្រូវនៅហ្នឹងវាកៀកហើយ មិនឆ្ងាយដូចទីក្រុងអីទេ គឺថាបរិវេណដែលនៅហ្នឹង គឺកៀកគ្នាតែទាំងអស់ ប៉ុន្មាននាក់ដែលការពារហ្នឹង យើងនិយាយថាកៀកហើយ។ ដូច្នេះទាំងអស់គ្នានៅចាំការពារគាត់ហ្នឹង ម្ភៃបួនម៉ោងលើម្ភៃបួនម៉ោង។

**ស៖** សូមអរគុណ។ តាមរយៈចម្លើយនេះ បានន័យថា លោកម្ភៃបួនម៉ោងក្នុងមួយថ្ងៃ ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍ នៅកៀកជិតគាត់តែម្តង។ យើងអាចសន្និដ្ឋានបានអ៊ីចឹងដែរឬទេ?

**ឆ៖** ខ្ញុំថាបើកៀក កៀកម្ភៃបួនម៉ោង ប៉ុន្តែផ្លាស់ប្តូរគ្នាដេកដែរ មិនមែនថា អត់បានដេកបានពួននោះទេបាទ។ ចង់បញ្ជាក់អ៊ីចឹងបាទ។

**ស៖** សូមអរគុណ។ យើងនិយាយអំពីការកៀកតាមផ្លូវចិត្ត ជាមួយនឹងឪពុកមារបស់លោកម្តង។ តើលោកអាចជម្រាបរៀបរាប់ទំនាក់ទំនង ដែលថាជិតស្និទ្ធតាមផ្លូវអារម្មណ៍ផ្លូវចិត្តនោះយ៉ាងម៉េចដែរជាមួយឪពុកមារបស់លោក?

[១១:៣៧:២៤]

**ឆ៖** ខ្ញុំបានជម្រាបហើយ ឪពុកមារបស់ខ្ញុំ ខ្ញុំស្រលាញ់ជាសក្ការៈ ពាក្យថា សក្ការៈនេះវាពេញលេញហើយ។ ពាក្យថា សក្ការៈហ្នឹងគឺថា ឥឡូវគាត់ស្លាប់ ខ្ញុំត្រូវយកធូបទៅបន់ឲ្យគាត់ទៅបានដល់សុខគតិភពបាទ។ សូមប៉ុណ្ណឹងទេបាទ។

**ស៖** ចុះចំពោះឪពុកមារបស់លោកចំពោះលោក តើគាត់មានស្រលាញ់ជាសក្ការៈដល់លោកដែរឬទេ? ហើយគិតថា លោកជាកូនប្រុសល្អមួយរូបដែរឬទេ?

**ឆ៖** គាត់បានកសាង ទិតៀនខ្ញុំជាច្រើន ប៉ុន្តែចំណុចអាក្រក់ក៏ខ្ញុំមាន ប៉ុន្តែចំណុចល្អដែលខ្ញុំមាន។ ចំណុចល្អដែលខ្ញុំមាន ដែលខ្ញុំចាប់អារម្មណ៍រហូតមកដល់ថ្ងៃនេះគឺ ចេះរួបរួមសាមគ្គីគ្នាបានក្នុងអង្គភាព។ បាទ សូមមានប៉ុណ្ណេះ។

[១១:៣៨:៣៩]

**ស៖** តើលោកអាចចេញចូលជួបជាមួយនឹងឪពុកមា របស់លោកបានដែរឬទេ នៅពេលដែល

លោកចង់ទៅជួបគាត់នោះ?

**ឆ៖** ខ្ញុំមិនអាចចេញចូលបាន សុំទៅជួបលោកបានទេ។

**ស៖** តើលោកអាចទៅជួបគាត់នោះ តាមរយៈបុគ្គលមួយរូបផ្សេងនៅពេលដែលលោកចង់ទៅជួបគាត់ដែរឬទេ?

**ឆ៖** ទាល់តែមានភារកិច្ចបានទៅជួប។

**ស៖** លោកនិយាយថា គាត់អប់រំលោក។ ដូច្នេះ តើគាត់មានដែលធ្លាប់អង្គុយនៅកន្លែងណាមួយអប់រំគាត់-- អប់រំមកលោកនិយាយជាមួយលោកដែរឬទេ? តើការអប់រំនោះយ៉ាងម៉េចដែរ? ដោយរបៀបណា?

[១១:៣៩:៥០]

**ឆ៖** បើពីតូចគាត់អប់រំខ្ញុំ ដោយអង្គុយលើភ្លៅលើអី ដល់តែចូលព្រៃចូលអីហើយ គេហៅថាចូលធ្វើនយោបាយហើយ នែ៎! ធ្វើការតស៊ូ មិនមែននយោបាយទេ ធ្វើការតស៊ូហើយ ខ្ញុំមិនដែលឃើញលោកហៅខ្ញុំទៅអង្គុយនិយាយដោយតែឯងទេ។

**ស៖** សូមអរគុណ។ តាមចម្លើយនេះ យើងអាចសន្និដ្ឋានបានថា ឪពុកមារបស់លោកមិនដែលអប់រំលោក អំពីគំនិតដែលឪពុកមារបស់លោកគិតគូរយ៉ាងម៉េច យ៉ាងម៉ានោះទេ ហើយក៏មិនដែលអប់រំលោកអំពីកម្មវិធីនយោបាយ កម្មវិធីនៃការធ្វើបដិវត្តន៍ តើអ៊ីចឹងមែនដែរឬទេ?

**ឆ៖** បាទ មានតែអប់រំជារួម។

**ស៖** ហើយតើគាត់មានប្រាប់ថា អ្នកណាខ្លះនៅក្នុងសមាជិកអចិន្ត្រៃយ៍ដែរឬទេ? គណៈអចិន្ត្រៃយ៍ដែរឬទេ?

**ឆ៖** គាត់មិនដែលប្រាប់អីទេ។

**ស៖** តើគាត់មានដែលប្រាប់ថា អ្នកណាខ្លះជាសមាជិកគណៈមជ្ឈិមដែរឬទេ?

**ឆ៖** សូន្យហើយ អត់ទេ។

**ស៖** តើគាត់ធ្លាប់ដែលប្រាប់អំពីរចនាសម្ព័ន្ធដឹកនាំរណាខ្លះ? មានតួនាទីអ្វី? អំណាចអ្វី? តើគាត់មានដែលធ្លាប់ពិភាក្សាអ៊ីចឹងជាមួយលោកដែរឬទេ?

[១១:៤១:៤៦]

**ឆ៖** បាទ អត់មានទេ។

**សៈ** តើគាត់ដែលពន្យល់ប្រាប់លោក ថាតើអំណាចតួនាទីរបស់គាត់នោះអ្វីដែរ ដែលប្រាប់លោកអ៊ីចឹងដែរឬទេ?

**ធៈ** បាទ អត់មានអំណួតអ៊ីចឹងទេ។

**សៈ** តើគាត់បានប្រាប់លោកថា គាត់ធ្លាប់ធ្វើសេចក្តីសម្រេចដោយផ្អែកលើគោលការណ៍សមូហភាពដែរឬទេ?

**ធៈ** ជាទ្រឹស្តីនេះ គាត់បង្រៀនជាទូទៅ។

**សៈ** តើគាត់ធ្លាប់បានប្រាប់លោកថា គាត់ធ្លាប់អនុវត្តគោលការណ៍ប្រជាធិបតេយ្យសមូហភាពនោះ ជាគោលការណ៍ហ្នឹងរហូតមក អ៊ីចឹងដែរឬទេ?

**ធៈ** ផ្ទាល់ខ្លួន មិនបានប្រាប់ផ្ទាល់ទេ គឺនៅពេលរៀនសូត្រ។

**សៈ** តើឪពុកមារបស់លោក ធ្លាប់អញ្ជើញលោកឲ្យទៅចូលរួមកិច្ចប្រជុំណាមួយ ដែលគាត់ជាប្រធានដែរឬទេ? ខ្ញុំមិនមែននិយាយអំពីវគ្គអប់រំទេ គឺថាកិច្ចប្រជុំ។ តើគាត់ធ្លាប់មានអញ្ជើញលោកឲ្យទៅចូលរួមកិច្ចប្រជុំទាំងឡាយណាដែលគាត់ជាប្រធាននៅពេលនោះដែរឬទេ ប្រធានអង្គប្រជុំ?

[១១:៤៣:៣១]

**ធៈ** អង្គប្រជុំ អង្គប្រជុំហ្នឹងមានន័យថា គ្នាច្រើនណាស់ មិនមែនបុគ្គលខ្ញុំទល់គ្នាទេ។ អង្គប្រជុំគឺក្នុងន័យថា មានគ្នីគ្នាជាច្រើន នោះខ្ញុំបានចូលរួម។

**សៈ** សូមអរគុណ។ ដូច្នេះ ខ្ញុំយល់ថា នៅពេលដែលភូមិភាគ មេភូមិភាគមកជួបជាមួយឪពុកមារបស់លោក លោកក៏ចូលរួមនៅក្នុងកិច្ចប្រជុំនោះផងដែរ ដែលនៅពេលនោះ ឪពុកមារបស់លោកបានពិភាក្សាជាមួយនឹងមេដឹកនាំភូមិភាគទាំងអស់នោះ តើអ៊ីចឹងដែរឬទេ?

**ធៈ** មិនមែនយ៉ាងដូច្នេះទេ។ ភារកិច្ចភូមិភាគអីៗមកប្រជុំ ខ្ញុំអត់មានបានចូលទេ។ ពាក្យថា "អង្គប្រជុំ" នេះ គឺអង្គប្រជុំត្រឹមតែថ្នាក់ខ្ញុំ ដែលជាទទួលខុសត្រូវខាងផ្នែកក្រុមមួយ។ អង្គភាពមួយតែប៉ុណ្ណោះ។

**សៈ** តើឪពុកមារបស់លោកដែលប្រាប់ឲ្យលោកឲ្យបានដឹង ថាតើមានការពិភាក្សាអ្វីខ្លះនៅក្នុងកិច្ចប្រជុំទាំងឡាយ ដែលគាត់បានចូលរួមប្រជុំជាមួយគេឯងនោះ?

[១១:៤៤:៥៩]

**ធៈ** ប្រជុំជាសាលានោះ ខ្ញុំបានប្រជុំ។ ប្រជុំជាអង្គភាព ឧទាហរណ៍ ពេលខ្ញុំទៅនៅភូមិភាគ

បស្ចិម កំពង់ស្ពឺ គឺខ្មម មានគ្រប់មានអី គាត់ហៅខ្ញុំនេះ អ្នកគ្រប់គ្រងអាដែងធ្វើបញ្ជីគ្រាប់។ ប្រពន្ធខ្ញុំដាំបាយ កងការពារពីរបីនាក់ទៅ ហៅខ្ញុំទៅប្រជុំ។ រូបភាពវាអ៊ីចេះ។ អាហ្នឹងបានជួបជាមួយគាត់ បាទ ហើយគាត់ណែនាំទៅ ន៎ែ! អ្នកឯងធ្វើគ្រាប់អីឲ្យស្រួលណា ជិតចូលភ្នំពេញហើយណ៎ា អីអ៊ីចឹងទៅ អើអាអ្នកដាំបាយធ្វើអ៊ីចេះ ស្អែកហ្នឹងមានភ្ញៀវមកអីម្នាក់អ៊ីចឹង។ ប្រជុំអ៊ីចឹង គេហៅថាប្រជុំធម្មតាជាគ្រួសារ។

[១១:៤៦:១៣]

**ស៖** សូមអរគុណ។ នៅពេលដែលខ្ញុំនិយាយនៅពេលនេះ គឺខ្ញុំនិយាយអំពីកិច្ចប្រជុំដែលលោកមិនបានចូលរួម គឺកិច្ចប្រជុំដែលឪពុកមា ប៉ុល ពត របស់លោកនោះ ប្រជុំជាមួយនឹងមេដឹកនាំដទៃ ដូចជាមេដឹកនាំភូមិភាគ។ ក្រោយពីកិច្ចប្រជុំទាំងអស់នោះ តើឪពុកមារបស់លោកធ្លាប់ប្រាប់លោកថាមានពិភាក្សាអ្វីខ្លះនៅក្នុងកិច្ចប្រជុំទាំងអស់នោះ? ហើយមានការសម្រេចអ្វីខ្លះនៅក្នុងកិច្ចប្រជុំទាំងអស់? តើគាត់មានប្រាប់លោកទេ?

**ឆ៖** អត់មានប្រាប់ទេ។

**ស៖** តើឪពុកមារបស់លោកដែលធ្លាប់ហុចឯកសារជាលាយលក្ខណ៍អក្សរកំណត់ហេតុ កំណត់ត្រាណាមួយឲ្យលោក ដើម្បីឲ្យលោកអាន បានដឹងព័ត៌មានដែរឬទេ? ដើម្បីឲ្យលោកបានដឹងថាមានអ្វីពិភាក្សាសម្រេចនៅពេលប្រជុំទាំងអស់នោះ តើគាត់មានធ្លាប់ឲ្យទេ?

[១១:៤៧:១១]

**ឆ៖** អត់មានទេ។

**ស៖** នៅពេលដែលមានកិច្ចប្រជុំទាំងអស់នោះនៅក្នុងព្រៃ នៅពេលមេដឹកនាំភូមិភាគជួបប្រជុំជាមួយនឹងឪពុកមារបស់លោក គឺ ប៉ុល ពត តើគេមានធ្វើការប្រកាសជាទូទៅដែរឬទេ ឬក៏ការអញ្ជើញប្រជុំនោះតាមរយៈឪពុកមារបស់លោកតែប៉ុណ្ណោះ?

**ឆ៖** អត់មានប្រកាសឲ្យយើងខ្ញុំដឹងទេ។

[១១:៤៧:៥៦]

**ស៖** យើងសន្និដ្ឋានថា លោកមិនដឹងទេថា មេដឹកនាំភូមិភាគទាំងអស់នោះ ត្រូវបានគេអញ្ជើញមកចូលរួម ឬក៏មកដោយខ្លួនឯង គឺលោកមិនដឹងទេ តើមែនដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់បានដឹងទេ។

**ស៖** នៅពេលដែលមេដឹកនាំទាំងអស់នោះ មកដល់ចូលរួមប្រជុំ តើគេធ្លាប់ប្រាប់លោក ឪពុកមារបស់លោកធ្លាប់ប្រាប់លោក ឬក៏នរណាម្នាក់ធ្លាប់ប្រាប់លោកថា ភ្ញៀវដែលមកចូលរួមប្រជុំនោះមានអ្នកណាខ្លះ? ដែលមកចូលរួមប្រជុំជាមួយនឹងឪពុកមារបស់លោក ប៉ុល ពត, គេមានប្រាប់ទេ?

**ឆ៖** អត់មានប្រាប់ទេ។

**ស៖** តើលោកធ្លាប់សួរគេផ្សេង ដើម្បីដឹងព័ត៌មានទាំងអស់នេះដែរឬទេ? ដូចជាសួរ ប៉ង់ ថាតើភ្ញៀវមកចូលរួមប្រជុំនោះនរណាខ្លះ? លោកមានធ្លាប់សួរគេទេ?

**ឆ៖** បាទ ខ្ញុំធ្លាប់សួរគេដែរ គ្រាន់តែសួរហ្នឹង គឺត្រឹមតែឈ្មោះទេ អីៗទៀត ខ្ញុំអត់ប៉ានសួរ។

[១១:៤៩:២៤]

**ស៖** អ៊ីចឹងលោកបានដឹងឈ្មោះខ្លះទេ អ្នកណាមកចូលរួមប្រជុំ?

**ឆ៖** តើប្រជុំនោះនៅពេលណា?

**ស៖** ខ្ញុំសួរលោក លោកបាននិយាយថា នៅក្នុងកិច្ចប្រជុំមួយនោះ គឺលោកបានសួរថា មានអ្នកណាខ្លះមកចូលរួមប្រជុំ។ ហើយកាលពីថ្ងៃមុននោះ ក៏លោកបានលើកឡើងថា ម្នាក់ៗដឹងតែរឿងខ្លួនឯង។ ដូច្នេះនៅពេលនេះ ខ្ញុំចង់សួរលោក នៅពេលដែលលោកឆ្ងល់ថាតើនរណាមកចូលរួមប្រជុំជាមួយឪពុកមារបស់លោក ប៉ុល ពត។ តើគេមានប្រាប់ឈ្មោះអ្នកដែលមកចូលរួមប្រជុំនោះឲ្យលោកបានដឹងដែរឬទេ? ឬក៏គេផ្សេងនោះមកប្រាប់លោកថា កុំខ្វល់អីគិតតែរឿងខ្លួនឯងទៅបានហើយ តើលោកមានធ្លាប់ដឹងឈ្មោះបុគ្គលទាំងអស់នោះដែរឬទេ?

**ឆ៖** បាទ បើនិយាយអ៊ីចឹងគឺថា រហូតមកដល់ឥឡូវនេះ ខ្ញុំដឹងឈ្មោះទាំងអស់បាទ។ ប្រធានភូមិភាគ ដូចជាលោកសួរឈ្មោះ ឌឿន ឈ្មោះអីៗ នួន ជា, នួន អីហ្នឹងគឺថា ខ្ញុំស្គាល់ៗទាំងអស់បាទ។ នរណាដែលបានខ្ញុំសួរហើយ ខ្ញុំដឹងកន្លងមក ខ្ញុំស្គាល់បាទ។

**ស៖** ដូច្នេះបានន័យថានៅពេលនោះ គេប្រាប់ឈ្មោះលោកនៅពេលនោះតែម្តង គេផ្តល់ព័ត៌មានពាក់ព័ន្ធនឹងឈ្មោះបុគ្គលដែលមកចូលរួមប្រជុំនៅពេលនោះ ហើយលោកដឹងតែម្តង ឬក៏ឈ្មោះដែលលោកដឹងថាបានមកចូលរួមប្រជុំនោះ ទើបតែដឹងក្រោយពេលនេះទេ?

[១១:៥១:២៣]

**ឆ៖** ពេលដែលសួរ គេប្រាប់មក ខ្ញុំដឹងពេលនោះ។ ពេលណាដែលខ្ញុំមិនបានសួរគេ យូរៗមកទៀតទៅ ខ្ញុំសួរចេះតែសួរៗទៅក៏ដឹងហែហូរមកអ៊ីចឹងទៅបាទ។ ភាគច្រើន ខ្ញុំមិនស្គាល់ដឹងឈ្មោះពី

ដើមទេ អ្នកដឹកនាំអស់ទាំងនោះបាទ។

**សៈ** សូមអរគុណ។ នៅពេលនេះយើងនិយាយអំពី ប៉ង់ ម្តង។ លោកបានលើកឡើងថា លោកៗមិនស្និទ្ធនៅកៀក ប៉ុល ពត ដូច ប៉ង់ នោះទេ។ លោកនិយាយអំពីកៀកទាំងផ្លូវកាយ ទាំងផ្លូវចិត្ត។ អ៊ីចឹងថាតើមួយណាដែរ ដែលលោកថានៅមិនកៀកដូច ប៉ង់ នោះ? ផ្លូវកាយ ឬក៏ផ្លូវចិត្ត?

**ឆៈ** ខ្ញុំសូមអត្ថាធិប្បាយ គឺ ប៉ង់ ទទួលខុសត្រូវលើខ្ញុំ។ ដូច្នេះអ្វីៗក៏ដោយ ខ្ញុំមិនបានទៅសួរមតិសួរអីពី ប៉ុល ពត ទេ។ ខ្ញុំមានភារកិច្ចការពារ និងដាំបាយដាំទឹក ដែលគាត់ត្រូវការ ចាក់ថ្នាំចាក់អីតែប៉ុននុ៎ង។ ឯផែនការមន្ទីរអីផ្សេងៗ គឺ ប៉ង់ ដែលជាអ្នកទៅបានការណែនាំពី ប៉ុល ពត។

[១១:៥៣:១៥]

**សៈ** ខ្ញុំសូមបញ្ជាក់សួរឡើងវិញ ដើម្បីឲ្យខ្ញុំយល់។ លោកមិនទទួលការណែនាំពីឪពុកមារបស់លោកទេពាក់ព័ន្ធនឹងការងារប្រចាំថ្ងៃ។ ប៉ង់ ជួបពាក់ព័ន្ធការងារប្រចាំថ្ងៃជាមួយនឹង ប៉ុល ពត។ ដូច្នេះបានន័យថា ប៉ង់ ទទួលការណែនាំដោយផ្ទាល់ពី ប៉ុល ពត តើត្រឹមត្រូវដែរឬទេ? នេះជាអ្វីដែលលោកនិយាយ ហើយខ្ញុំយល់អ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆៈ** បាទត្រឹមត្រូវ។

**សៈ** តើលោកបានដឹងដែរឬទេ ថានៅពេល ប៉ង់ ទទួលការណែនាំពី ប៉ុល ពត នោះថាតើគេមានប្រាប់ថាលោកគួរធ្វើអ្វីដែរឬទេ?

**ឆៈ** គឺមានការណែនាំបន្ត ដូចតែខ្ញុំត្រូវការ ឧទាហរណ៍ស្អែកជូន-- ភាសាពេលនោះគេហៅថាបង ជូនបង ប៉ុល ពត ណ៎ា ទៅនេះណ៎ា មើលម៉ូតូឲ្យស្រួល។ រៀបចំទៅថ្នាំសង្កូវអី មួយព្រឹក ទៅមើលសមរភូមិ។ ខ្ញុំពេលនុ៎ងក៏រៀបចំទៅ តាមហ្នឹងទៅ ព្រឹកឡើងក៏ពនាក់ម៉ូតូគាត់ទៅ មើលសមរភូមិទៅ។ នេះខ្ញុំសូមជម្រាប។

[១១:៥៥:00]

**សៈ** សូមអរគុណ។ តើ ប៉ង់ បានដឹងថា លោកគឺជាក្មួយរបស់ ប៉ុល ពត ដែរឬទេ? បានន័យថាជាកូនរបស់បងរបស់ ប៉ុល ពត តើគាត់ដឹងដែរឬទេ?

**ឆៈ** បាទ ប៉ង់ ដឹង។

**សៈ** យើងនិយាយនឹងអំពី ប៉ង់ ឲ្យបានច្រើនជាងហ្នឹងបន្តិចនៅពេលបន្តិចទៀតនេះ ក៏ប៉ុន្តែខ្ញុំនិយាយអំពីឈ្មោះ ជាម ម្តង។ តាមចម្លើយរបស់លោកកាលពីម្សិលមិញ លោកបានលើកឡើងថា

លោកបានជួប ជាម នៅក្នុងព្រៃក្នុងឆ្នាំ៦៨ ឬ៦៩ តើត្រឹមត្រូវដែរឬទេ?

[១១:៥៦:០៥]

**ឆៈ** បាទ ៦៧, ៦៨ បាទ ៦៩ រហូតដល់៧០, ៧១ មកបាទ។

**សៈ** តើ ជាម នោះនៅក្រោមបង្គាប់របស់ ប៉ង់ ក្រោម ប៉ង់ ឬក៏យ៉ាងម៉េច? ឬក៏ ជាម ស្ថិតនៅក្រោមបុគ្គលផ្សេងនៅពេលនោះ?

**ឆៈ** ទាំងខ្ញុំ ទាំង ជាម នៅក្រោមបង្គាប់របស់ ប៉ង់។

**សៈ** ប្រសិនបើលោកអាចបំភ្លឺឲ្យបានភ្លឺជាងនេះបន្តិច តើ ជាម នោះទទួលខុសត្រូវអ្វីដែរនៅពេលនោះ?

**ឆៈ** ជាម ជានីរសារ និងកងការពារ។ គេហៅថា ពេលនោះអត់មានកំណត់ការងារអីទេ គឺថាឲ្យតែត្រូវការអី នរណាទំនេរ ខាងលើឲ្យប្រើធ្វើអី គឺធ្វើបានទាំងអស់នៅក្រោមបញ្ជារបស់ ប៉ង់។

**សៈ** លោកមានការងារច្រើន តើលោកនៅពេលនោះធ្វើការជាមួយនឹង ជាម ដែរឬទេ?

**ឆៈ** ខ្ញុំនៅក្រោមបញ្ជារបស់ ប៉ង់។ ដូច្នេះ ខ្ញុំធ្វើការរួមគ្នាជាមួយ ជាម ដែរ។

**សៈ** តើលោកក៏រស់នៅ-- នៅផ្ទះ ឬក៏នៅក្នុងអគារជាមួយនឹង ជាម ដែល ជាម រស់នៅនោះផងដែរ។ តើអ៊ីចឹងដែរឬទេ? លោកនៅក្នុងកន្លែងជាមួយគ្នា ឬក៏យ៉ាងម៉េច?

**ឆៈ** ខ្ញុំពិបាកពន្យល់ ពីព្រោះមន្ទីរប-១ វាមានផ្ទះលេខ១, ផ្ទះលេខ២, ផ្ទះលេខ៣ អីកន្លែងភ្ញៀវ។ ដូច្នេះ ខ្ញុំសរុបចុះគឺខ្ញុំ ពេលណាជួប ជាម--

**សៈ** ខ្ញុំសូមបញ្ឈប់លោកបន្តិច។ ខ្ញុំនិយាយនៅក្នុងព្រៃៗនោះគឺ ប៉ង់ ជាណែនាំទៅដល់នីរសារ កងការពារ និងណែនាំទៅដល់លោក។ ដូច្នេះបានន័យថា លោករស់នៅជាមួយគ្នា ហូបជាមួយគ្នា ហើយដើរហើរចូលក្នុងសង្គមនៅទីនោះជាមួយគ្នា ឬក៏យ៉ាងម៉េច?

[១១:៥៩:១២]

**ឆៈ** អំមិញឮសួរថា អគារហ្នឹង ខ្ញុំវាពិបាកបក។ ដូច្នេះបើលោកបញ្ជាក់អ៊ីចឹង ខ្ញុំឆ្លើយថា នៅរួមគ្នា បាទរួមគ្នា។

**សៈ** តើនៅពេលនោះលោកជាមិត្តនឹងគ្នាដែរឬទេ? ហើយជិតស្និទ្ធគ្នាដែរឬទេ នៅពេលនោះ?

**ឆៈ** ការធ្វើបដិវត្តន៍ គេអត់ហៅឯកឧត្តម ឯកឧឧត្តម អីទេ គេហៅគ្នាថា សមមិត្ត។ ពាក្យថាសមមិត្តនេះ គឺទាល់តែយល់ចិត្ត យល់ថ្លើមគ្នា រួមរស់ជាមួយគ្នា កុំក្បត់គ្នា។ នេះហើយ ដែលហៅថា

ជាសមមិត្តនឹងគ្នា។

**ស៖** តើវា ករណីអ៊ីចឹង គេធ្វើអ៊ីចឹងតែម្តងនៅក្នុងសម័យនោះ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ខ្ញុំឃើញគេធ្វើអ៊ីចឹងទាំងអស់គ្នា។

[១២:០០:២៨]

**លោក ម៉ៃខល ការណាវ៉ាស៖**

លោកប្រធានខ្ញុំគិតថា នៅពេលនេះប្រហែលជាប៉ុន្មាន*សេហ្គុង* ហួសម៉ោងដប់ពីរ ប៉ុន្មានវិនាទីហួសម៉ោងដប់ពីរហើយ ដូច្នេះហើយ យើងគួរតែឈប់សម្រាកសិន ឬក៏យ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ អរគុណសាក្សី។ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយ សម្រាក ហើយនិងពិសាអាហារថ្ងៃត្រង់។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល និងផ្តល់កន្លែងសម្រាកសមរម្យសម្រាប់សាក្សី និងមេធាវីប្រឹក្សារបស់គាត់នៅបន្ទប់សម្រាប់សាក្សី ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅរសៀលនេះនៅម៉ោងមួយសាមសិបនាទី។

សូមអញ្ជើញលោកមេធាវី!

[១២:០១:២៤]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ កូនក្តីរបស់ខ្ញុំបានចុះហត្ថលេខានៅលើលិខិតបោះបង់សិទ្ធិចូលរួមដោយផ្ទាល់ក្នុងរយៈពេលដែលនៅសល់ក្នុងថ្ងៃនេះ ហើយលោកគាត់ គាត់ស្នើសុំទៅតាមនៅក្នុងបន្ទប់រង់ចាំខាងក្រោម។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញអង្គុយចុះ!

បាទ បានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់សុំទៅបន្តតាមដានកិច្ចដំណើរការ សវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍នៅបន្ទប់ខាងក្រោមបន្ទប់សវនាការនេះសម្រាប់រយៈពេលពេញមួយរសៀលនេះ ដោយគាត់លះបង់សិទ្ធិចូលរួមផ្ទាល់

ក្នុងកិច្ចដំណើរការសវនាការ ដោយក្រុមមេធាវីការពារក្ដីសន្យារថា នឹងប្រគល់មកអង្គជំនុំជម្រះនូវលិខិតលះបង់សិទ្ធិចូលរួមកិច្ចដំណើរការសវនាការដោយផ្ទាល់របស់ជនជាប់ចោទ។

អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំតាមរយៈមេធាវីការពារក្ដីរបស់គាត់ សុំទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមបន្ទប់សវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលពេញមួយរសៀលនេះ ដោយគាត់លះបង់សិទ្ធិចូលរួមផ្ទាល់ក្នុងកិច្ចដំណើរការសវនាការ ក្នុងបន្ទប់សវនាការនេះ។ អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្ដី ជនជាប់ចោទ នួន ជា ប្រគល់មកអង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ដែលធ្វើឡើងដោយលោក នួន ជា ហើយនិងបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ សម្រាប់ជនជាប់ចោទរូបនេះអាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមបន្ទប់សវនាការនេះ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់រសៀលនេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទ នួន ជា និងលោក ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោម ដោយឲ្យរក្សាទុកលោក នួន ជា នៅក្នុងបន្ទប់ដែលបានរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់តាមដាន និងចូលរួមកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍ ដោយឡែកបង្គាប់ឲ្យនាំខ្លួនលោក ខៀវ សំផន មកកាន់បន្ទប់សវនាការនេះវិញនៅរសៀលនេះ មុនម៉ោងមួយសាមសិបនាទីរសៀល។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៤ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:១៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងសូមប្រគល់វេទិកាជូនទៅ

ក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញ!

**លោក ម៉ៃខល កាណាវាស៖**

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម។ ជម្រាបសួរលោកសាក្សី និងសាធារណជនទាំងក្នុង ទាំងក្រៅបន្ទប់សវនាការ។

[១៣:៣២:០០]

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** លោកសាក្សី មុនថ្ងៃ១៧ មេសា ៧៥ នៅពេលដែលលោករស់នៅក្នុងព្រៃជាមួយនឹងពូរបស់លោកគឺ ប៉ុល ពត។ ព្រឹកមិញនេះ គឺថាលោកបាននិយាយថា លោកបានចាក់ថ្នាំឲ្យគាត់។ លោកអាចប្រាប់ខ្ញុំបានទេ ថានៅពេលដែលលោកចាក់ថ្នាំឲ្យគាត់ហ្នឹង លោកចាក់ថ្នាំហ្នឹង ដោយមានតែលោកម្នាក់ឯង ឬក៏មានអ្នកដទៃនៅជាមួយនឹងលោកដែរ?

**លោក សាឡុត បាន៖**

**ឆ៖** ពេលខ្ញុំចាក់ថ្នាំ គឺខ្ញុំនៅម្នាក់ឯងជាមួយលោក។

**ស៖** ដូច្នេះ មានតែរូបលោក ហើយនិងពូរបស់លោក គឺ ប៉ុល ពត នៅពេលដែលលោកចាក់ថ្នាំឲ្យគាត់នោះ អ៊ីចឹងមែនទេ?

[១៣:៣៣:១៥]

**ឆ៖** បាទ ប៉ុន្តែខ្ញុំ មានពេលខ្លះ គ្រួសារគាត់ក៏នៅក្បែរដែរ។

**ស៖** ហើយនៅក្នុងឱកាសទាំងនោះ នៅក្នុងឱកាសដែលមានតែលោក ហើយនិង ប៉ុល ពត។ តើលោកមានការសន្ទនាគ្នាតិចតួចណាមួយ ការនិយាយគ្នាតិចតួចណាមួយដែរទេ?

**ឆ៖** ការសន្ទនាមានតិចតួច។ ដូចជាលោកថា ប្រាប់គ្រួសារឯង ឲ្យធ្វើសម្លនេះ សម្លនោះ ហើយកុំឲ្យប្រៃពេក កុំឲ្យដាក់ប៊ីចេងច្រើនពេក។ មានតែប៉ុណ្ណឹងទេ។

**ស៖** តើគាត់អត់មានបានប្រាប់លោក ថាមានអ្វីកើតឡើងនៅខាងក្រៅ ឬក៏-- តើគាត់មានដែលនិយាយអ៊ីចឹងទេ ថាមានរឿងរ៉ាវអីកើតខាងក្រៅ យ៉ាងណាយ៉ាងណីជាមួយនឹងលោក អ៊ីចឹងទេ?

**ឆ៖** អត់ដែលមានទាល់តែសោះ។

[១៣:៣៤:៥៧]

**ស៖** មុននឹងភ្នំពេញដួលរលំទៅ លោកបាននិយាយថា នៅក្នុងកិច្ចប្រជុំមួយ គឺជាការជួបជុំគ្នាក្នុងសមាជិកគ្រួសារគឺលោកអំពីការប្រមូលគ្រាប់ គឺនៅកំពង់ស្ពឺ។ តើលោកមានចាំទេ លោកមាននិយាយជាមួយគាត់ពីរឿងការប្រមូលគ្រាប់?

**ឆ៖** ខ្ញុំមានភារកិច្ចដែលលោក ប៉ុល ពត ប្រគល់ឲ្យខ្ញុំ គឺថាឲ្យខ្ញុំជួយមើលទុកដាក់គ្រាប់ឲ្យស្រួលផង ធ្វើបញ្ជីចេញចូលឲ្យបានស្រួលផង។ គាត់ផ្ដែផ្ដាំខ្ញុំអ៊ីចឹង។ ដូច្នេះខ្ញុំបំពេញភារកិច្ចនេះតាមដែលគាត់ត្រូវឲ្យធ្វើតែប៉ុណ្ណោះ។

[១៣:៣៦:០៧]

**ស៖** ចុះ ប៉ង់ វិញ តើ ប៉ង់ ពាក់ព័ន្ធក្នុងរឿងនេះដែរ ឬ ប៉ុល ពត ណែនាំទៅលោកផ្ទាល់តែម្ដង ឬក៏មានៗ ប៉ង់ ចូលរួមដែរ?

**ឆ៖** មន្ទីរនោះ ប៉ង់ អត់នៅជាមួយខ្ញុំទេ ប៉ង់នៅឯខាងៗកើតទន្លេៗសាបឯណោះទេ ខ្ញុំនៅខាងលិចទន្លេសាប។

**ស៖** តើមានគ្រាប់រំសេវប្រហែលប៉ុន្មានដែរ ដែលលោកកំពុងនិយាយនេះ? ពេលនោះមានបរិមាណគ្រាប់រំសេវប្រហែលប៉ុន្មានដែរ?

**ឆ៖** តាមខ្ញុំចាំ ប្រហែលជាពីរ ឬបីតោនប៉ុណ្ណោះបាទ។

**ស៖** ហើយ-- ក្រោយមកថាតើមានគ្រាប់ច្រើនដែរឬទេ លោកអាចគិតអំពីចំនួនបានទេ ពីបរិមាណប្រាប់ខ្ញុំបានទេ?

**ឆ៖** ដូចមិនមានបរិមាណអីលើសហ្នឹងទេ។ យកទៅចេះតែអស់ទៅៗ រហូតដល់ភ្នំពេញបែកតែម្ដង។

[១៣:៣៨:០២]

**ស៖** ហើយបើតាមខ្ញុំសក្ខីកម្មពីម្សិលមិញនោះ គឺថាលោកនៅរក្សាទុកនូវគ្រាប់រំសេវ និងបន្ទាប់ពី ប៉ុល ពត គាត់យកលោកមកតែការពារ យាមកាមគ្រាប់រំសេវហ្នឹង បន្ទាប់ពី ប៉ុល ពត ចាកចេញទៅ។ តើត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** លោកដឹងទេថា ហេតុអ្វីបានជា ប៉ុល ពត ជ្រើសរើសរូបលោក ឲ្យលោកធ្វើការយាមកាមគ្រាប់រំសេវទាំងនេះ?

**ឆ៖** ខ្ញុំមិនដឹងមូលហេតុអីដែរ ប៉ុន្តែពេលនោះគ្រួសារខ្ញុំមានផ្ទៃពោះ។ ប្រហែលជាគាត់ឲ្យខ្ញុំនៅហ្នឹងដើម្បីរក្សាគ្រួសារខ្ញុំដែរក៏មិនដឹង។

**ស៖** តើគ្រាប់រំសេវទាំងនេះវាមានសារៈសំខាន់ ម៉េចក៏មិនជ្រើសរើសអ្នកណាម្នាក់ដែលទុកចិត្តឲ្យយាមកាមគ្រាប់រំសេវទាំងនុ៎ង?

**ឆ៖** សារៈសំខាន់គ្រាន់រំសេវនេះ ខ្ញុំពិនិត្យមើលទៅឃើញថា វាមានសារៈសំខាន់ដែរ ហើយសារៈសំខាន់មួយទៀត ដូចខ្ញុំបានជម្រាបអំមិញអ៊ីចឹង ខ្ញុំក៏ជាសេចក្ដីទុកចិត្តរបស់គាត់ដែរ។ ទីបីទៀត ក៏ខ្ញុំមានគ្រួសារដែលមានផ្ទៃពោះនៅទីនោះ។

[១៣:៤០:០៣]

**ស៖** ចុះ ជាម តើគាត់នៅជាមួយលោកដែរ ឬគាត់នៅជាមួយ ប៉ង់ ឯណោះទៅវិញ?

**ឆ៖** តាមខ្ញុំចាំ ជាម នៅឯខាងលិចទន្លេ-- អ៊ូ! ខាងកើតទន្លេ។

**ស៖** តើលោកដឹងថា គាត់នៅជាមួយ ប៉ង់ គាត់ជាកូនចៅរបស់ ប៉ង់ ឬក៏គាត់នៅជាមួយអ្នកណាផ្សេង តើលោកនៅនឹកឃើញទេ លោកចាំទេ?

**ឆ៖** គឺនៅជាមួយ ប៉ង់ ហ្នឹងហើយ ពីព្រោះមន្ទីរអស់នេះ គឺ ប៉ង់ គ្រប់គ្រងនៅខាងកើត នៅខាងកើតទន្លេនុ៎ង។

[១៣:៤១:០៨]

**ស៖** កាលពីព្រឹកមិញ លោកបានប្រាប់ថា ប៉ង់ នេះ តាមពិតទៅ ប៉ង់ នេះគឺជិតស្និទ្ធជាមួយនឹង ប៉ុល ពត ដែលជាឰូរបស់លោកជាងរូបលោក។ លោកដឹងទេថា អ្នកណាចាត់តាំង ប៉ង់ ហ្នឹងឲ្យទៅខាងទិសខាងកើតហ្នឹងនៅពេលនុ៎ង?

**ឆ៖** បញ្ហានេះ ខ្ញុំអត់បានដឹងទេ។

**ស៖** មុនពេល ប៉ង់ ចាកចេញទៅទិសខាងកើត តើលោកអាចសន្និដ្ឋានទេ យោងតាមអ្វីដែលលោកបានលើកឡើងពីព្រឹកមិញ ថាមេរបស់លោកផ្ទាល់នោះ គឺ ប៉ុល ពត តែម្ដង?

**ឆ៖** សូមបំភ្លឺបញ្ហានេះបន្តិច។ ខ្ទមដែលខ្ញុំនិយាយថា ខ្ញុំនៅនុ៎ង នៅខាងលិចទន្លេសាបហ្នឹងក្រាំងបេង ក្រាំងដូងអីហ្នឹង។ ប៉ង់ មិនមាននៅទេ ប៉ង់ អត់មាននៅនុ៎ងទេ មានតែខ្ញុំដែលជា គ្រាន់អ្នកដែលអ្នកគ្រប់គ្រងបន្ទាប់ពី ប៉ុល ពត មកនោះ។ ដូច្នេះ ប៉ង់ អត់មានចេញចូលអីពីខាងលិចទន្លេ ទៅខាងកើតទន្លេទេ ប៉ង់នៅតែប្រចាំនៅខាងកើតទន្លេតែរហូត បាទ។

**ស៖** ខ្ញុំសូមបញ្ជាក់ ដើម្បីឲ្យខ្ញុំយល់ឲ្យបានច្បាស់ ដូច្នេះគាត់នៅទិសខាងកើតនៃទន្លេពីឆ្នាំ៦៨, ៦៩ រហូតមកដល់ឆ្នាំ១៩៧៥ តើនេះគឺជាអ្វីដែលលោកកំពុងតែជម្រាបខ្ញុំមែនទេ?

**ឆ៖** បាទ។

[១៣:៤៣:៣៨]

**ស៖** ហើយនៅក្នុងអំឡុងពេលនេះ នៅពេលដែល ប៉ង់ នៅតែមានការណែនាំដល់លោកជាប្រចាំនូវអ្វីដែលត្រូវធ្វើជាប្រចាំថ្ងៃ អ៊ីចឹងទេ?

**ឆ៖** ពេលដែលខ្ញុំបែកពី ប៉ង់ មកគឺខ្ញុំអត់មានអីត្រូវទទួលពី ប៉ង់ ទេ ខ្ញុំទទួលតែពីលោក ប៉ុល ពត។

**ស៖** ប្រហែលជាមានការបាត់បង់ពាក្យពេចន៍អី ដោយសារតែការបកប្រែហើយមើលទៅ។ នៅពេលដែលលោកនៅជាមួយនឹងពូ ប៉ុល ពត។ ព្រឹកមិញលោកបានជម្រាបថា លោកបានទទួលការណែនាំពី ប៉ង់ ដែល ប៉ង់ នេះទទួលការណែនាំ ឬក៏ការបញ្ជាពី ប៉ុល ពត មក។ តើខ្ញុំយល់យ៉ាងដូច្នេះ តើត្រឹមត្រូវទេ?

**ឆ៖** ដូច្នេះ ខ្ញុំឆ្លើយរបៀបអំមិញទៀតបាទ។ ពេលណាដែល ប៉ង់ នៅ-- ខ្ញុំនៅជាមួយ ប៉ង់ គឺខ្ញុំទទួលពី ប៉ង់។ បើ ប៉ង់ មិននៅទេ ខ្ញុំទទួលពី ប៉ុល ពត ផ្ទាល់បាទ។

[១៣:៤៥:១៤]

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំសូមទោសដែលខ្ញុំមានការយល់ច្រឡំមុននេះ។ តាមដែលខ្ញុំយល់ក្រោយពីភ្នំពេញដួលរំលំទៅមួយខែ ឬក៏ប្រហែលនេះ លោកក៏បានចូលមកភ្នំពេញ តើនេះត្រឹមត្រូវទេ?

**ឆ៖** បាទ ប្រហែលជាមួយខែទៅពីរខែ រហូតដល់គ្រួសារខ្ញុំរឹងដៃរឹងជើងកូនហើយ បានខ្ញុំចូលមកភ្នំពេញជាមួយគ្រួសារខ្ញុំ។

**ស៖** នៅពេលដែលលោកចាកចេញពីទីកន្លែងដែលលោកឃោមកាមគ្រាប់រំសេវនោះ តើលោកមានទទួលការណែនាំផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរពីអ្នកណាម្នាក់ដើម្បីឲ្យលោកចាកចេញពីទីកន្លែងនោះមកកាន់ភ្នំពេញដែរឬទេ?

**ឆ៖** តាមខ្ញុំចាំពេលនោះ លោកបានណែនាំ មុននឹងលោកទៅ លោកបានណែនាំថាប្រគល់ឲ្យទៅតំបន់វិញហើយ។

**ស៖** ពេលណាលោកនិយាយថាគាត់ៗហ្នឹងជាអ្នកណា? គាត់ហ្នឹងជាពូ ប៉ុល ពត ហ្នឹងឯង ឬជាអ្នកណា?

**ឆ៖** បាទ គឺលោក ប៉ុល ពត។

**ស៖** ហើយនៅពេលដែលលោកចូលមកភ្នំពេញ នៅពេលដែលលោកចូលមកដល់ភ្នំពេញភ្លាម តើលោករាយការណ៍ទៅអ្នកណា? បើសិនណាមានអ្នកណាម្នាក់លោកត្រូវរាយការណ៍ ថាតើលោករាយការណ៍ទៅអ្នកណា?

**ឆ៖** ពេលដែលចូលមកភ្នំពេញ លោក ប៉ង់ មកជួប អត់មានរាយការណ៍ទៅពីណាទេ លោក ប៉ង់ មកជួបថាឲ្យនៅកន្លែងនេះ កន្លែងនោះអ៊ីចឹង។

**ស៖** ហើយថាតើ ប៉ង់ ដឹងថាមកជួបលោកនៅកន្លែងណា? ដោយរបៀបណា? ហើយនិងថាតើគាត់ជួបលោកនៅកន្លែងណា?

[១៣:៤៨:០៤]

**ឆ៖** ប៉ង់ ប្រាប់ថាឲ្យខ្ញុំរស់នៅកន្លែងក្រសួងការបរទេសហ្នឹង គឺខាងលិចៗក្រសួងការបរទេសទីស្តីការៗនាយករដ្ឋមន្ត្រីសព្វថ្ងៃ។

**ស៖** ខ្ញុំសូមសួរសំណួរនេះឡើងវិញ។ លោកបាននិយាយថានៅពេលលោកចូលមកភ្នំពេញ ប៉ង់ មកជួបលោក។ ភ្នំពេញកាលនោះ គឺថាដូចសព្វថ្ងៃដែរ ជាទីក្រុងមួយធំដែរ។ តើ ប៉ង់ ដឹងថាមកជួបលោកដោយរបៀបណា? ហើយត្រូវណែនាំលោកដោយរបៀបណា?

**ឆ៖** ខ្ញុំមិនដឹង ប៉ង់ មករបៀបណាទេ ប៉ុន្តែខ្ញុំចូលទៅ ចូលទៅជាមួយគេជាមួយឯងអ៊ីចឹងទៅកាលណោះដូចជាមាននីរសារមកប្រាប់។ មាននីរសារមកប្រាប់ថា បើចូលទៅ ៗភ្នំពេញនៅក្រសួងការពារជាតិ។ ដល់ទៅក្រសួងការពារជាតិទៅ មានគេអ្នកមកមុននោះ គេនៅនុ៎ង គេបបួលខ្ញុំ ណ៎ាគេបបួលខ្ញុំឲ្យនៅត្រង់ហ្នឹងសិនទៅ បាន ប៉ង់ មកប្រាប់ ថាអ្នកឯងនៅត្រង់ហ្នឹងហើយ។

[១៣:៤៩:៥៨]

**ស៖** ហើយលោកបានជម្រាបមកយើងថា លោកធ្វើការឲ្យក្រសួងការពារជាតិមួយខែ ឬក៏ពីរខែ គឺលោកបោសសម្អាតអគារចាប់ពីថ្ងៃដំបូងមក តើនេះត្រឹមត្រូវទេ?

**ឆ៖** បាទនៅពេលនោះ កន្លែងខ្ញុំដែលគេឲ្យនៅក៏បោស កន្លែងដែលក្បែរៗនុំងក៏បោសសម្អាតទាំងអស់គ្នា។

**ស៖** តើអ្នកណាផ្តល់សេចក្តីណែនាំដល់លោក ដើម្បីឲ្យលោកមានការរវល់បោសសម្អាតអីយ៉ាងដូច្នេះ?

**ឆ៖** គឺលោក ប៉ង់ ដដែល ដែលណែនាំខ្ញុំ។

**ស៖** ហើយនៅពេលដែលលោកចេញពីក្រសួងការពារជាតិទៅ តើអ្នកណាដែលមកជួបលោក មកប្រាប់លោកឲ្យចេញពីត្រង់ហ្នឹង ហើយប្រាប់លោកឲ្យទៅទីណានោះ?

**ឆ៖** លោក ប៉ង់ ឲ្យខ្ញុំរៀបចំបោសសម្អាត ហើយពេលនោះមិនទាន់-- បង អៀង សារី មិនទាន់មកទេ មានតែលោក ប៉ង់ មកប្រាប់ខ្ញុំឲ្យបោសសម្អាតទាំងអស់ គ្រប់កន្លែងទាំងអស់បាទ។

[១៣:៥០:៥០]

**ស៖** លោកបានជម្រាបមកយើងខ្ញុំថា ប្រពន្ធរបស់លោកគឺជាអ្នកដាំស្លនៅ ក-១ ត្រឹមត្រូវទេ? ហើយលោកនិយាយថា អ្នកណា អ្នកផ្តល់ការងារហ្នឹងឲ្យភរិយាលោកហ្នឹង នៅក-១ ហ្នឹង?

**ឆ៖** ក៏លោកប៉ង់ ដែរ។

**ស៖** យើងនឹងនិយាយរឿងនេះច្រើនជាងនេះទៅទៀត ប៉ុន្តែលោកនិយាយថាលោកក៏មានបងប្អូនប្រុសម្នាក់ដែលធ្វើជាទាហានវាយប្រយុទ្ធជាមួយនឹងវៀតណាម ប្រហែលជាចាប់តាំងពីឆ្នាំ១៩៧០ ហើយថ្ងៃនេះទើបយើងដឹងថា លោកប្រាប់ថា គាត់ជាអ្នកថតរូប។ អ្នកណាជាអ្នកឲ្យការងារហ្នឹងទៅឲ្យប្អូនរបស់លោកនៅ ក-១ ហ្នឹង?

**ឆ៖** ខ្ញុំស្តាប់បានអំមិញថាបងប្រុស ប៉ុន្តែមិនមែនទេ ប្អូនប្រុសបាទ។ អ៊ីចឹងទេ?

**ស៖** បាទ អភ័យទោសគឺប្អូនប្រុសរបស់លោក។ អ្នកណាប្រគល់ការងារហ្នឹងឲ្យប្អូនប្រុសរបស់លោក លោកនឹកឃើញទេ? លោកចាំទេ?

[១៣:៥៣:៤៤]

**ឆ៖** ក្រោយមកទេ ខ្ញុំសួរប្អូនខ្ញុំ គឺពូ ប៉ុល ពត គាត់ឲ្យប្អូនខ្ញុំធ្វើការងារថតរូប។

**ស៖** តើលើកទីមួយនោះ ដែលលោកបានមកជួបជាមួយនឹងពូ ប៉ុល ពត បន្ទាប់-- ក្រោយពីគាត់ៗចូលមកភ្នំពេញ-- នៅពេលដែលគិតចាប់តាំងពីពេលដែល លោកនៅយាមកាមនៅឃ្លាំងអាវុធនោះ?

**ឆ៖** សូមជម្រាបអំពីប្អូនដែលថតរូប នៅព្រៃក៏មានថតរូបដែរ ប៉ុន្តែមានអង្គភាពផ្សេង ប្អូនខ្ញុំអត់ថតរូបទេ។ ប្អូនខ្ញុំនេះ ខ្ញុំនិយាយប្រវត្តិប្អូនបន្តិចបានៗយល់បាទ ប្អូនខ្ញុំនេះមិនទាន់ជួបខ្ញុំទេ គេនៅក្នុងជួរកងទ័ពវៀតណាម ដែលចាត់តាំង។ ដល់ទៅរកឃើញហើយ បានយកប្អូនខ្ញុំមក យកប្អូនខ្ញុំមក ៗនៅ

ក្នុងមន្ទីរ។ នៅក្នុងមន្ទីរនេះ រំដោះហើយនេះ បានយកប្អូនខ្ញុំនេះទៅប្រើប្រាស់ថតរូប។

**ស៖** ប្រហែលជាខ្ញុំសួរលម្អិតពីចំណុចនេះថែមទៀត ដើម្បីឲ្យខ្ញុំបានយល់ឲ្យបានច្បាស់។ លោកដឹងថា ប្អូនរបស់លោកគឺថា នៅជាមួយកងទ័ពវៀតណាមហើយ ក្រោយមកគឺថាលោកនាំប្អូនរបស់លោកឲ្យមកនៅជាមួយនឹងពូរបស់លោកគឺ ប៉ុល ពត នេះឯង។ តើអ៊ីចឹងមែនទេ?

[១៣:៥៦:០១]

**ឆ៖** មិនមែនខ្ញុំនាំទេ ស្រាវជ្រាវ ការស្រាវជ្រាវទៅ ខាង៣០៤ ខាងលោក កុយ ធួន ឃើញថាប្អូនខ្ញុំនៅកងទ័ពវៀតណាម។ ដូច្នេះហើយពេលនោះ គេសុំខ្មែរដែលនៅក្នុងកងទ័ពវៀតណាម ខាងលើណា សុំណា ឲ្យមកនៅក្នុងជួរកងទ័ពតស៊ូយើងវិញ។

**ស៖** តាមដែលខ្ញុំយល់ពីចម្លើយមុនៗរបស់លោកនោះគឺថា គាត់មកកាន់កន្លែងដែលលោកធ្វើការ។ ដូច្នេះ យើងអាចសន្និដ្ឋានបានទេ តាមចម្លើយរបស់លោកថា ប្អូនប្រុសរបស់លោកនៅជាមួយលោក នៅពេលដែលលោកនៅជាមួយនឹង ប៉ុល ពត?

**ឆ៖** បាទ នៅមែន។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្វាឯល៖**

លោកប្រធាន។ ខ្ញុំគិតថា មានសំណួរជាច្រើន ដែលថាមិនបានបញ្ជាក់អំពីពេលវេលា ឬក៏ទីកន្លែង ហើយអាសំណួរចុងក្រោយនេះក៏អ៊ីចឹងដែរ។ លោក កាណាវាស គាត់មិនបានបញ្ជាក់ថា តើប្អូនរបស់គាត់ជួបគាត់នៅកន្លែងណា? ពេលណា? ដូច្នេះ សាក្សីមិនអាចឆ្លើយឲ្យបានច្បាស់ទេ ពីព្រោះថាសំណួរទាំងអស់នេះ ដូចជាមិនច្បាស់លាស់សោះ។

សូមអរគុណលោកប្រធាន។

ខ្ញុំគិតថា សាក្សីបានឆ្លើយហើយ ក៏ប៉ុន្តែខ្ញុំអត់បានឮការបកប្រែទេ។ សូមអរគុណ។

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធានខ្ញុំគិតថា ខ្ញុំច្បាស់ហើយ ច្បាស់ណាស់ហើយតាមរយៈចម្លើយ ប៉ុន្តែខ្ញុំនឹងព្យាយាមសួរតាំងសំណួរឲ្យបានជាក់លាក់ តាមសំណើរបស់សហព្រះរាជអាជ្ញា។

[១៣:៥៨:០៧]

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ឥឡូវនេះយើងត្រឡប់ទៅពេលដែលលោកចូលភ្នំពេញ ក្រោយពីការដួលរលំភ្នំពេញនៅឆ្នាំ ១៩៧៥ លោកបានជម្រាបថា លោកបានទៅនៅក្រសួងការពារជាតិ។ ឥឡូវនេះ សំណួររបស់ខ្ញុំគឺថា តើលើកទីមួយ ដែលលោកបានជួបជាមួយនឹងពូរបស់លោក ប៉ុល ពត ក្រោយពីលោកចូលមកដល់ភ្នំពេញ ថាតើលោកជួបគាត់ជាលើកដំបូងនៅពេលណា?

**លោក សាឡុត បាន៖**

**ឆ៖** ខ្ញុំសូមបញ្ជាក់។ ខ្ញុំមិនមែននៅក្រសួងការពារជាតិទេ ខ្ញុំទៅបោសសំរាម នៅក្រសួងការពារជាតិបាទ។ ខ្ញុំជួបលោក ប៉ុល ពត នៅពេលដែលគាត់រៀបចំនៅមន្ទីរ ក-១ ហើយ។

**ស៖** តើលោកអាចចាំខែទេ នៅក្នុងឆ្នាំ១៩៧៥ហ្នឹង ក្នុងខែណា?

**ឆ៖** សូមទោសៗ បាទ។ មើល! ខ្ញុំជួបមុនដំបូងនៅព្រះកែវ នៅព្រះកែវមរកតបាទ។ នៅព្រះវិហារព្រះកែវមរកត។

[១៤:០០:១០]

**ស៖** និយាយអំពីអំឡុងពេលម្តងលោក អំឡុងពេលណា ប្រហែលជាលោកដឹងបានច្បាស់ ដើម្បីឲ្យខ្ញុំយល់បានច្បាស់ អំឡុងពេលណាដែរ?

**ឆ៖** ប្រហែលជាខ្ញុំមកដល់ហើយ គឺនៅក្នុងខែមើល៍ ១០ មេសា ក្នុងខែឧសភា អីហ្នឹងបាទ។

**ស៖** ក្រោយពីជួបលើកដំបូងនោះ ខ្ញុំសូមសួរអ៊ីចេះវិញ នៅពេលជួបនោះ ជួបក្នុងពេលណាដែរ? ក្នុងឱកាសអ្វីដែលលោកបានជួបឪពុកមារបស់លោកជាលើកដំបូងនោះ ក្នុងឱកាសអ្វីដែរ?

**ឆ៖** តាមខ្ញុំចាំ គឺឱកាសដែលកម្ម-- ដូចជាប្រជុំមួយ ខ្ញុំក៏មិនដឹងថាប្រជុំហ្នឹង ប្រជុំអីដែរ។ មានការប្រជុំមួយ នៅកន្លែងព្រះវិហារព្រះកែវនោះ។

**ស៖** តើលោកនៅពេលនោះ បាននិយាយជាមួយនឹងឪពុកមារបស់លោកដែរឬទេ? នៅពេលដែលលោកជួបគាត់ជាលើកដំបូងក្នុងពេលនោះ ក្នុងពេលដែលមកដល់ភ្នំពេញនោះ?

**ឆ៖** បាទ ខ្ញុំអត់មាននិយាយអីផ្ទាល់ជាមួយលោកទេ គឺភារកិច្ចការពារនិងដាំបាយតែប៉ុណ្ណោះ។

[១៤:០២:១៦]

**ស៖** នៅពេលដែលលោកនិយាយអំពីបញ្ហាសន្តិសុខ តើអ្នកណាគេចាត់តាំងលោកឲ្យធ្វើការងារសន្តិសុខនោះ? តើអ្នកណាគេជាមេផ្ទាល់របស់លោក នៅពេលនោះ?

**ឆ៖** ទាំងអស់នេះ គឺនៅក្រោម ប៉ង់ ទាំងអស់។

**ស៖** ថាតើមុនពេលដែលលោកទៅក្រសួងការបរទេស ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ មុនពេលទៅក្រសួងការបរទេស។

**ស៖** តើ ជាម ក៏នៅទីនោះដែរ ឬក៏យ៉ាងម៉េច? តើលោកចាំបានទេ?

**ឆ៖** បាទ ជាម នៅទីនោះដែរ។

**ស៖** នៅពេលដែលលោកនិយាយថា "យើង" នោះ តើ ជាម ហ្នឹង ក៏ធ្វើការលើការងារសន្តិសុខ ការពារទៅដល់ឪពុកមារបស់លោក ប៉ុល ពត ដែរ ឬក៏យ៉ាងម៉េច?

**ឆ៖** មិនមែនជាការងារផ្ទាល់របស់ ប៉ុល ពត ទេ គឺជាការងារផ្ទាល់របស់រួមទាំងអស់។ អ្នកការពារផ្ទាល់ មានម្នាក់ទៀត ឈ្មោះ ហួន។ ឥឡូវគាត់ស្លាប់ហើយ។

[១៤:០៤:២៣]

**ស៖** សូមអរគុណ។ តើ ហួន នេះ នៅពីលើ ប៉ង់ ឬក៏ជាកូនចៅរបស់ ប៉ង់?

**ឆ៖** ហួន នេះនៅពីក្រោម ប៉ង់។

**ស៖** តើ ប៉ង់ នៅទីនោះដែរនៅពេលនោះដែរ ដើម្បីធ្វើការត្រួតពិនិត្យបញ្ហាសន្តិសុខដែរ សម្រាប់ឱ្យលោក ប៉ុល ពត ឬក៏យ៉ាងម៉េច?

[១៤:០៥:០០]

**ឆ៖** ប៉ង់ នៅទីនោះទទួលខុសត្រូវសន្តិសុខរួម។

**ស៖** នៅពេលនោះយើងនិយាយអំពីឆ្នាំ៧៥ ពេលដែលបែកភ្នំពេញ ដែលលោកធ្វើការការពារសន្តិសុខ។ ថាតើនរណាគេជាមេផ្ទាល់របស់ ប៉ង់?

**ឆ៖** ខ្ញុំមិនបានច្បាស់លាស់ថានរណាជាមេផ្ទាល់របស់ ប៉ង់ ទេ ឃើញតែ ប៉ង់ ហ្នឹងមេខ្ញុំ។

**ស៖** ថាតើ ប៉ង់ នេះកៀកជិតស្និទ្ធនឹង ប៉ុល ពត ទៅកម្រិតត្រឹមណាដែរ នៅពេលនោះ?

**ឆ៖** ដូចខ្ញុំបាននិយាយពីមុនអ៊ីចឹង មានការអីដែលត្រូវការធ្វើជា បើកវគ្គ បើកសាលា ប្រជុំអីៗ ហ្នឹង គឺហៅ ប៉ង់ ទៅនិយាយបាទ។

[១៤:០៦:២៧]

**ស៖** តាមអ្វីដែលលោកដឹង តើ ប៉ង់ មានទទួលការណែនាំពី ប៉ុល ពត ដែរឬទេ ឬក៏មានអ្នកផ្សេងពាំនាំការណែនាំនោះមកដល់ ប៉ង់? ខ្ញុំសួរតែអ្វីដែលលោកដឹងទេ តើលោកដឹងទេ?

**ឆ៖** បាទ បើគាត់ណែនាំ ប៉ង់ ហើយ ខ្ញុំមិនឃើញនរណាមកណែនាំទៀតទេបាទ។

**ស៖** តើ ប៉ង់ នៅក្នុងពេលនោះ-- តើ ប៉ង់ នៅជាមួយនឹង ប៉ុល ពត រយៈពេលប៉ុន្មានដែរនៅពេលនោះ តាមអ្វីដែលលោកដឹង?

**ឆ៖** ខ្ញុំចាំអត់បានទេលោក។

**ស៖** បានន័យថា មុនពេលដែលលោកទៅដល់ព្រៃក្នុងឆ្នាំ៦៨, ៦៩ ឬក៏ពេលណាដែរ? រយៈពេលប៉ុន្មានដែរ?

**ឆ៖** ខ្ញុំអត់យល់សំណួរហ្នឹងទេលោក។

**លោក ម៉ៃខល កាណាវាស៖**

[១៤:០៨:០៨]

*(មានបញ្ហាបច្ចេកទេសសំឡេង)*

**ប្រធានអង្គជំនុំ៖**

*(មានបញ្ហាបច្ចេកទេសសំឡេង)*

**លោក ម៉ៃខល កាណាវាស៖**

*(មានបញ្ហាបច្ចេកទេសសំឡេង)*

[១៤:០៨:៥៤]

**លោក សាឡុត បាន៖**

សួរអត់ស្ដាប់បាន។ ពេលវេលាអីៗ អត់ដឹងជួបពេលណា យើងមិនដឹង។

[១៤:១០:០០]

*(មានបញ្ហាបច្ចេកទេសសំឡេង)*

[១៤:១២:៣៣]

**ប្រធានអង្គជំនុំ៖**

បាទ ទំនងចាប់ផ្ដើមបានទេ?

ហើយអ្នកបកប្រែអាចស្ដាប់ឮទេ?

**អ្នកបកប្រែ៖**

បាទ អ្នកបកប្រែទទួលសម្លេងបានលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកមេធាវី!

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** សូមអរគុណលោកប្រធាន។ លោកសាក្សី មកត្រឹមឆ្នាំ១៩៧៥ តើលោកបានដឹងដែរ ឬទេថា ប៉ង់ នៅជាមួយនឹងឪពុកមារបស់លោករយៈពេលប៉ុន្មានឆ្នាំដែរ?

**លោក សាឡុត បាន៖**

**ឆ៖** ប៉ង់ នៅជាមួយឪពុកមាខ្ញុំរហូតដល់ ប៉ង់ បាត់ខ្លួន។

**ស៖** តើ ប៉ង់ នេះប្រភពដើមរបស់គាត់ហ្នឹង មកពីណាដែរ?

**ឆ៖** ខ្ញុំ និយាយដោយស្មោះ ដើម្បីជាពន្លឺដល់តុលាការ ខ្ញុំជួប ប៉ង់ ប្រហែលជាឆ្នាំ១៩៦៦-៦៧ កាលនោះមានចលនាតស៊ូ គេនាំខ្ញុំទៅដុតពោតនៅ-- គេហៅថាជំនាន់នុ៎ង វាហៅថា បឹងទំពុន។ ជំនាន់នុ៎ងវាដីគោកៗ គេធ្វើពោត ឥឡូវនេះធ្វើផ្ទះអស់ហើយ។ ស្រាប់តែឃើញ ប៉ង់ នៅផ្ទះនោះ។ ផ្ទះហ្នឹងគេធ្វើជាស្ថានអ៊ីចឹងទៅ ខាងក្រោមហ្នឹងគេដាំ ដាំនែ៎! ដាំត្រកួន, ដាំ*ក្រេសស៊ុង,* ដាំអីហ្នឹងបាទ។ ដល់ដីគោក គេធ្វើពោត។ ទៅគេហៅថាទៅលេងអីដើរដុតពោតដុតអីអ៊ីចឹង ឃើញ ប៉ង់ នៅទីនោះ។

[១៤:១៥:២៣]

នៅទីនោះ ខ្ញុំឃើញឈ្មោះ ជូ ជេត ខ្ញុំទើបតែស្គាល់ ដល់ក្រោយមក ខ្ញុំស្គាល់ថា អ្ហូ! នេះហើយតើ ជូ ជេត ណ៎ា។ ដល់ទៅឃើញបដិវត្តន៍ឈ្មោះ ជូ ជេត ហ្នឹង ឃើញ ជូ ជេត ហ្នឹងបាទ។ ដល់ខ្ញុំមើលកាសែតប្រជាជនទៅឃើញថា ជូ ជេត ហ្នឹងជាចាងហ្វាងកាសែតប្រជាជនពីដើមនុ៎ង រូបនង្គ័ល។ បាទ នេះខ្ញុំស្គាល់ទីមួយ។ ស្គាល់ទីមួយណ៎ា។ បាទ ស្គាល់ទីពីរ ពេលចលនាបដិវត្តន៍ ប្រឆាំងនឹងចក្រពត្តិអាមេរិកាំង។ ខ្ញុំក៏ចូលចលនានោះដែរ។ ខ្ញុំទៅប្រជុំនឹងសាលាសន្ធរម៉ុក។ ដល់ប្រជុំសាលាសន្ធរម៉ុក ឃើញ ប៉ង់ នៅនុ៎ងដែរ។ មិនស្គាល់ឈ្មោះ ប៉ង់ ទេ ហើយមិនស្គាល់ឈ្មោះគេពិតទៀត ឃើញមុខហ្នឹង បានទៅស្គាល់គ្នាក្នុងព្រៃណោះបាទ។ ដល់អ៊ីចឹងទៅ គាត់ឃើញមុខនៅក្នុងការប្រជុំ នៅក្នុងសាលាអនុវិទ្យាល័យ ក្រោមពេទ្យចិនអំមិញ ខ្ញុំថាអំមិញ? វិទ្យាល័យក្រោមពេទ្យចិនពីដើមលោក នែ៎ សាលាវិទ្យាល័យ ក្រោមពេទ្យចិនហ្នឹង ឃើញនៅនុ៎ងបាទ ភ្លេចឈ្មោះវិទ្យាល័យនុ៎ង។ ឃើញ ប៉ង់ ហ្នឹងចូលប្រជុំ។ ប៉ុន្តែលោក ប៉ង់ ហ្នឹងអត់ចូលប្រជុំទេ ថាហ៊ឺខ្ញុំអត់ប្រជុំទេ ខ្ញុំទៅយាម ហើយខ្ញុំហ្នឹងក៏ប្រជុំជាមួយគេទៅ ផែនការបាចខិត្តប័ណ្ណអីម៉េចៗអីៗអ៊ីចឹងទៅ។ នេះជួបទីពីរ។ ដល់ជួបទីបីខ្ញុំទៅជួប ប៉ង់ នៅឆ្នាំ

១៩៧៧-៧៨ នេះរតនគិរី។ នេះប្រវត្តិដែលខ្ញុំជួប ប៉ង់ បាទ។

[១៤:១៨:០០]

**ស៖** ជួបលើកទីបី ខ្ញុំចង់ដឹងឆ្នាំ មិនមែនឆ្នាំ៧៧ គឺ៦៧ ឬក៏៦៨? បានន័យថាលោកជួបគាត់លើកទីបីនៅរតនគិរីនោះ គឺ៦៧ និង៦៨ ត្រឹមត្រូវដែរឬទេ? នៅពេលដែលលោកជួបគាត់នៅក្នុងឆ្នាំនោះហើយ លើកទីបីនោះហើយ ដែលលោកដឹងថាគាត់នៅរាប់អានជិតស្និទ្ធជាមួយនឹងឪពុកមារបស់លោក គឺ ប៉ុល ពត។ តើមែនអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ មែន។

**ស៖** សូមអរគុណ។ ខ្ញុំរំលងកន្លែងនេះបន្តិច នៅក្នុងឆ្នាំ៧៥ ដែលលោកនិយាយថា លោកទៅការពារសន្តិសុខជាមួយនឹង ជាម លោកបានជម្រាបថា ប៉ង់ ទទួលបន្ទុកផ្នែកសន្តិសុខនៅក្នុងកិច្ចប្រជុំមួយជាក់លាក់នៅក្នុងឆ្នាំនោះ។ ដូច្នេះខ្ញុំសូមសួរដូចតទៅ៖

[១៣:១៩:២០]

តើ ប៉ង់ មានទទួលបន្ទុក-- ប្រសិនបើ ប៉ង់ ទទួលបន្ទុកផ្នែកសន្តិសុខសម្រាប់លោក ប៉ុល ពត។ ដូច្នេះតើយើងអាចទាញសេចក្តីសន្និដ្ឋានថា ប៉ង់ ហ្នឹងមានទំនាក់ទំនងយ៉ាងម៉េចជាមួយនឹង ប៉ុល ពត?

**ឆ៖** បាទ ក្នុងន័យនេះ ខ្ញុំសូមបញ្ជាក់ មិនមែនសន្តិសុខរបស់ ប៉ុល ពត ផ្ទាល់ទេ សន្តិសុខរួមរួមក្នុងមន្ទីរ។ នៅកន្លែងណាៗមួយភ្លែតហ្នឹងក៏គេហៅមន្ទីរដែរ ជំនាន់នុ៎ងបាទ។ ឲ្យតែកន្លែងណាមានប្រជុំ គេហៅថាមន្ទីរហើយ បាទ កន្លែងនុ៎ងបាទ។ មិនមែនសន្តិសុខផ្ទាល់របស់ ប៉ុល ពត ទេ គឺសន្តិសុខរួម អាចដើរទៅណាបាន ដូចខ្ញុំបានបញ្ជាក់អ៊ីចឹងបាទ។

**ស៖** សូមអរគុណ។ កាលពីម្សិលមិញ ឬម្សិលម្ង៉ៃលោកបានប្រាប់ថា ក្នុងឱកាសមួយចំនួននៅពេលដែលលោកទៅមន្ទីរក-១ លោកចាំថា លោកបាននិយាយអ៊ីចឹងទេ លោកធ្លាប់ទៅក-១?

**ឆ៖** បាទ ខ្ញុំធ្លាប់បាននិយាយថាទៅ ក-១ ពេលដែលខ្ញុំត្រូវការ ដូចថាមានអីសំខាន់ៗ ដូចជាខាងស្បៀងខាងអីត្រីសាច់អីៗ។ មួយទៀត គ្រួសារខ្ញុំដាំបាយនៅត្រង់នោះ ខ្ញុំបានទៅ។

[១៤:២១:០៧]

**ស៖** នៅពេលដែលលោកទៅមន្ទីរ ក-១ នោះដើម្បីទៅជួបប្រពន្ធតែប៉ុណ្ណោះ ឬក៏លោកទៅទីនោះដោយសារតែមានរឿងរ៉ាវសំខាន់ៗ ដែលលោកចង់ទៅ ទើបលោកទៅ ហើយក្នុងពេលជាមួយគ្នានោះជួបជាមួយនឹងប្រពន្ធរបស់លោកតែម្តង។ តើអ៊ីចឹងដែរឬទេ?

**ធ៖** អត់ទេ។ គឺទៅជារបៀបជាគ្រួសារធម្មតាបាទ។ មិនមែនមានរឿងអីចេះតែទៅទេបាទ។

**ស៖** នៅពេលដែលលោកទៅជួបប្រពន្ធ ទៅជាលក្ខណៈគ្រួសារ តើលោកត្រូវការលិខិតដើរផ្លូវដែរឬទេ? ឬក៏ដោយសារតែលោកជាក្មួយរបស់លោក ប៉ុល ពត គឺលោកទៅទីនោះស្រេចតែនឹងចិត្ត?

**ធ៖** បាទ ខ្ញុំសូមជម្រាបបន្តិច។ កន្លែងដាំបាយនុំងគឺ បរិវេណក្រៅ ១កន្លែង ក-១។ ក-១ ហ្នឹងគឺថាបរិវេណមួយទៅ ប៉ុន្តែជាប់នៅនេះ ជាប់នៅពីក្រោយបន្តិចនេះ គឺបរិវេណដាំបាយ និងគ្រួសារនៅគ្រួសារជាប្រពន្ធខ្ញុំនៅ។ ដូច្នេះ ពេលណាដែលមានត្រូវការចូលក-១ នោះបានមានសំបុត្រ ប៉ុន្តែខ្ញុំអាចសរសេរសំបុត្រឱ្យបុគ្គលិកខ្ញុំចេញចូលបាន ហើយខ្លួនខ្ញុំចូលក-១ មិនមានសំបុត្រស្នាមអីទេ។

**ស៖** *(គ្មានការបកប្រែ)*

**ធ៖** ហើយសូម-- សូមបញ្ជាក់ឱ្យច្បាស់ម្តងទៀត បើទៅលេងគ្រួសារ ខ្ញុំអត់បាច់ឆែកទេ បើមានអីត្រូវការដូចថា បង អៀង សារី ឱ្យខ្ញុំទៅទាក់ទងខាង ក-១ អី យកសំបុត្រយកអីទៅ គេឆែក គេត្រូវឆែកខ្ញុំហើយ។

[១៤:២៤:០១]

**ស៖** សូមអរគុណ។ លោកនិយាយខាងដើមថា លោកសរសេរលិខិត បានន័យថា លោកសរសេរលិខិត ចេញលិខិតដោយខ្លួនឯង ទៅកន្លែងនោះ ដើម្បីទៅកន្លែងនោះ តើលោកមាននិយាយអីចឹងទេ? ខ្ញុំស្តាប់អីចឹងត្រូវដែរឬទេ?

**ធ៖** ខ្ញុំសរសេរលិខិតខ្លួនឯង ឱ្យបុគ្គលិកខ្ញុំទៅបានគេទទួល។ បើខ្ញុំទៅលេងគ្រួសារ ខ្ញុំមិនបាច់សរសេរលិខិតទេ ពីព្រោះអានុំងវាអត់ជាប់នឹងក-១។ បើខ្ញុំទៅ ក-១ ខ្ញុំអត់មានសរសេរលិខិតអីខ្លួនឯងទេ គឺខ្ញុំតែខ្លួនទទេដោយខ្លួនឯង ប៉ុន្តែគេឆែកឆេរខ្ញុំបាទ។ បាទ អស់ហើយប៉ុណ្ណឹង។

[១៤:២៤:៥៦]

**ស៖** សូមអរគុណ។ នៅពេលដែលលោកចូលទៅដល់ ក-១ តើលោកធ្លាប់ចូលរួមប្រជុំ ទាំងប្រជុំផ្លូវការ ឬក៏ប្រជុំក្រៅផ្លូវការរបស់គណៈអចិន្ត្រៃយ៍ដែរឬទេ?

**ធ៖** ចូល ក-១ មានតែសំបុត្រស្នាមតែប៉ុណ្ណោះ ដែលទទួលពីបង អៀង សារី ទៅ។ ហុចទៅឱ្យអ្នកណាហើយ ត្រឡប់មកវិញហើយ អត់មាននិយាយអីទៀតទេ។ អ្នកនៅក្បែរនុំងក៏មិននិយាយដែរ។

**ស៖** សូមអរគុណ។ ក៏ប៉ុន្តែខ្ញុំសួរមួយដំណាក់កាលម្តងៗ ដើម្បីឱ្យខ្ញុំយល់ច្បាស់ត្រង់មួយចំណុចម្តងៗ។ តើលោកធ្លាប់ចូលរួមកិច្ចប្រជុំទាំងឡាយ ដែលរៀបចំឡើងដោយគណៈអចិន្ត្រៃយ៍ដែរឬទេ?

**ឆ៖** ខ្ញុំមិនបានប្រជុំដោយគណៈអចិន្ត្រៃយ៍ទេបាទ។

**ស៖** ចុះការប្រជុំរៀបចំឡើងដោយអង្គការវិញ មិនថាមានអ្នកណាចូលរួមទេ តើលោកធ្លាប់ចូលរួមប្រជុំទាំងអស់នោះដែរឬទេ ប្រជុំរបស់អង្គការ?

**ឆ៖** ពាក្យថា “អង្គការ” ហ្នឹង វាសួរមកខ្ញុំអ៊ីចឹងវាពិបាកឆ្លើយណាស់បាទ។ ពីព្រោះអង្គការខ្ញុំបានជម្រាបពីមុនហើយបាទ អង្គការ គឺមានអង្គការថ្នាក់តូច ពីភូមិ ពីឃុំ ពីស្រុកទៅ ពីពួក ពីអីទៅបាទ។ ខ្ញុំចូលប្រជុំតែត្រឹមថ្នាក់អង្គការតូចតាចតែប៉ុណ្ណោះ។ អង្គការមជ្ឈិម អង្គការអចិន្ត្រៃយ៍ អង្គការភាគ អង្គការអីនេះ ខ្ញុំមិនបានប្រជុំទេ។

**ស៖** តើលោកធ្លាប់ទទួលឯកសារពីគណៈអចិន្ត្រៃយ៍ដែរឬទេ? ឬក៏ពីគណៈមជ្ឈិមដែរឬទេ?

**ឆ៖** ខ្ញុំមិនបានទទួលឯកសារផ្ទាល់ពីគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិមទេបាទ?

[១៤:២៨:១០]

**ស៖** យើងនិយាយអំពីពូរបស់លោកគឺ ប៉ុល ពត នៅពេលដែលលោកនៅក្នុងព្រៃ។ ក្នុងពេលដែលលោក និងឪពុកមារបស់លោកនៅក្នុងទីក្រុងភ្នំពេញ តើឪពុកមារបស់លោក ប៉ុល-- ឪពុកមារបស់លោក គឺ ប៉ុល ពត ហ្នឹងដែលមាននិយាយរឿងរ៉ាវ ពាក់ព័ន្ធនឹងគាត់ប្រាប់ដល់លោកដែរឬទេ?

**ឆ៖** ខ្ញុំមិនច្បាស់ បកប្រែថាព្រៃផង ភ្នំពេញផង ហើយពាក់ព័ន្ធអី ឲ្យខ្ញុំដឹងខ្លះទេ ហ្នឹងខ្ញុំពិបាកពន្យល់ណាស់បាទ។

**ស៖** ខ្ញុំរៀបចំសំណួរឡើងវិញ។ នៅពេលដែលលោក និង ប៉ុល ពក-- ប៉ុល ពត នៅក្នុងទីក្រុងភ្នំពេញចន្លោះឆ្នាំ៧៥ ដល់៧៩។ តើឪពុកមារបស់លោក ដែលធ្លាប់ជជែកពិភាក្សាជាមួយលោក អំពីការងារដែលគាត់កំពុងធ្វើដែរឬទេនាពេលនោះ?

**ឆ៖** ដូចខ្ញុំបានជម្រាបពីព្រឹកមិញ អត់មានទេ។

**ស៖** តើគាត់ដែលប្រាប់លោកជាក់លាក់អំពីតួនាទី និងអំណាចរបស់គាត់ជាអ្វីដែរឬទេ នៅពេលនោះ?

**ឆ៖** ដូចខ្ញុំបានជម្រាបព្រឹកមិញ អត់ទេ។

[១៤:៣០:០០]

**ស៖** តើគាត់ធ្លាប់ប្រាប់-- ថាតើគាត់ធ្វើសេចក្ដីសម្រេចណាខ្លះ? ហើយតើបុគ្គលណាធ្វើសេចក្ដីសម្រេចណាខ្លះដល់លោកដែរឬទេ?

**ឆ៖** អត់មានទេ។

**ស៖** គាត់ដែលធ្លាប់ប្រាប់លោកអំពីដំណើរការដែលគេធ្វើសេចក្ដីសម្រេចនោះ យ៉ាងម៉េចដែរឬទេ? គាត់មានដែលប្រាប់ថា គាត់ជាមួយនឹងសមមិត្តរបស់គាត់នោះ ពិភាក្សា ហើយបន្ទាប់មកចេញសេចក្ដីសម្រេចដោយរបៀបណាដែរឬទេ?

**ឆ៖** បាទ អត់មានទេ។

**ស៖** តើធ្លាប់មានការជជែកជាមួយនឹងលោក និយាយអំពីអង្គការដែរឬទេ? អង្គការ មានន័យយ៉ាងម៉េច? ហើយអ្នកណាគេខ្លះជាអង្គការ តើមានដែលធ្លាប់ជជែកនិយាយចំណុចហ្នឹងដែរឬទេ?

**ឆ៖** បាទ អត់មានទេ។

**ស៖** តើលោកធ្លាប់សួរឪពុកមាររបស់លោក គឺប៉ុល ពត។ លោកធ្លាប់សួរគាត់ថា ប៉ង់ មានតួនាទី និងអំណាចអ្វីដែរឬទេ?

**ឆ៖** អត់ប៊ានទាល់តែសោះ។

[១៤:៣១:៣៧]

**ស៖** ដោយសារតែធ្លាប់ លោកធ្លាប់ស្គាល់ប៉ង់ ជាច្រើនឆ្នាំរួចមកហើយ ថាប៉ង់នេះ ជាមនុស្សចូលចិត្តនិយាយដែរឬទេ? ហើយគាត់ជាមនុស្សចូលចិត្តចែករំលែកព័ត៌មានដែលគាត់ធ្លាប់ទៅចូលរួមប្រជុំដែរឬទេ? ហើយលោកចាំទេ ថាគាត់ធ្លាប់និយាយជជែកជាមួយលោកដែរឬទេ លោក ប៉ង់ ហ្នឹង?

**ឆ៖** ការជជែកជាមួយខ្ញុំ អត់មានទេ។ ភាគច្រើន គាត់ជជែកនៅខាងក្រៅច្រើន ប៉ុន្តែការជជែកមិនដឹងអីទេ។ គាត់ចេញខាងក្រៅ ខ្ញុំនៅតែខាងក្នុងមន្ទីរបាទ។

**ស៖** តើគាត់ធ្លាប់ដែលនិយាយប្រាប់លោកថា គាត់ធ្លាប់បានកត់សម្គាល់ឃើញ ឬក៏គាត់ស្ដាប់ឮនៅក្នុងកិច្ចប្រជុំណាមួយដែរឬទេ?

**ឆ៖** គាត់អត់ដែលបាននិយាយអីប្រាប់ខ្ញុំទេ ពីរឿងកិច្ចប្រជុំអីៗនោះ។ ប៉ុន្តែខ្ញុំចាំ ខ្ញុំចាំរឿងមួយនេះសូមឲ្យច្បាស់ខ្ញុំ ខ្ញុំចាំរឿងមួយ។ ចាំថា ពាក្យថា សួរខ្ញុំ! សួរខ្ញុំថា តើ អៀង ធីរិទ្ធ បង អៀង ធីរិទ្ធ និងបង យុន យ៉ាត ហ្នឹង ម៉េចនឹងគ្នាវី? សួរខ្ញុំអ៊ីចឹង។ ដូចអត់ត្រូវគ្នាទេដឹង សួរអ៊ីចឹង។ ខ្ញុំថា អ្ហែ! អត់ដឹងអីដែរ ខ្ញុំអត់ដឹងទេ ប៉ុន្តែក្នុងហ្នឹង ខ្ញុំលាក់ថា យី! មនុស្សនេះ ដូចជាមិនស្រួលទេនេះ សួរនេះរបៀបម៉េច ចាក់ចុចផ្ទៃក្នុងយ៉ាងម៉េច ខ្ញុំសំងំស្ងៀមទៅ។

[១៤:៣៤:២០]

**សៈ** តើគាត់ដែលប្រាប់លោកថា គាត់ធ្លាប់បានចូលរួមកិច្ចប្រជុំណាមួយរបស់គណៈអចិន្ត្រៃយ៍ដែរឬទេ?

**ធៈ** អត់មានទេ អត់មានដែលឮសួរនិយាយទេបាទ។

**សៈ** តើគាត់ដែលប្រាប់លោកថា គាត់គិតថាអ្នកណា ឬក៏គាត់បានដឹងថា អ្នកណាជាសមាជិករបស់គណៈអចិន្ត្រៃយ៍ដែរឬទេ?

**ធៈ** ខ្ញុំសួរ-- ខ្ញុំស្តាប់សំណួរមិនច្បាស់ តើសួរខ្ញុំ ឬសួរលោក ប៉ង់ ហ្នឹងដែរស្គាល់ ឬខ្ញុំ?

**សៈ** សំណួររបស់ខ្ញុំ គឺថាតើ ប៉ង់ ធ្លាប់ដែលនិយាយជាមួយលោក ឬក៏ថានៅពេលដែលលោកជួបគាត់ គាត់ជួបលោក ថាតើគាត់ធ្លាប់ដែលនិយាយប្រាប់លោក ថាគាត់ធ្លាប់បានចូលរួមប្រជុំក្នុងប្រជុំណាមួយ ដូចរបស់គណៈមជ្ឈិម តើគាត់ធ្លាប់ដែលប្រាប់លោកថាអ៊ីចឹងទេ?

**ធៈ** បាទ អត់មានទេ។

**សៈ** ថាតើគាត់ធ្លាប់ដែលប្រាប់លោក ថាគាត់បានស្គាល់ថា បានស្គាល់យ៉ាងច្បាស់ថា អ្នកណាជាសមាជិកគណៈមជ្ឈិម ឬក៏អ្នកណាជាសមាជិកគណៈអចិន្ត្រៃយ៍ដែរឬទេ? តើមានសមាជិកប៉ុន្មាននាក់នៅក្នុងគណៈកម្មាធិការនីមួយៗនេះ?

**ធៈ** អត់បានប្រាប់ទេ។

[១៤:៣៦:៣០]

**សៈ** តើមានអ្នកណាម្នាក់ផ្សេង-- អ្នកណាផ្សេងទៀតធ្លាប់ប្រាប់លោកទេពេលហ្នឹង ថា សមាជិកគណៈមជ្ឈិមមានអ្នកណាខ្លះ? សមាជិកគណៈអចិន្ត្រៃយ៍មានអ្នកណាខ្លះ? តើលោកអាចនៅនឹកឃើញថាលោកធ្លាប់បានទទួលព័ត៌មានទេ? ហើយរយៈពេលដែលខ្ញុំចង់និយាយសំដៅទៅដល់នេះ គឺខ្ញុំនិយាយសំដៅពីចន្លោះ៧៥ ដល់៧៩។

**ធៈ** បាទ អត់មាននរណាមកនិយាយប្រាប់ជាផ្លូវការទេ ខ្លួនឯងចេះតែស្មានៗទៅទេបាទ។

**សៈ** នៅពេលដែលលោកធ្វើសេចក្តីសន្និដ្ឋានផ្ទាល់ខ្លួន លោកអាចចែករំលែកជាមួយខ្ញុំបានទេ ចែករំលែកអំពីព្រឹត្តិការណ៍ អង្គហេតុ ឬក៏ព្រឹត្តិការណ៍ដែលលោក នាំឲ្យលោកឈានដល់សេចក្តីសន្និដ្ឋានផ្ទាល់ខ្លួននេះ?

**ធៈ** នៅក្នុងព្រៃ ខ្ញុំឃើញលោកពូខ្ញុំ ប៉ុល ពត និងបង នួន ជា នៅជាប់គ្នា។ ខ្ញុំសន្និដ្ឋានថាប្រហែលជាអចិន្ត្រៃយ៍ហើយ។ ក្រៅពីនោះ ខ្ញុំឃើញពេលខ្លះមានប្រជុំ ធំៗ ហើយមើលឃើញតាមគេ

និយាយអីខ្លះអ៊ីចឹងទៅ ក៏ដឹងថា អ៊ូ!ថ្នាក់នេះ ថ្នាក់នោះអី ខ្លះគេនិយាយតៗគ្នាមក បានខ្ញុំដឹងថាប្រហែលហើយអ៊ីចឹង អ៊ីចឹងក៏អ៊ីចឹងទៅចុះ អចិន្ត្រៃយ៍អីអ៊ីចឹងទៅ រហូតដល់គេនិយាយថា ប៉ង់ តិចទៀតចូលគណៈមជ្ឈិមហើយ ក្មេងជាងគេ។ នេះនិយាយពីក្រោមកទេ មិនមែន ប៉ង់ និយាយប្រាប់ខ្ញុំទេ អ្នកពីក្រៅៗ និយាយហ្នឹង គឺអ្នកដែលនៅក្នុងមន្ទីរហ្នឹង អ្នកក្នុងមន្ទីរ ដែលនៅ ក-១ កអីហ្នឹង គេនិយាយមកអ៊ីចឹងទៅ ខ្ញុំសន្និដ្ឋានតាមអ៊ីចឹងទេបាទ។

[១៤:៣៨:៥៥]

**ស៖** តើលោកអាចប្រាប់ឈ្មោះម្នាក់បានទេ យ៉ាងហោចណាស់ថា តើអ្នកណាជាសមាជិករបស់គណៈអចិន្ត្រៃយ៍ដែលចែករំលែកព័ត៌មាននេះជាមួយលោក ដែលប្រាប់លោកថា អ្នកណាជាសមាជិកអចិន្ត្រៃយ៍នោះ? តើមានសមាជិកគណៈអចិន្ត្រៃយ៍ណាម្នាក់ធ្លាប់ប្រាប់លោកពីសមាសភាពដែលជាសមាជិកគណៈអចិន្ត្រៃយ៍នេះដែរឬទេ?

**ឆ៖** ដូចអត់មានទេ អត់មានទេបាទ អត់មានទេ។

**ស៖** ចុះសមាជិកគណៈមជ្ឈិមវិញ ថាតើធ្លាប់មានសមាជិកគណៈមជ្ឈិមណាម្នាក់ធ្លាប់និយាយជាមួយលោក បង្ហាញប្រាប់លោកពីឈ្មោះអ្នកណាខ្លះដែលជាសមាជិកមជ្ឈិមនោះ តើមានទេ?

**ឆ៖** ក៏អត់មានដែរ។

[១៤:៤០:០១]

**ស៖** នៅថ្ងៃនេះ នៅពេលដែលចៅក្រមសួរសំណួរទៅលោកថា តើគណៈមជ្ឈិមមានសមាជិកប៉ុន្មាននាក់? ខ្ញុំជឿថាលោកថាមានមួយចំនួនប្រហែលជា២០នាក់។ តើលោកនៅចាំថាលោកបានជម្រាបទៅចៅក្រមអ៊ីចឹងទេ?

**ឆ៖** បាទ ខ្ញុំបានជម្រាបចៅក្រមដូច្នេះ ប៉ុន្តែខ្ញុំដឹងដោយរបៀបទៅខ្ញុំជម្រាបលោកអំមិញអ៊ីចឹង។ មិនដឹងជាផ្លូវការ ហើយគ្មាននរណាមកប្រាប់ខ្ញុំថាអ្នកនេះអ្នកនោះជាអីៗទេបាទ។

**ប្រធានអង្គជំនុំ៖**

អូខេ! សូមអញ្ជើញបាទ!

បើកក្បាលមីក្រូសិន!

**សួរដោយលោក ម៉ៃខល កាណាវ៉ាស៖**

**ស៖** តើយើងអាចនិយាយថានៅពេលដែលលោកស្មានថាប្រហែល២០នាក់ កាលពីព្រឹកមិញនេះ

E1/69.1

គឺលោកស្មាន គឺតើខ្ញុំអាចនិយាយថាលោកស្មានថាប្រហែល២០នាក់ អ៊ីចឹងត្រឹមត្រូវទេ?

[១៤:៤១:២០]

**លោក សាឡូត បាន៖**

**ផ៖** បាទ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណលោកមេធាវី អរគុណសាក្សី។ ហើយឥឡូវដល់ពេលសមល្មមសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី។ ហើយចាប់ពីពេលនេះទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ប៉ុន្តែមុននឹងសម្រាក អង្គជំនុំជម្រះសូម ចង់ដឹងព័ត៌មានខ្លះពីក្រុមមេធាវីការពារក្តី តើក្រុមលោកមេធាវីការពារក្តី អៀង សារី តើត្រូវការពេលវេលាទំនងប្រហែលជាប៉ុន្មានទៀតក្នុងការតាំងសំណួរសាក្សីនេះ?

**លោក ម៉ៃខល កាណាវាស៖**

ប្រសិនណាជាខ្ញុំត្រូវស្មានពេលវេលាក្នុងពេលនេះ គឺមិនមែនត្រូវពេលតែសម្រាប់ពេញមួយរសៀលនេះទៀតទេ ប្រហែលជាត្រូវការរយៈពេលមួយព្រឹកពេញទៀតនៅថ្ងៃចន្ទ។ នេះបើតាមខ្ញុំប៉ាន់ប្រមាណពេលវេលា។ ជាការពិត គឺថាខ្ញុំត្រូវការពេលវេលានៅថ្ងៃចន្ទទៀត លោកប្រធាន។

[១៤:៤២:២៨]

**ប្រធានអង្គជំនុំ៖**

អរគុណ ចុះក្រុមមេធាវីការពារក្តីលោក នួន ជា?

**លោក ម៉ៃខល ផេសមិន៖**

ក្រុមយើងខ្ញុំក៏ត្រូវការពេលវេលាកន្លះថ្ងៃដែរ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទអរគុណច្រើន។ ចុះមេធាវីការពារក្តីលោក ខៀវ សំផន?

**លោក គង់ សំអុន៖**

បាទសូមអរគុណលោកប្រធាន។ ខាងក្រុមយើងខ្ញុំបានសំណូមពរពីលើកមុនថាសូមរយៈពេលអាចរហូតដល់មួយម៉ោងកន្លះត្រឹមប៉ុណ្ណឹងបាទ។ អរគុណ។

[១៤:៤៣:០៥]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ បាទសូមមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកសមរម្យនៅកន្លែងសម្រាកសម្រាប់សាក្សី ហើយនិងឲ្យអញ្ជើញសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មវិញនៅវេលាម៉ោងបី។ សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៣នាទី ដល់ម៉ោង១៥:០៤ នាទី)*

[១៥:០៤:៣៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

**លោក ម៉ៃខល កាណាវាស៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម អស់លោក លោកស្រីនៅក្នុងបន្ទប់សវនាការ និងនៅជុំវិញបន្ទប់សវនាការសាជាថ្មីម្តងទៀត ហើយសូមសួស្តីលោកសាក្សីសាជាថ្មី។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** នៅពេលនេះយើងនិយាយអំពីការចាត់តាំងលោក ទៅធ្វើការងារនៅក្រសួងការបរទេស។ លោកបានជម្រាបយើងខ្ញុំរួចមកហើយថាគឺ ប៉ង់ ដែលជាអ្នកចាត់តាំងលោកឲ្យកាន់នាទីនោះនៅក្នុងក្រសួងការបរទេស។ តើលោកចាំត្រង់ចំណុចដែលលោកនិយាយដូច្នេះដែរឬទេ?

[១៥:០៥:៤៤]

**លោក សាឡុត បាន៖**

**ឆ៖** បាទ លោក ប៉ង់ ណែនាំខ្ញុំឲ្យមកនៅក្រសួងការៗបរទេសបាទ។

**ស៖** នៅពេលនេះយើងនិយាយអំពីគុណសម្បត្តិ គុណវុឌ្ឍិនៅក្នុងនាទីរបស់លោក នៅក្រសួងការបរទេស។ នៅពេលដែលយើងនិយាយអំពីលក្ខណៈសម្បត្តិការងាររបស់លោកនេះ គឺថាជាដំបូងយើងសូមលើកឡើងអំពីការអប់រំរបស់លោក។ លោកនៅពេលដែលលោករៀននោះ លោកប្រឡងធ្លាក់

ដែរ ដូច្នេះតើលោកបានរៀនចប់ត្រឹមថ្នាក់ណាដែរ?

**ឆ៖** ខ្ញុំរៀនចប់ថ្នាក់ទីបី ពេលនោះគេហៅថា ទីបីទំនើបបាទ។

**ស៖** ចំពោះយើងខ្ញុំដែលមកពីប្រព័ន្ធដែលប្រព័ន្ធអប់រំ នៅក្នុងប្រទេសយើងមានលក្ខណៈផ្សេងពីនេះនោះ តើលោកអាចបញ្ជាក់ទេលោកបានសិក្សារយៈពេលប៉ុន្មានឆ្នាំដែរ ត្រឹមថ្នាក់ដែលលោកលើកឡើងហ្នឹង?

**ឆ៖** បើតាមខ្ញុំគិតមើលប្រហែល១៣ថ្នាក់បាទ។ បាទ អាច១០ថ្នាក់ទេបាទ។ មិនដល់៣ទេបាទ។

**ស៖** សូមអរគុណ។ លោកបានលើកឡើងថា លោកបានទៅប្រឡង។ ដូច្នេះ នៅពេលប្រឡងនោះលោកធ្លាក់ ដូច្នេះហើយទើបលោកមិនអាចឡើងថ្នាក់បាន តើខ្ញុំនិយាយនេះត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ក្រៅពីការអប់រំនេះ តើលោកទទួលការអប់រំបណ្ដុះបណ្ដាលផ្សេងពីនេះដែរឬទេ?

[១៥:០៨:២៩]

**ឆ៖** ក្រៅពីការអប់រំពីសាលា ខ្ញុំមានគេបណ្ដុះបណ្ដាលផ្សេងដែរ។ អ្នកផ្សេងនោះគឺឈ្មោះគេមិនពិត គេជាឈ្មោះសម្ងាត់ដែរ គេរៀនអំពីន័ ឲ្យសៀវភៅ គេថាឲ្យសៀវភៅមើលជំនាន់ហ្នឹង គេឲ្យសៀវភៅ គេយកសៀវភៅឲ្យមើលរឿង កាលនុ៎ងចូលចិត្តមើលរឿងចិន ឲ្យតែកុនអីចិនអីលេងរឿងបដិវត្តន៍ហ្នឹង បបួលគ្នាទៅមើលហើយ។ នេះខ្ញុំចាប់អារម្មណ៍ថា ការបណ្ដុះបណ្ដាលខ្ញុំមានអីចឹង។

**ស៖** មុនពេលដែលលោក ត្រូវបានចាត់តាំងទៅក្រសួងការបរទេស តើលោកមានបទពិសោធន៍ធ្វើការនៅក្នុងការងាររដ្ឋាភិបាលដែរឬទេ មុនពេលចាត់តាំងលោកទៅធ្វើការងារ នៅក្រសួងការបរទេស?

[១៥:១០:០៤]

**ឆ៖** បាទ ខ្ញុំអត់មានការចាត់តាំងពីធ្វើការងារខាងរដ្ឋបាលអីទេ ដូចខ្ញុំបានជម្រាបអីចឹងជាពលករសេរី។

**ស៖** នៅពេលដែលលោកនិយាយថា ជាពលករសេរី គឺលោកបានធ្វើការងារសាងសង កម្មករសំណង់ អ្នកធាក់ស៊ីក្លូ និងក្រោយមក លោកជាយុទ្ធជន គឺជាទាហាន តើត្រូវដែរឬទេ? ដូច្នេះ តាមការរៀបរាប់ខ្ញុំនេះ ទាំងអស់នេះហើយជាបទពិសោធន៍ដែលលោកធ្លាប់មានពីមុនមក នៅក្នុងពេលនោះ។ តើត្រឹមត្រូវដែរឬទេ?

**ផ៖** បាទ ត្រឹមត្រូវ។

**ស៖** មុនពេលលោកទទួលតួនាទី នៅក្នុងក្រសួងការបរទេស តើលោកមានទទួលការឧទ្ទេសនាម ឬក៏ទទួលការបណ្តុះបណ្តាលលើនាទីរបស់លោក មុនពេលទៅទទួលការងារនៅក្រសួងការបរទេសដែរឬទេ?

**ផ៖** តួនាទីរបស់ខ្ញុំ ចូលក្នុងក្រសួងការបរទេស ដូចខ្ញុំបានជម្រាបអ៊ីចឹង ទទួលខាងការគ្រប់គ្រងកម្លាំង ពិសេសកម្លាំងខាងផ្នែកកសិករ និងកុមារ ដែលមករៀន គេថាមកៗធ្វើការនៅក្រសួងការបរទេសនេះ ដែលទិសដៅនោះ គឺថាឲ្យកុមារអស់ទាំងនោះ ចេះរៀនការងារក្រសួងការបរទេស។

[១៥:១២:២១]

**ស៖** សូមអរគុណ។ មុនពេលលោកទៅធ្វើការងារនៅក្រសួងការបរទេស តើលោកគ្រប់គ្រងលើមនុស្សប៉ុន្មាននាក់ដែរ មុនពេលទៅធ្វើការក្រសួងការបរទេស។ បានន័យថា នៅពេលដែលលោកនៅក្នុងព្រៃ មានលោកមានកូនចៅប៉ុន្មាននាក់ដែរ ដែលលោកគ្រប់គ្រងពីលើ?

**ផ៖** ពេលនោះ ច្រើនតែការពារមន្ទីរ។ ដូច្នេះ មន្ទីរនោះ គឺមិនហួសពី៣០នាក់ទេ។

**ស៖** សូមអរគុណ។ តើលោកអាចជម្រាបយើងខ្ញុំបានដែរឬទេ អំពីកម្រិតអប់រំរបស់ ប៉ង់ តើគាត់ជាមនុស្សដែលទទួលការអប់រំបានជ្រៅជ្រះខ្ពង់ខ្ពស់ដែរឬទេ?

**ផ៖** តាមការប្រតិកម្មជាមួយបងប្អូន គេថាមនុស្សនេះ ពូកែអប់រំណាស់ ឲ្យគេចូលចិត្តសម្តីទន់ភ្លន់។

**ស៖** តើ ប៉ង់ អាចចេះសរសេរ ចេះអានអីបានដែរឬទេ?

**ផ៖** ពេលខ្ញុំស្គាល់ ប៉ង់, ប៉ង់ ចេះសរសេរ ចេះអាន ចេះភាសាវៀតណាមទៀត។

**ស៖** សូមអរគុណ។ តើលោកអាចជម្រាបយើងខ្ញុំបានដែរឬទេថា តើលោកមានគុណសម្បត្តិអ្វីដែលសមនឹងទទួលតួនាទី ទីពីរនៅក្នុងក្រសួងការបរទេស? ដោយលោកគ្រាន់តែមានការគ្រប់គ្រងទៅលើអ្នកដែលជាកូនចៅរបស់លោក ត្រឹមតែ៣០នាក់តែប៉ុណ្ណោះ ហើយលោកមិនមានការបណ្តុះបណ្តាលជាក់លាក់ផង ហើយលោកក៏មិនចេះភាសាផងដែរនោះ តើលោកមានគុណសម្បត្តិអ្វី បានជាគេចាត់តាំងឲ្យលោកមានមុខនាទី ទីពីរនៅក្នុងក្រសួងការបរទេសនោះ?

[១៥:១៥:០៥]

**ផ៖** ខ្ញុំអត់យល់សំណួរហ្នឹង។ អំមិញខ្ញុំឆ្លើយអំមិញហ្នឹង ខ្ញុំឆ្លើយក្នុងព្រៃ ឥឡូវមកក្រសួង

ការបរទេស ហ្នឹងខ្ញុំភ័ន្តច្រឡំបាទ។ អំមិញ៣០នាក់ អំមិញហ្នឹង គឺថាខ្ញុំចាប់អារម្មណ៍ថា សំណួរហ្នឹងសួរខ្ញុំនៅក្នុងព្រៃទេបាទ។ ឥឡូវនេះ ខ្ញុំថាគាត់ចង់សួរពីក្នុងព្រៃ ឬក៏មួយក្រសួង-- នៅក្នុងក្រសួងការបរទេសតែម្តង?

**ស៖** ខ្ញុំសូមអធ្យាស្រ័យ សំណួររបស់ខ្ញុំវាហាក់ដូចជាវែងបន្តិច។ តើលោកមានលក្ខណៈសម្បត្តិអ្វី គុណសម្បត្តិអ្វីដែលធ្វើឲ្យគេចាត់តាំងលោកជាអគ្គលេខាធិការនៅក្រសួងការបរទេសនោះ?

[១៥:១៦:១០]

**ឆ៖** ខ្ញុំមិនមានអីជាត្រូវការចាត់តាំងឲ្យខ្ញុំទៅក្រសួងការបរទេសទេ ខ្ញុំតវ៉ាដែរ ថាខ្ញុំមិនចេះទេ ខ្ញុំធុនណាស់ ពីរឿងបរទេសអីនោះ។ ប៉ុន្តែតាមខ្ញុំចាំ បង អៀង សារី គាត់ស្រឡាញ់ខ្ញុំ ប្រហែលជាខ្ញុំនេះអាចជួយជាមុខជាមាត់គាត់បាន។ ដូច្នេះ ខ្ញុំមើលឃើញគុណសម្បត្តិរបស់ខ្ញុំ គឺមានការស្មោះត្រង់នឹងលោក ប្រហែល។ នេះតាមខ្ញុំសន្និដ្ឋាន។

**ស៖** លោកបានជម្រាបយើងខ្ញុំ-- ខ្ញុំគិតថា លោកជម្រាបយើងខ្ញុំថា ប៉ង់ ជាអ្នកប្រាប់លោកឲ្យលោកទៅធ្វើការនៅក្រសួងការបរទេស។ ដូច្នេះថាតើ ប៉ង់ មើលឃើញគុណសម្បត្តិ ចំណុចល្អរបស់លោកត្រង់ណាខ្លះ ដែលបញ្ជូនលោកទៅធ្វើការនៅក្រសួងការបរទេសនោះ?

**ឆ៖** តាមខ្ញុំយល់ខ្លួនឯង ប្រហែលជាបង អៀង សារី លោកស្នើខ្ញុំហើយមើលទៅ។

[១៥:១៧:៤៨]

**ស៖** សូមអរគុណដែលលោកបានជម្រាបយើងខ្ញុំអំពីគំនិតទស្សនៈផ្ទាល់ខ្លួនរបស់លោក។ ចំណុចនេះហើយដែលខ្ញុំចង់ជជែកបន្តិចបន្តួច។ តាមដែលខ្ញុំយល់ លោកចង់បានន័យថាយ៉ាម៉េច? បានន័យថា ចំណុចនេះលោកដឹងផ្ទាល់ ឬលោកគ្រាន់តែស្មានទេ?

**ឆ៖** តាមទម្លាប់របស់ជនបដិវត្តន៍ អ្នកដឹកនាំមិនបញ្ចេញភាពអស្ចារ្យឲ្យនរណាមួយដឹងទេ។ ត្រូវគិតគូរដោយខ្លួនឯង។

**ស៖** ខ្ញុំសូមនិយាយបញ្ជាក់ម្តងឡើងវិញ។ ប្រហែលជាមានការបាត់ពាក្យពេចន៍នៅក្នុងការបកប្រែ។ នៅពេលដែលលោកនិយាយថា តាមខ្ញុំដឹង បានន័យថាលោកចង់និយាយថា លោកដឹង ឬក៏លោកស្មានទេ នៅពេលដែលលោកនិយាយថា តាមខ្ញុំដឹងហ្នឹង? មួយណា លោកស្មាន ឬក៏លោកដឹងដោយផ្ទាល់?

**ឆ៖** តាមការវិភាគរបស់ខ្ញុំ ខ្ញុំដឹងផ្ទាល់ដោយខ្លួនឯងហើយ។

**ស៖** តាមការវិភាគខ្ញុំយល់ដោយខ្លួនឯង បានន័យថា លោកផ្អែកទៅលើហេតុការណ៍ជាក់ស្តែង ឬក៏លោកស្មានទេ នៅពេលដែលលោកនិយាយថា តាមការវិភាគខ្ញុំដឹងផ្ទាល់ខ្លួននេះ?

**ឆ៖** ខ្ញុំដឹងដោយខ្លួនឯង។

[១៥:២០:០៣]

**ស៖** តើលោកគិតថា គ្រាន់តែជាក្មួយរបស់ ប៉ុល ពត ធ្វើឲ្យលោកបានទទួលតំណែងហ្នឹងតែម្តងត្រឹមត្រូវដែរឬទេ ត្រង់ចំណុចហ្នឹង?

**ឆ៖** អត់មានអ៊ីចឹងទេ អត់ត្រឹមត្រូវទេបាទ។

**ស៖** តើលោកគិតថាមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹង ប៉ង់ ជាច្រើនឆ្នាំ។ ចំណុចនេះឲ្យដែលធ្វើឲ្យលោកទទួលបាននាទីនេះ។ អ៊ីចឹងដែរឬទេ?

**ឆ៖** អត់មានអ៊ីចឹងទេលោក។

**ស៖** ប្រសិនបើខ្ញុំសួរអំពី ជាម តើលោកដឹងថាគាត់ធ្វើការអ្វី? ហើយទទួលតំណែងអ្វីនៅក្នុងក្រសួងការបរទេស?

**ឆ៖** គាត់ជាផ្នែកមួយក្រោមការដឹកនាំរបស់ខ្ញុំដែរ។ គាត់មានតួនាទីផ្នែកខាងកសិករទេ ជាការមើលការខុសត្រូវខាងសន្តិសុខ និងខាងការដាំដុះ។

**ស៖** ខ្ញុំសូមត្រឡប់សួរសំណួរសាឡើងវិញ។ លោកបានជម្រាបយើងខ្ញុំពីមុនថា ប៉ង់ គឺជាបុគ្គលម្នាក់ចាត់តាំង ជាម ឲ្យទៅធ្វើការនៅក្រសួងការបរទេស។ តើខ្ញុំនិយាយដូច្នេះត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទត្រឹមត្រូវ។

**ស៖** លោកទើបតែជម្រាបយើងខ្ញុំថា ជាម ធ្វើការខាងផ្នែកសន្តិសុខ តើអ៊ីចឹងដែរឬទេ?

**ឆ៖** *(មិនឮសំឡេង)*

**ស៖** ជាម គឺជាកូនចៅរបស់លោក ហើយលោកគឺជាមេផ្ទាល់របស់ ជាម តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ នៅក្នុងក្របខ័ណ្ឌក្រសួងការបរទេស។

**ស៖** ហើយក៏ទទួលបន្ទុកផ្នែកសន្តិសុខផងដែរ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ។

**ស៖** មុនពេលទៅធ្វើការនៅក្រសួងការបរទេស លោកធ្វើការផ្នែកសន្តិសុខក្រោមការទទួលខុសត្រូវរបស់ ប៉ង់។

**លោក ម៉ែខល កាណាវាស៖**

ខ្ញុំសូមឈប់ត្រឹមហ្នឹងសិន ខ្ញុំឃើញមេធាវីគាត់ក្រោកឈរឡើង ប្រហែលជាខ្ញុំសួរខុសឬយ៉ាងម៉េច?

[១៥:២៣:៣៩]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមឲ្យថាំបន្តិចព្រោះថាចម្លើយអត់បាន អត់មានចម្លើយនៅក្នុងការបកប្រែ ផ្នែកខាងដើមនៃចម្លើយនេះ។ អ៊ីចឹងសូមឲ្យពន្យារ-- ពន្យឺតបន្តិច។ សូមអរគុណ។

**លោក ម៉ែខល កាណាវាស៖**

សូមអធ្យាស្រ័យ ហើយខ្ញុំយល់ថាខ្ញុំដឹងថាបារាំងបកចេញពីអង់គ្លេស ហើយអង់គ្លេសបកទៅចេញជាភាសាខ្មែរ។ ខ្ញុំសូមអធ្យាស្រ័យ ខ្ញុំនឹងសួរឲ្យបានយឺត ខុសពីទម្លាប់ដែលខ្ញុំធ្លាប់សួរ។

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** មុនពេលដែលលោកទៅធ្វើការងារនៅក្រសួងការបរទេស លោកនិង ជាម ធ្វើការងារនៅក្នុងផ្នែកសន្តិសុខក្រោមការក្តោបក្តាប់ដោយផ្ទាល់របស់ ប៉ង់។ តើត្រឹមត្រូវដែរឬទេ?

**លោក សាឡុត បាន៖**

**ឆ៖** បាទត្រឹមត្រូវ។

[១៥:២៥:០០]

**ស៖** កាលពីព្រឹកមិញ សំណួរសួរដោយចៅក្រម នៅពេលដែលចៅក្រមសួរអំពីប្រវត្តិរូបរបស់លោក ហើយថាតើសំខាន់បែបណាដែលត្រូវឲ្យលោកមានប្រវត្តិរូបស្អាតស្អំ? តើមានសួរសំណួរ-- ចៅក្រមសួរសំណួរដូច្នេះទៅដល់លោកដែរឬទេ?

**ឆ៖** ខ្ញុំភ្លេចហើយ។

**ស៖** ខ្ញុំគិតឃើញថា ខ្ញុំចាំថា លោកហាក់ដូចបញ្ជាក់ថា ដោយសារតែលោកមានប្រវត្តិរូបស្អាតស្អំ។ ដូច្នេះហើយ មហាជនដែលគាត់ទុកចិត្តលោកឲ្យលោកធ្វើការងារនៅក្នុងក្រសួងការបរទេស ប្រហែលជាខ្ញុំចាំស្តាប់ទៅខុសត្រង់ចំណុចនេះ ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ត្រឹមត្រូវ។

[១៥:២៦:០៨]

**សៈ** ខ្ញុំសន្មតថា ផ្អែកតាមការ-- ចំណុចនេះ គឺផ្អែកតាមការវិភាគរបស់លោក តើត្រឹមត្រូវដែរឬទេ?

**ឆៈ** បាទ ត្រឹមត្រូវ។

**សៈ** តើលោកអាចប្រាប់យើងខ្ញុំដែរឬទេ លោកមានចំណុចលក្ខណៈត្រង់ណាដែលលោកធ្វើការវិភាគទៅលើប្រវត្តិរូបរបស់លោកថាស្អាតស្អំ ហើយមហាជនគាត់ពេញចិត្តចង់ឲ្យតែងតាំងលោកកាន់តួនាទីនៅក្នុងក្រសួងបែបនោះ នោះ?

**ឆៈ** ខ្ញុំយល់ឃើញថា ខ្លួនខ្ញុំមានគុណសម្បត្តិ និងគុណវិបត្តិ ប៉ុន្តែគុណសម្បត្តិមានធំជាងគុណវិបត្តិ។ គុណវិបត្តិដែលធំ គឺអត្តចរិតរបស់ខ្ញុំមិនចេះជ្រៀតជ្រែកគេ ចេះតែបង្រួបបង្រួមគ្នាឲ្យបានសុខឲ្យបានគង់ ឲ្យបានចម្រើននៅក្នុងក្រសួងនីមួយៗដែលខ្ញុំទទួល កន្លែងណាដែលខ្ញុំទទួល គឺបានសេចក្ដីសុខ សេចក្ដីគង់ សេចក្ដីចម្រើន។

**សៈ** សូមអរគុណ។ លោកបានបញ្ជាក់ថា បាទពីពេលមួយទៅពេលមួយ ម្សិលមិញ ម្សិលម៉្ងៃ គេសួរលោកអំពី ប៉ង់។ គឺគេសួរលោកអំពី ប៉ង់ ចន្លោះឆ្នាំ៧៥ ទៅដល់៧៩ ហើយមានសំណួរសួរលោកដដែលថា តើអ្នកណាគេជាមេផ្ទាល់របស់ ប៉ង់? នៅពេលដែលលោកនៅក្នុងថ្ងៃនេះ លោកបានជម្រាបយើងខ្ញុំថា ទោះបីជាលោកចំណាយពេលជាច្រើនឆ្នាំនៅជាមួយនឹង ប៉ង់ ក៏ដោយ ក៏លោកនៅតែមិនស្គាល់នរណាគេជាមេរបស់ ប៉ង់ ដែរ? តើអ៊ីចឹងដែរឬទេ?

**ឆៈ** ខ្ញុំមិនដឹងនរណាជាមេរបស់ ប៉ង់ ផ្ទាល់ទេ។ ខ្ញុំដឹងថា ប៉ង់ នៅក្នុង ជា១១ប្រធានមន្ទីរ ៨៧០។

[១៥:២៩:១៧]

**សៈ** សូមអរគុណ។ លោកបាននិយាយថា ខ្ញុំដឹងថាគាត់ជាប្រធាន តើលោកដឹងហ្នឹងផ្អែកតាមអ្វី នរណាគេប្រាប់លោកដែរ?

**ឆៈ** ពីព្រោះ ប៉ង់ មានអំណាចដើរបាន អ្វីបានក្រៅ អ្នកធ្វើសំបុត្រស្នាម ចេញចូល ដើរហើរអីបាន។ ដូច្នេះបងប្អូននៅក្នុងមន្ទីរ មិនមែនអ្នកដឹកនាំប្រាប់ខ្ញុំទេ បងប្អូនមន្ទីរថា ប៉ង់ ជាប្រធានមន្ទីរហើយ។

**សៈ** កាលពីព្រឹកមិញ លោកបាននិយាយថា ប៉ង់ គាត់មានអំណាចទៅលើមន្ទីរទាំងឡាយ ទៅលើក្រសួងទាំងឡាយ។ តើលោកផ្អែកលើអ្វីដែរ ដែលលោកឆ្លើយដូច្នេះ?

**ធ៖** ទីមួយ បង អៀង សារី គាត់ប្រាប់ខ្ញុំថា “ប៉ង់ មកត្រូវការអីស្ដាប់ ប៉ង់ ទៅ!”។ នេះទីមួយ។ ប៉ុន្តែទីពីរ បងប្អូនដែលនៅក្នុងមន្ទីរ ពិសេសមន្ទីរក-១ នុ៎ង ប្រាប់ខ្ញុំថា “ប៉ង់ ជាប្រធានមន្ទីរហើយ”។

**ស៖** យើងសួរសំណួរចុងប្រយោគចុងក្រោយអ្នកណាគេនៅក-១ ដែលប្រាប់លោកអំពីបញ្ហា ប៉ង់ នេះ?

[១៥:៣១:៣០]

**ធ៖** គឺលោក លីន ឈ្មោះលោក លីន។

**ស៖** ចុះចំពោះឪពុកមារបស់លោក លោកធ្លាប់និយាយជាមួយឪពុកមារបស់លោកអំពីតួនាទីរបស់ ប៉ង់ ដែរឬទេ?

**ធ៖** ខ្ញុំមិនដែលសួរពីរឿងមុខងាររបស់លោក ប៉ង់ ទេជាមួយនឹងឪពុកមាខ្ញុំ។

**ស៖** លោកជម្រាបយើងខ្ញុំថា ប៉ង់ អាចចេញចូលតាមចិត្តបាន។ ប៉ង់ អាចនាំមនុស្សមកក្រសួង ហើយចាប់មនុស្សនៅក្នុងក្រសួងយកទៅខាងក្រៅវិញតាមចិត្តរបស់ខ្លួនបាន។ លោកផ្អែកចំណុចហ្នឹងៗត្រង់ចំណុចណាដែរ ដែលនិយាយថាអំណាច តួនាទីរបស់ ប៉ង់ ហ្នឹង?

**ធ៖** ផ្អែកនៅចំណុចដែលខ្ញុំបាននិយាយអំមិញអ៊ីចឹង គឺប្រាប់ ដឹងថាប្រធានមន្ទីរ ដឹងថា បង អៀង សារី លោកថា “ប៉ង់ ឲ្យមកធ្វើអីក៏តាម ប៉ង់ ទៅ!”។

**ស៖** សូមអរគុណ។ តើមានអ្វីកើតឡើង ប្រសិនបើលោកជំទាស់តវ៉ាជាមួយ ប៉ង់ នៅពេលដែល ប៉ង់ នោះមកចាប់មនុស្សយកចេញទៅនោះ?

**ធ៖** ខ្ញុំអត់មានអីតវ៉ាទេ។ ខ្ញុំគ្រាន់តែសួរ បើមកជួបខ្ញុំ ខ្ញុំគ្រាន់តែសួរថា “យកគេធ្វើអី? គេថា យកទៅៗនេះ យកទៅនោះ មន្ទីរនេះមន្ទីរនោះអីខ្ញុំអត់ដឹងទេ។ ខ្លះគេថាយកទៅនៅកន្លែងផ្សេង មន្ទីរផ្សេង”។ ដូច្នេះ ក៏ឲ្យគេទៅ អត់មានតវ៉ាអីទេ។

**ស៖** សូមអរគុណ។ លោកជាអ្នកទទួលផ្នែកសន្តិសុខ ហេតុអ្វីបានជាលោកពុំព្រមចាត់វិធានការការពារមនុស្សទាំងឡាយដែលធ្វើការងារនៅក្រសួងការបរទេសទាំងអស់នោះ?

**ធ៖** បាទ អត់មានសិទ្ធិៗ បាទ អត់មានសិទ្ធិតវ៉ាបាទ។ តែឃើញមនុស្សហ្នឹងមក គឺថាអត់មានសិទ្ធិតវ៉ាអីទេ។

**ស៖** តើលោកខ្លាចៗគាត់ទេ?

[១៥:៣៥:០៥]

**ឆ៖** ពីដើមឡើយ អត់មានរឿងអីចាប់ចង ខ្ញុំមិនខ្លាចទេ។ ដល់តែឃើញរឿងចាប់ចងចេញមកពីហ្នឹង ខ្ញុំខ្លាច ចាប់ផ្ដើមខ្លាច "វេនណាអញទៀតហើយ"។

**អ្នកបកប្រែ៖**

សូមអធ្យាស្រ័យលោកប្រធាន មេធាវីអត់បើក្បាលមីក្រូ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ហេតុអ្វីបានជាលោកខ្លាច ប៉ង់ ពីព្រោះលោកស្គាល់ ប៉ង់ ច្រើនឆ្នាំមកហើយ? ហើយដោយសំអាងទៅលើថា ដោយសារតែលោកជាក្មួយបង្កើតរបស់ ប៉ុល ពត គឺថាលោកមានដែល ប៉ុល ពត ជិតដិតជាមួយនឹង ប៉ង់ នោះ ម៉េចបានជាលោកខ្លាច ប៉ង់ ទៅវិញ?

**លោក សាឡុត បាន៖**

**ឆ៖** ខ្ញុំពិបាកពន្យល់ណាស់បាទ។ អានេះវាជាច្បាប់គឺថា នៅពេលនុ៎ងគឺថា អ៊ីចឹងវាបង្កើតអ៊ីចឹងតែម្ដងបាទ គឺថាគេធំហើយគេបានបញ្ជាអ៊ីចឹងហើយ គឺត្រូវតែធ្វើតាម ហើយគេមកគេថា គេយក ដូចខ្ញុំនិយាយអំមិញហ្នឹង យកទៅនេះយកទៅនោះ។ ខ្ញុំក៏គិតឃើញថា អូ៎ បែបគេទៅហ្នឹងគេទៅស្រួលបួលទេមិនដឹង។ ប៉ុន្តែដល់ខ្ញុំក្រោយមក ខ្ញុំបាននិយាយជាញឹកញាប់ហើយ ក្រោយមកដល់ឃើញថា អូ៎ យកទៅនេះមិនយកទៅអប់រំរៀនសូត្រអីទេរើយទៅបាត់ៗហើយ។ ដូច្នេះ ក៏កើតក្ដីព្រួយអ៊ីចឹងអ្នេ៎។

[១៥:៣៦:៥៧]

**ស៖** ប៉ុន្តែលោកមានទំនាក់ទំនងផ្ទាល់ខ្លួនជាមួយនឹង ប៉ង់ ហេតុអីក៏លោកមិនពិភាក្សាជាមួយ ប៉ង់ មិនសួរ ប៉ង់?

**ឆ៖** ខ្ញុំបានជម្រាបហើយតើ ខ្ញុំសួរបន្តិចបន្តួចដែរតើ គេថាយកទៅកន្លែងផ្សេង ខ្ញុំមិនដឹងថាគេយកទៅធ្វើបាបឯណា។

**ស៖** ចុះម៉េចក៏លោកមិនទៅជួបពូរបស់លោក ហើយសួរថា តើមានរឿងអីកើតឡើងចំពោះមនុស្សទាំងអស់ហ្នឹង?

**ឆ៖** ដូចខ្ញុំបានជម្រាបអ៊ីចឹង ទាល់តែរួមផ្សំគ្នាឲ្យច្បាស់លាស់ណាស់ បើមិនច្បាស់លាស់ទេកុំរាយការណ៍ប្រយ័ត្នវ័ណ្ឌក ដល់ខ្ញុំដឹងរឿងច្បាស់ ខ្ញុំទៅមូលដ្ឋាន ខ្ញុំឃើញគេធ្វើបាបប្រជាជន ឪពុកខ្ញុំ។ ខ្ញុំរាយការណ៍ទៅបង អៀង សារី ហើយបង អៀង សារី រាយការណ៍ទៅខាងលើ បានបង្កើតច្បាប់

អា៧ជាន់ហ្នឹងមក។

[១៥:៣៨:៣០]

**ស៖** ឥឡូវនេះត្រឡប់ទៅនិយាយអំពីការភ័យខ្លាចរបស់លោកនៅពេលលោកនៅក្រសួងការបរទេស តើលោក បើលោកខ្លាច ប៉ង់ ហេតុអ្វីក៏លោកមិនទៅជួបឪពុកមា ពូរបស់លោក ដើម្បីនិយាយអំពី ប៉ង់ ដែលជាអ្នកផ្ដល់សន្តិសុខទៅឲ្យពូរបស់លោក គឺ ប៉ុល ពត ហេតុអីក៏មិនទៅជួបពូរបស់លោកតែម្ដងទៅ?

**ឆ៖** ខ្សែណា ខ្ញុំត្រូវតាមខ្សែនុ៎ង ខ្ញុំមិនរំលងខ្សែទេ ខ្ញុំមិនមែន-- លោកពូខ្ញុំមិនមែនជាគ្រួសារនិយមទេ។ ខ្ញុំត្រូវតាមឋានានុក្រមខ្សែខ្ញុំ។

**ស៖** លោកបានបញ្ជាក់ថា ប៉ង់ ត្រួតត្រាក្រសួងផ្សេងៗគ្រប់គ្រងក្រសួងផ្សេងៗដទៃទៀត ក្រៅពីក្រសួងការបរទេស តើមានក្រសួងណាខ្លះ?

**ឆ៖** តាមខ្ញុំដឹងដូចមានឥទ្ធិពលទាំងអស់គ្រប់ក្រសួងបាទ ព្រោះខ្ញុំគេឃើញគេដើរហើរអីបានតាមចិត្ត ក្រុមគេដើរហើរអីបានតាមចិត្តបាទ។

[១៥:៤០:០៣]

**ស៖** នៅពេលដែលលោកថា គេមានឥទ្ធិពលគ្រប់ក្រសួងទាំងអស់ មានន័យថា លោកក៏មាន-- គាត់ក៏មានឥទ្ធិពលទៅលើ អ្នកដែលគ្រប់គ្រងក្រសួងទាំងនោះដែរ ឬក៏យ៉ាងណា?

**ឆ៖** ខ្ញុំមិនសន្និដ្ឋានបានទេបាទ។

**ស៖** លោកបានបញ្ជាក់ថា មានពេលមួយនោះ ជាម បានយកមនុស្សចេញទៅពីក្រសួងការបរទេស លោកនៅនឹកឃើញថា លោកបានបញ្ជាក់ថាដូច្នេះទេ?

**ឆ៖** បាទ ពេលនោះ ពេលដែល ជាម យកទៅ ខ្ញុំអត់ដឹងទេ។ ប៉ុន្តែ ពេលដែល ជាម មកវិញ បានខ្ញុំសួរ។ ពេលដែលខ្ញុំសួរ គេថា គេមកទទួលយកពី ជាម ទៅទៀតហើយ ទៅណាៗ មិនដឹងទេ។

**ស៖** អ្នកដែលបានចូលរួមក្នុងក្រសួង តើគេមានបានបង្ហាញខ្លួនរបស់គេ ណែនាំបង្ហាញខ្លួន ឬមានឯកសារណាមួយ ដែលគេហៅថាមានលក្ខណៈរឹងមាំ ដើម្បីអនុញ្ញាតឲ្យអ្នកទាំងនោះ ចូលមកធ្វើការនៅក្រសួងការបរទេសទេ? ឬក៏មានតែ ជាម ទេ ដែលជាអ្នកប្រាប់ទៅលោកនោះ?

**ឆ៖** គឺលោក ជាម នៅក្រោមការដឹកនាំរបស់ខ្ញុំ។ ដូច្នេះ ខ្ញុំសួរបានតែលោក ជាម ទេ ដែលនៅក្រោមការដឹកនាំរបស់ខ្ញុំបាទ។

[១៥:៤២:១៦]

**ស៖** តើគាត់ដែលបង្ហាញអត្តសញ្ញាណមនុស្សដែរឬទេ? ដោយសារថាគាត់ទទួលផ្នែកសន្តិសុខ ហើយគាត់គឺជាអ្នកនៅក្រោមឱវាទ ជាកូនចៅរបស់លោក។ តើលោកដែលសួរគាត់ថា អ្នកទាំងនោះជាអ្នកណាទេ? ហើយបើគេមកអ៊ីចឹង តើគេមានអំណាចអី ដែលគេអាចយកមនុស្សចេញទៅខាងក្រៅក្រសួងបាននោះ លោកដែលសួរសំណួរបែបនេះទៅគាត់ដែរទេ?

**ឆ៖** ទៅលោក ជាម ឬទៅពីណា លោក?

**ស៖** លោកបាននិយាយថា លោកបានដឹងថា ជាម បានយកមនុស្សចេញពីក្រសួងការបរទេស។ ខ្ញុំក៏សួរលោកថា ដោយសារថា ជាម នេះ លោកជាមេរបស់គាត់ តើលោកដែលសួរទៅ ជាម ដើម្បីឲ្យកំណត់អត្តសញ្ញាណរបស់មនុស្ស ដែលត្រូវចូលមកយកខ្លួនមនុស្សចេញ ទៅខាងក្រៅក្រសួងការបរទេសនោះដែរឬទេ?

**ឆ៖** បាទ ខ្ញុំសួរ ថាមនុស្សនេះ ជាមនុស្សរបស់មកពីលោក ប៉ង់។

**ស៖** តើគាត់ដឹងថា អ្នកដែលមកយកមនុស្សហ្នឹង គឺមកពីក្រុមរបស់ ប៉ង់ ដោយរបៀបណា?

**ឆ៖** ខ្ញុំពិបាកឆ្លើយ របៀបណាហ្នឹង គឺថា ប៉ង់ បញ្ជាមកហើយ បានគេមក។ ហើយគេមកហ្នឹងតាមរបៀបណា គឺតាមម៉ូតូៗអីហ្នឹងបាទ។

**ស៖** ថាតើអ្នកដែលមកហ្នឹង មានឯកសារណាមួយដែល ប៉ង់ បញ្ជាឲ្យមកដើម្បីបង្ហាញខ្លួនពួកគេថា ពួកគេគឺជាមនុស្សក្រុម ប៉ង់ ឬក៏ជាសន្តិសុខមកពីក្រុម ប៉ង់ ដើម្បីឲ្យពួកគេអាចយកមនុស្សចេញទៅខាងក្រៅក្រសួងបាននោះ?

[១៥:៤៥:០៥]

**ឆ៖** ព្រោះ ជាម ក៏ស្គាល់មនុស្សនោះថាជាមនុស្សរបស់ ប៉ង់ ជាអនុ ជាសមាជិករបស់ ប៉ង់ ច្បាស់លាស់ណាស់។

**ស៖** តើនេះដោយសារថា ជាម ធ្វើការជាមួយអ្នកទាំងនោះមុននឹងគាត់បានតួនាទី ទទួលបានតួនាទីនៅក្រសួងការបរទេសនេះ ឬក៏យ៉ាងណា?

**ឆ៖** មិនមែន ជាម ធ្វើការជាមួយលោក ប៉ង់ អ្វីធំដុំទេ គ្រាន់តែពេលខ្លះអាច គឺថា ប៉ង់ មានសិទ្ធិណ៎ះ ខ្ញុំមិននៅអីៗ ប៉ង់ អាចៗហៅ ជាម ហ្នឹង។ អាចហៅ ជាម ហ្នឹងទៅឧទ្ទេសនាមប្រាប់ថា អានេះមនុស្សខ្ញុំៗអ៊ីចេះៗ។ នេះវិធីគេអ៊ីចឹង អ៊ីចេះៗបាន ហើយបើមានការអី ន៎ែ ទាក់ទងទៅន៎ែ! មនុស្ស

នេះដែលខ្ញុំឧទ្ទេសនាម អ៊ីចេះៗទៅ អ្នកឯងធ្វើតាមហ្នឹងទៅ។

[១៥:៤៦:២៤]

**សៈ** នៅពេលដែលលោកមានវត្តមាន ថាតើ ប៉ង់ បានមកជួបលោកទេ?

**ផៈ** ខ្ញុំស្តាប់មិនច្បាស់ នរណាដែលវត្តមានបាទ?

**សៈ** នៅពេលដែលលោកមានវត្តមាននៅក្រសួងនុ៎ង ហើយគឺថាគេមិនចាំបាច់ត្រូវទៅជួប ជាមទេ តើប៉ង់ ត្រូវមកជួបលោក ឬក៏យ៉ាងណា?

**ផៈ** ពេលយកមនុស្ស ខ្ញុំវត្តមាន មិនដែលឃើញ ប៉ង់ មកជួបខ្ញុំទេ។

**សៈ** នៅពេលដែលលោកមានវត្តមាន តើមានគេដែលយកមនុស្សចេញពីក្រសួងការបរទេសដែរទេ? ឬក៏លោកកំពុងតែជម្រាបមកខ្ញុំថា កាលណាលោកមានវត្តមាន គឺគេមិនដែលមកយកមនុស្សចេញទៅខាងក្រៅក្រសួងទេ អ៊ីចឹងឬក៏យ៉ាងណា?

**ផៈ** ពេលដែលខ្ញុំនៅក្រសួង ខ្ញុំចាំបានថា មានគេមកយក។ ប៉ុន្តែ ប៉ង់ ទូរស័ព្ទ ថាបើមានគេមកយកអ្នកនេះអ្នកនោះទៅនេះ ឲ្យយកផង។ ឯផ្ទាល់ដូចជាមិនដែលទេ មានតែទូរស័ព្ទបាទ។ កាលនុ៎ងគេប្រើទូរស័ព្ទខ្សែ បាទ។

[១៥:៤៨:៣៨]

**សៈ** សូមអរគុណលោកសាក្សី។ ខ្ញុំចង់សួរបញ្ជាក់ឲ្យច្បាស់ តើ ប៉ង់ ដែលពន្យល់ប្រាប់លោកថាគាត់ត្រូវសុំសិទ្ធិអំណាចពីអ្នកណា ដើម្បីឲ្យ ប៉ង់ ហ្នឹងអាចមកយកមនុស្សចេញពីក្រសួងការបរទេសបាននោះ?

**ផៈ** អត់មានទេ ខ្ញុំក៏អត់សួរ។

**សៈ** ហេតុអីក៏លោកមិនសួរគាត់? ឬក៏មានអ្វីមួយដែលតម្រូវថាលោកមិនត្រូវធ្វើបែបនេះនោះ?

**ផៈ** អត់សួរ។ បើសួរពីរឿងចាប់មនុស្ស ចាប់អី ខ្ញុំមិនសួរទេ គ្រាន់តែសួរថា យកទៅណាៗហ្នឹងមិនហ៊ានសួរផង។ ប៉ុន្តែដល់ពេលខ្លះ ខ្ញុំក៏សាកសួរអ្នកខ្លះដែរ ខ្សឹបៗទេ “យកទៅណា? អូ៎! យកទៅរៀន ទៅនេះ ទៅនោះ ទៅធ្វើអគ្គិសនី ទៅធ្វើអីអ៊ីចឹងទៅ គេអ្នកបច្ចេកទេសអ៊ីចេះៗអី”។ សួរបានតែប៉ុណ្ណឹងទេបាទ។

[១៥:៥០:១០]

**សៈ** តើលោកជឿនូវអ្វីដែលគេប្រាប់មកលោកអ៊ីចឹងទេ?

**ឆ៖** ពេលដែលខ្ញុំមិនដឹងសភាពការណ៍ទូទៅ ច្របូកច្របល់ ក្រសួងការបរទេសក៏មិនទាន់ច្របូកច្របល់ដែរ។ គេសួរអ៊ីចឹងទៅ-- អ៎ គេមកយកអ៊ីចឹងទៅ ក៏សម្ងំទៅ គឺថាអត់ដឹងអីទេ។ មិនសូវដឹងអីទេ ស្មានតែគេយកទៅថា-- តាមគេថាអ៊ីចឹងមែន។ ដល់តែខ្ញុំដឹងពីនោះពីនេះច្រើនមក ខ្ញុំដើរទទួល-- ជូនភ្ញៀវអីទៅជនបទជនអីអ៊ីចឹងទៅ ដឹងពីរឿងជីវភាពអ៊ីចឹងទៅ បានខ្ញុំដឹងថា អ្ហូ រឿងនេះមិនមែនរឿងទៅធ្វើការទេ រឿងៗទៅសម្លាប់ ទៅអីផ្សេងហើយ។ នេះខ្ញុំដឹងអ៊ីចឹងទេ ក្រោយមកបាទ។

[១៥:៥១:២១]

**ស៖** តើលោកដែលលោកសួរទៅពូ ប៉ុល ពត នៅមុន ឬក្រោយឆ្នាំ១៩៧៩ ថាតើមានអ្វីកើតឡើងចំពោះអ្នកដែលគេយកចេញទៅក្រៅហ្នឹង?

**ឆ៖** ខ្ញុំមិនដែលបានសួរលោកផ្ទាល់ទេ។

**ស៖** យើងនៅសល់ពេលតែដប់នាទីទៀតទេ ខ្ញុំនឹងត្រឡប់មកដើម្បីឲ្យដឹងច្បាស់ ថាតើថ្ងៃចន្ទយើងត្រូវដល់ត្រឹមណា។ លោក ពីរថ្ងៃមុននេះលោកបានបញ្ជាក់ថា ពូរបស់លោកគឺ ប៉ុល ពត មិនអាចធ្វើសេចក្ដីសម្រេចតែម្នាក់ឯងបានទេ។ លោកនៅចាំថា លោកបានៗនិយាយថាអ៊ីចឹងទេ?

**ឆ៖** បាទ ខ្ញុំចាំ។

**ស៖** ហើយតាមពិតទៅ ខ្ញុំជឿទៅ លោកនិយាយថា និយាយរួមសេចក្ដីសម្រេចត្រូវតែធ្វើរួមគ្នា។ តើនេះជាការយល់ឃើញរបស់លោក ឬយ៉ាងណា?

[១៥:៥១:៤៦]

**ឆ៖** ជាការរៀនសូត្រផង ជាការយល់ឃើញរបស់ខ្ញុំផង។

**អ្នកបកប្រែ៖**

សូមអធ្យាស្រ័យលោកប្រធាន មេធាវីអត់បានបើកក្បាលមីក្រូ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** សំណួរតាមដែលខ្ញុំយល់នោះ គឺថាលោកមិនដែលបានឃើញ ឬក៏លោកមិនបានចូលរួមនៅក្នុងការធ្វើសេចក្ដីសម្រេចទេ? តើនេះត្រឹមត្រូវដែរទេ?

**លោក សាឡុត បាន៖**

**ឆ៖** *(និយាយមិនបើកមីក្រូហ្វូន)*

**ស៖** បាទ សូមអរគុណ។--

**ប្រធានអង្គជំនុំ៖**

ឲ្យគាត់ឆ្លើយសិន! គាត់អត់ទាន់ឆ្លើយទេ។

**លោក សាឡុត បាន៖**

**ឆ៖** បាទ ជាការត្រឹមត្រូវ។

**លោក ម៉ែខល កាណាវាស៖**

ឥឡូវយើងសូមចូលត្រឡប់ទៅមើលឯកសារដែលគេបានបង្ហាញទៅលោក គឺD233/2 ហើយក៏ជាឯកសារ E3/415។ ទំព័រជាភាសាខ្មែរ 00357530 ដល់ 31, ERN ជាភាសាបារាំង 00404555 ERN ជាភាសាអង់គ្លេស 00361013។ ខ្ញុំ-- លោកប្រធានខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះ ដើម្បីបង្ហាញឯកសារនេះជូនទៅដល់សាក្សី។ ឯកសារ-- សាក្សីធ្លាប់បានឃើញឯកសារនេះហើយ ហើយខ្ញុំនឹងប្រើប្រាស់ការបង្ហាញឯកសារតែបីបួនប្រាំនាទីចុងក្រោយនេះតែប៉ុណ្ណោះ។

[១៥:៥៥:០៣]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការស្រាវជ្រាវរកឯកសារអម្បាញ់មិញនេះដាក់ជូនសាក្សីពិនិត្យ!

**សួរដោយលោក ម៉ែខល កាណាវាស៖**

**ស៖** លោកបានឃើញឯកសារនេះហើយឬនៅ?

**លោក សាឡុត បាន៖**

**ឆ៖** បាទ ឃើញហើយ។

**ស៖** បើសិនយើងមើលទៅដល់ចុងបញ្ចប់នៃសំណួរនេះ សួរថា "ដូច្នេះ មានន័យតែ សូម្បីតែ-- ដូច្នេះមានន័យថា ប៉ុល ពត មិនអាចសម្រេចតែម្នាក់ឯងបានទេ។ ពេលនោះ តាមខ្ញុំឮ ខ្ញុំដឹង គឺពូ ប៉ុល ពត គាត់ទទួលខាងនយោបាយ ហើយបង នួន ជា ទទួលខាងចាត់តាំង"។ តើលោកនៅចាំទេ ថាលោកបានផ្តល់ចម្លើយនេះ នៅពេលដែលលោកត្រូវបានសាក្សីសួរនោះ?

**ឆ៖** បាទ ខ្ញុំចាំ។

**ស៖** ប្រសិនណាជាយើងមើលទៅលើបន្តិចទៀត ថាតើម៉េចបានលោកឈានមកដល់ការធ្វើសេចក្តីសន្និដ្ឋានបែបនេះ? លោកបាននិយាយថា លោកបានទទួលព័ត៌មានខ្លះដែលគេឲ្យប្រាប់មកគាត់

ទាក់ទងទៅនឹង ហ៊ួ យន់។ តើលោកនៅចាំទេ នេះគឺជាផ្នែកមួយនៃចម្លើយរបស់លោកដែលលោកបានផ្តល់ជូនសហចៅក្រមស៊ើបអង្កេតនោះ?

ខ្ញុំសូមអានផ្នែកនេះជូនលោកទាំងស្រុងតែម្តង "ដល់ពេល ហ៊ួ យន់ ស្លាប់ គេចោទដាក់ ប៉ុល ពត តែមិនដឹងថា ហ៊ួ យន់ សម្លាប់ពីមូលហេតុអ្វីទេ។ តាមខ្ញុំដឹងនៅពេល ហ៊ួ យន់ នៅរស់ លោក ប៉ង់ តែងតែនិយាយថា ប៉ុល ពត សុំយក ហ៊ួ យន់ មកនៅក្បែរគាត់ធ្វើជាលេខា ប៉ុន្តែមិនដឹងជាមូលហេតុអ្វីបានជាមជ្ឈិមមិនយល់ព្រម។ ពេលបាត់ ហ៊ួ យន់ ខ្ញុំគិតថាវាមានមូលហេតុអ្វីបានជាដូច្នេះ។ ដូច្នេះមានន័យថា ប៉ុល ពត មិនអាចសម្រេចតែម្នាក់ឯងបានទេ"។ តើលោកឃើញចម្លើយនេះទេ ហើយលោកដឹងថា លោកបាននិយាយដូច្នេះទេ?

[១៥:៥៨:៣៩]

**ឆ៖** ពេលដែលសួរចម្លើយនេះ គឺខ្ញុំបានចូលមក គេហៅថា បានសមាហរណកម្មចូលមកក្នុងប្រទេសហើយ។ ចម្លើយខ្ញុំមានតែមួយទេ បើ ប៉ុល ពត សម្រេចខ្លួនឯងបានម៉េចក៏ តាម៉ុក ទៅសម្លាប់ធ្វើឲ្យ ប៉ុល ពត ស្លាប់។ ដូច្នេះចម្លើយនេះ ខ្ញុំគិតថា ដោះស្រាយបញ្ហានេះបានហើយ គាត់មិនសម្រេចអីតែឯងទេបាទ។ អំណាចរបស់សត្រូវ ឬ ប៉ុល ពត តែម្តង។

**សៈ** ឥឡូវសូមកុំអាលនិយាយអំពី តាម៉ុក និយាយអំពីពូរបស់លោកសិននៅពេលដែលគាត់ត្រូវបានចាប់ខ្លួន ហើយគេយកមកកាត់ទោសនោះ គឺថាផ្តោតទៅលើចម្លើយរបស់លោកនេះសិន។ លោកបានប្រាប់ថា ប៉ង់ បានប្រាប់លោកថា "ប៉ុល ពត ចង់យក ហ៊ួ យន់ មកធ្វើជាលេខារបស់គាត់"។ តើលោកឆ្លើយថា អ៊ីចឹងមែនទេ? ហើយពេលខ្លះនោះ គឺថា ខាងគណៈមជ្ឈិមបានធ្វើអន្តរាគមន៍ ហើយរារាំងមិនឲ្យ ហ៊ួ យន់ នេះក្លាយមកជាលេខារបស់ ប៉ុល ពត ទេ។ តើវាត្រឹមត្រូវដូច្នេះមែនទេ?

**ឆ៖** បាទ។

**សៈ** ក្រៅពីអ្វីដែលលោក ប៉ង់ បានប្រាប់មកលោកនោះ លោក តើលោកមានព័ត៌មានណាផ្សេងទៀត ដែលបញ្ជាក់ថាវាបន្ថែមទម្ងន់ដើម្បីឲ្យបញ្ជាក់ឲ្យឃើញថា ពូរបស់លោក គឺ ប៉ុល ពត ពិតជាចង់យក ហ៊ួ យន់ មកធ្វើជាលេខារបស់គាត់នោះ?

**ឆ៖** គ្មានអីបញ្ជាក់ថែមទៀតទេ។ រឿងនេះមានទម្ងន់នៅពេលដែល-- ពេលនៅពេលដែល--

**សៈ** តើ ប៉ុល ពត ពូរបស់លោកនេះ ដែលធ្លាប់ប្រាប់លោកថា គាត់ចង់យក ហ៊ួ យន់ មកធ្វើការជាលេខារបស់គាត់ ឬក៏មាន-- ហើយមានប្រាប់លោកថាដោយសារតែគណៈមជ្ឈិមនេះបានរារាំង

មិនឲ្យយក ហ៊ូ យន់ មកធ្វើជាលេខានោះ?

[១៦:០១:៤៧]

**ឆ៖** លោកមិនដែលប្រាប់ខ្ញុំទេ។ សម្ដីនេះចេញតែពីលោក ប៉ង់ ទេ។

**ស៖** ដូច្នេះ បើសិនណាជាក្រឡេកទៅមើលចម្លើយរបស់លោក លោកមាន-- លោកលើកឡើងថា "ដូច្នេះមានន័យថា ប៉ុល ពត មិនអាចសម្រេចតែម្នាក់ឯងបានទេ"។ លោកសាក្សី តើលោកសំអាងទៅលើចម្លើយដែលលោកឆ្លើយនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយនេះ ដោយសំអាងតែទៅលើអ្វីដែល ប៉ង់ បានប្រាប់មកលោកអំពីបញ្ហា ហ៊ូ យន់ និង ពូរបស់លោក? នេះគឺជាព័ត៌មានតែមួយគត់ដែលលោកទទួលបាន ហើយឲ្យលោកធ្វើសេចក្ដីសន្និដ្ឋានថា ពូរបស់លោកមិនអាចសម្រេចតែម្នាក់ឯងបានទេ?

**ឆ៖** ពេលដែលគេប្រាប់ក្នុងពេលនោះ ខ្ញុំមិនសម្រេចទេ ពេលវេលានោះណ៎ា ខ្ញុំអត់សម្រេចថា អ៎! លោកពូខ្ញុំមិនអាចសម្រេចអីបានទេ។ ដល់ពេលមកឃើញសភាពការណ៍ចុងក្រោយនេះ ដែល តាម៉ុក គាត់នែ៎ ខ្ញុំថាអ៊ីចេះចុះ តាម៉ុក គាត់ប្រឆាំងនឹង ប៉ុល ពត បានខ្ញុំឃើញថា អូ! នេះហើយដែលជាអ្វីដែល ប៉ុល ពត ធ្វើជាលេខាមែន ដែលការគោរពពីដើម ឥឡូវប្រែជាឈប់គោរពវិញ។ ដូច្នេះ បានថាអ្វីសម្រេចខ្លួនឯងមិនបានទេ។ អានេះមួយណ៎ាលោកណ៎ា។ ប៉ុន្តែទីពីរ ច្បាប់ក្នុងនេះ គឺថាសមូហភាពវាធំជាងបុគ្គល ឲ្យតែបុគ្គលភាគច្រើន គឺភាគច្រើនហ្នឹង ភាគតិចហ្នឹង គឺត្រូវគោរពភាគច្រើន។ នេះដែលខ្ញុំយល់។

[១៦:០៤:១១]

**ស៖** លោកប្រធាន ខ្ញុំនៅសល់តែមួយសំណួរទៀតទេ ដោយសារថាវាម៉ោងជាងបួនទៅហើយ។ នៅពេលដែលលោកនិយាយថា ប៉ុល ពត ប្រឆាំង-- តាម៉ុក ប្រឆាំងជាមួយ ប៉ុល ពត ដែលជាពូរបស់លោក។ បានសេចក្ដីថាលោកទើបលើកឡើងអម្បាញ់ៗនេះ។ តើលោកកំពុងតែនិយាយសំដៅទៅលើឆ្នាំ ១៩៩៦-៩៧ ឬយ៉ាងណា? តើនេះជារយៈពេលដែលលោកកំពុងនិយាយសំដៅយោងទៅនុ៎ង ឬក៏មិនមែនទេ?

**ឆ៖** បាទ ខ្ញុំសំដៅយោង៩៦-៩៧ បាទ។

**ស៖** នេះគឺក្រោយពេលដែល សុន សេន និងក្រុមគ្រួសារគាត់ទាំងមូលត្រូវបានគេសម្លាប់ចោល ប្រហែលជាគេសន្និដ្ឋានថា សុន សេន និងក្រុមគ្រួសារគាត់ត្រូវពូរបស់លោក ជាអ្នកចាត់ការសម្លាប់ចោល។ តើនេះត្រឹមត្រូវទេ?

**ឆ៖** បាទ ការត្រឹមត្រូវ។

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ។ ហើយខ្ញុំសូមអរគុណអង្គជំនុំជម្រះយ៉ាងច្រើន ដែលបានអនុញ្ញាតឲ្យខ្ញុំអូសបន្លាយពេលបួនប្រាំនាទី ចុងក្រោយបន្ថែមទៀតនេះ។

[១៦:០៥:៣៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះកិច្ចដំណើរការសម្រាប់ថ្ងៃនេះ សមល្មមនឹងដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី៣០ ខែមេសា ឆ្នាំ២០១២ ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

អរគុណសាក្សី ដែលបានខិតខំប្រឹងប្រែងអំណត់ អត់ធ្មត់ ហើយនិងផ្តល់អារម្មណ៍ក្នុងការតាំងសំណួរដ៏ច្រើនរយៈពេលប៉ុន្មានថ្ងៃនេះ។ ប៉ុន្តែដោយបញ្ហាវាធំធេង ហើយស្មុគស្មាញនោះ គឺកិច្ចដំណើរការតាំងសំណួរដេញដោលចំពោះលោក គឺមិនទាន់ចប់ទេ ប្រហែលជាទំនងនៅមួយថ្ងៃទៀតគឺថ្ងៃចន្ទ។ ដូច្នេះ អង្គជំនុំជម្រះសូមអញ្ជើញលោកមកបន្តការផ្តល់សក្ខីកម្ម សម្រាប់ថ្ងៃចន្ទ ដែលដើមសប្តាហ៍ក្រោយតទៅទៀត។ ហើយដូចគ្នា គឺសូមអញ្ជើញមេធាវីទីប្រឹក្សា អ៎ មេធាវីប្រឹក្សាសាក្សី ក៏សូមអញ្ជើញមកបន្តការអង្គុយអមសាក្សី ដើម្បីប្រឹក្សាក្នុងករណីមានយថាហេតុនៃការតាំងសំណួរផ្សេងៗ ដែលនាំឲ្យចម្លើយដាក់ពិរុទ្ធភាពលើសាក្សី។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយនិងឲ្យនាំពួកគាត់មកកាន់បន្ទប់សវនាការនេះ នៅព្រឹកថ្ងៃចន្ទ ទី៣០ ខែមេសា ឆ្នាំ២០១២ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។ សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៧ នាទី)*